# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់ឪពុកម្តាយ ចំពោះការអប់រំរបស់កូន

# នៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ

# PARENTAL INVOLVEMENT WITH CHILD´S EDUCATION IN PRIMARY SCHOOL IN PHNOM PENH

ដោយ/By

**ឈន បូរ៉ា**

CHHORN BORA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស ៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨ - ២០២០

## ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education

# និក្ខេបបទ

# ការចូលរួមរបស់ឪពុកម្ដាយ ចំពោះការអប់រំរបស់កូននៅ បឋមសិក្សាក្នុងរាជធានីភ្នំពេញ

## PARENTAL INVOLVEMENT WITH CHILD´S EDUCATION IN PRIMARY SCHOOL IN PHNOM PENH

**ដោយ**/By

**ឈន បូរ៉ា**/ CHHORN BORA

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨ - ២០២០**

**គ្រូដឹកនាំបង្គោល៖ លោកស្រី នូ ចន្ធី**

**គ្រូដឹកនាំរង៖ លោក នី រដ្ឋា**

# សេចក្ដីអះអាងរបស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា « **ការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ជូតទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**ឈន ម៉ូរ៉ា**

## លិខិតបញ្ជាក់

**លោកស្រី នូ ចន្ធី** ជាគ្រូដឹកនាំបង្គោល

**លោក នី រដ្ឋា** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **ឈន មូរ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការចូលរួមរបស់ឪពុកម្តាយ ចំពោះការអប់រំរបស់កូននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

.................................... ....................................

**លោកស្រី នូ ចន្ធី** **លោកបណ្ឌិត នី រដ្ឋា**

គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៣០៧ **អយក.ឧទ្ទ**

(**ការសម្គាល់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ រ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វុទ្ធារ៉ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំសូមសម្តែងនូវការដឹងគុណ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម នាយក សាស្ត្រាចារ្យ លោក លោកស្រី ជាថ្នាក់ដឹកនាំនៃវិទ្យាស្ថានជាតិ អប់រំ(NIE) ដែលបានយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលដល់នាងខ្ញុំ ក៏ដូចជាផ្តល់ឱកាសក្នុងការសិក្សាស្រាវជ្រាវក្រេងស្នាដៃនេះប្រកបដោយជោគជ័យ។ ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាជ្រៅចំពោះ **លោកស្រី នូ ចន្ធី** ជាគ្រូដឹកនាំបង្គោល និងលោក **បណ្ឌិត នី រដ្ឋា** ជាគ្រូដឹកនាំរង ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ពន្យល់ និងកែសម្រួលនិក្ខេបបទនេះតាំងពីចាប់ផ្តើមរហូតបញ្ចប់។

នាងខ្ញុំសូមថ្លែងអំណរគុណដល់លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញដែលបានសម្របសម្រួល និងអនុញ្ញាតឱ្យនាងខ្ញុំបានចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅ។ ជាមួយគ្នានេះដែរ នាងខ្ញុំក៏សូមអរគុណដល់នាយក លោកគ្រូ អ្នកគ្រូក្នុងសាលាគោលដៅទាំងប្រាំបី និងអាណាព្យាបាលសិស្សដែលចំណាយពេលវេលា និងកិច្ចសហការក្នុងការផ្តល់ពត៌មានដល់រូបនាងខ្ញុំដើម្បីឱ្យបានដំណើរការប្រមូលទិន្នន័យ និងការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។

ជាពិសេស នាងខ្ញុំសូមថ្លែងអំណរគុណដល់គ្រួសារដែលបានផ្តល់កម្លាំងចិត្តគ្រប់ពេលវេលា និងបងប្អូនដែលជួយរួមចំណែកក្នុងការជួយសម្រួលបច្ចេកទេសកុំព្យូទ័រ មិត្តរួមថ្នាក់ដែលបានចែករំលែកបទពិសោធន៍ ចំណេះដឹង និងផ្តល់យោបល់ទៅវិញទៅមក។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពជូនពរចំពោះលោក លោកស្រី លោកគ្រូ អ្នកគ្រូទាំងអស់សូមមានសុខភាពល្អ កម្លាំងកាយមាំមួនជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការចូលរួមរបស់ឪពុកម្តាយចំពោះការសិក្សារបស់កូនមានសារៈសំខាន់ដែល ជះឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលសិក្សា គុណភាពអប់រំ និងភាពជោគជ័យរបស់សិស្សនាពេលអនាគត។ផ្ទុយទៅវិញមានឪពុកម្តាយមួយចំនួនមិនបានយកចិត្តទុកដាក់ក្នុងការចូលរួមចំពោះការសិក្សាអប់រំកូន។ ដូចនេះហើយទើបអ្នកស្រាវជ្រាវសម្រេចចិត្ត ជ្រើសរើសប្រធានបទនេះក្នុងគោលបំណងរកឱ្យឃើញនូវ (១) ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយ ចំពោះការសិក្សារបស់កូន (២) បញ្ហាប្រឈមដែលជះឥទ្ធិពល ដល់ការចូលរួមរបស់ឪពុកម្តាយ (៣) យុទ្ធសាស្រ្តក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមក្នុងការអប់រំកូន។ ការសិក្សានេះរៀបចំឡើងដោយប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ ដោយភាគសំណាកជ្រើសចេញពីបឋមសិក្សាទាំងប្រាំបី នៃខណ្ឌទាំងប្រាំពីរក្នុងរាជធានីភ្នំពេញ។ ភាគសំណាកដែលបានបំពេញកម្រងសំណួររួមមាន ឪពុកម្តាយសិស្ស ឬអ្នកអាណាព្យាល លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ យោងតាមលទ្ធផលនៃការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ឪពុកម្តាយសិស្ស មួយចំនួនបានចូលរួមក្នុងដំណើរការសិក្សារបស់កូនដូចជា ការជួយធ្វើកិច្ចការផ្ទះកូន ការបង្ហាត់បង្រៀន និងពិនិត្យតាមដាន ការជំរុញ និងលើកទឹកចិត្តកូន ការទំនាក់ទំនងជាមួយសាលារៀននៅមានកម្រិតដោយផ្អែកលើតម្លៃមធ្យមសរុប(m=2,65)បង្ហាញថាឪពុកម្តាយនៅទីក្រុងភ្នំពេញបានចូលរួមចំពោះការអប់រំរបស់កូនក្នុងកម្រិតមធ្យម ដោយសារមានកត្តាមួយចំនួនដែលរាំងស្ទះដល់ដំណើរការនៃចូលរួមរបស់ឪពុកម្តាយរួមមានដូចជា កត្តាចំណេះដឹងឪពុកម្តាយ និងធនធានសេដ្ឋកិច្ច កត្តាពេលវេលា កត្តាកង្វះទំនាក់ទំនងជាមួយសលា កត្តាជីវភាពជាដើម។លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះក៏បង្ហាញឱ្យឃើញផងដែរថាមានឪពុកម្តាយនៅរាជធានីភ្នំពេញតិចតួចណាស់ដែលបានចូលរួមក្នុងដំណើរការនៃការអប់រំកូនពេញលេញនិងទៀងទាត់ជាប្រចាំ។ ជាមួយគ្នានេះដែរការសិក្សានេះ បង្ហាញឱ្យឃើញផងដែរពីចំណុចសំខាន់នៃយុទ្ធសាស្រ្តក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមនៅក្នុងការអប់រំកូនឱ្យកាន់តែប្រសើរឡើងជាងមុន។

# ABSTRACT

Observing that some parents are not paying attention to their children's education, on the contrary, parents 'involvement in their children's education has a significant impact on their academic performance, ensuring their students' education and success in the future. Therefore, the researchers decided to choose this topic in order to find out (1) the process of parental involvement in their child's education (2) the challenges that affect parental involvement (3) strategies for Encourage and motivate parents to be involved in their children's education. The study was conducted by collecting quantitative data by sector, selected from the eight primary schools of the seven districts in Phnom Penh. The sample that completed the questionnaire included the principal, teachers, students and parents. According to the research, the process of parental involvement includes helping with household chores, training and monitoring, encouraging and encouraging parent-school communication, parenting knowledge and economic resources. The results show that parents are involved in their children's learning process at an average level, and very few parents are fully involved in all types of participation.

At the same time, the study identified a number of challenges that hinder parents' involvement in educating their children. Participate in your child's education for the better.

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ..... iii

**លិខិតបញ្ជាក់** ..... iv

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ..... v

**មូលន័យសង្ខេប** ..... vii

ABSTRACT ..... viii

**បញ្ជីតារាង** ..... xii

**បញ្ជីក្រាហ្វ** ..... xiii

**ជំពូកទី១ ៖ សេចក្តីផ្តើម** ..... 1

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... 1

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... 2

១.៣. គោលបំណងនៃការស្រាវជ្រាវ ..... 3

១.៤. សំណួរស្រាវជ្រាវ ..... 4

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ..... 4

១.៦. ដែនកំណត់នៃការស្រាវជ្រាវ ..... 5

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... 5

**ជំពូកទី២៖ ការរំលឹកទ្រឹស្តី** ..... 7

២.១. សេចក្តីផ្តើម ..... 7

២.២. និយមន័យ ..... 7

២.៣. ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន ..... 8

២.៣.១. ការចូលរួមចំពោះកិច្ចការផ្ទះរបស់កូន ..... 10

២.៣.២. ការបង្ហាត់បង្រៀន និងការពិនិត្យតាមដានការសិក្សា ..... 10

២.៣.៣. ការជំរុញ និងការលើកទឹកចិត្ត ..... 12

២.៣.៤. ភាពជាដៃគូរវាងសាលារៀន និងគ្រួសារ ..... 13

២.៣.៥. ចំណេះដឹងរបស់ឪពុកម្តាយ ........ 14

២.៤. កត្តាដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយ ........ 15

២.៤.១. កត្តាចំណេះដឹងរបស់ឪពុកម្តាយ ........ 16

២.៤.២. កត្តាទំនាក់ទំនងរវាងគ្រួសារ និងសាលារៀន ........ 17

២.៤.៣. កត្តាជីវភាពគ្រួសារ ........ 18

២.៤.៤. ការផ្តល់ព័ត៌មានដល់ឪពុកម្តាយ ........ 19

២.៥.យុទ្ធសាស្ត្រក្នុងការជំរុញ និងការលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមការសិក្សារបស់កូន ........ 19

**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ** ........ 21

៣.១. ការជ្រើសរើសភាគសំណាក ........ 21

៣.២. ឧបករណ៍ស្រាវជ្រាវ ........ 20

៣.៣.១.ដំណើរការនៃការប្រមូលទិន្នន័យ ........ 21

៣.៣.១.១ ការសាកល្បង ........ 22

៣.៣.១.២. ការប្រមូលទិន្នន័យ ........ 22

៣.៣.២. ការវិភាគទិន្នន័យ ........ 23

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** ........ 24

៤.១. លទ្ធផល ........ 24

៤.១.១. ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន ........ 24

៤.១.១.១. ការចូលរួមចំពោះកិច្ចការផ្ទះរបស់កូន ........ 24

៤.១.១.២. ការបង្ហាត់បង្រៀន និងការពិនត្យតាមដាន ........ 26

៤.១.១.៣. ការជំរុញ និងការលើកទឹកចិត្ត ........ 28

៤.១.១.៤. ភាពជាដៃគួរវាងគ្រួសារ និងសាលារៀន ........ 30

៤.១.១.៥. កត្តាចំណេះដឹងឪពុកម្តាយ និងធនធានសេដ្ឋកិច្ច ........ 33

៤.១.២.បញ្ហាប្រឈមក្នុងការចូលរួមរបស់ឪពុកម្តាយ ........ 35

៤.១.២.១. កត្តាចំណេះដឹងរបស់ឪពុកម្តាយ ........ 36

៤.១.២.២. កត្តាទំនាក់ទំនងរវាងឪពុកម្តាយ និងសាលារៀន ........ 37

៤.១.២.៤. កត្តាពេលវេលា ........ 39

៤.១.៣.យុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមក្នុងការសិក្សារបស់កូន 40

៤.២. ការពិភាក្សា ........ 43

៤.២.១. ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន ....................................44
៤.២.១.១. ការចូលរួមជួយធ្វើកិច្ចការផ្ទះរបស់កូន ..........................................................44
៤.២.១.២. ការបង្ហាត់បង្រៀន និងត្រួតពិនិត្យតាមដាន ....................................................45
៤.២.១.៣. ការជំរុញ និងការលើកទឹកចិត្ត.....................................................................46
៤.២.១.៤. ការទំនាក់ទំនងរវាងគ្រួសារ និងសាលារៀន ....................................................47
៤.២.១.៥. កត្តាចំណេះដឹងរបស់ឪពុកម្តាយនិងធនធានសេដ្ឋកិច្ចគ្រួសារ ............................48
៤.២.២.បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយ ...................................49
៤.២.៣.យុទ្ធសាស្ត្រក្នុងការជំរុញនិងលើកទឹកចិត្តឪពុកម្តាយក្នុងការចូលរួមការអប់រំកូន ............50
**ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ**........................................................................51
៥.១. សន្និដ្ឋាន ............................................................................................51
៥.២. សំណូមពរ ...........................................................................................52
៥.៣. ការសិក្សាស្រាវជ្រាវបន្ត...............................................................................53
ឯកសារយោង............................................................................................54
ឧបសម្ព័ន្ធ ...............................................................................................57

# បញ្ជីតារាង

តារាងទី 1៖ បង្ហាញពីភាគសំណាកនៅតាមសាលានីមួយៗ ........................................................ 21
តារាងទី 2៖ បង្ហាញពីការចូលរួមចំពោះកិច្ចការផ្ទះរបស់កូន ........................................................ 26
តារាងទី 3៖ បង្ហាញពីការបង្ហាត់បង្រៀន និងការពិនិត្យតាមដាន.................................................. 26
តារាងទី 4៖ បង្ហាញពីភាពជាដៃគូរវាងគ្រួសារ  និងសាលារៀន .................................................... 30
តារាងទី 5៖ បង្ហាញពីកង្វះទំនាក់ទំនងរវាងឪពុកម្តាយ និងសាលារៀន ......................................... 37
តារាងទី 6៖ បង្ហាញពីយុទ្ធសាស្រ្តក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយ................................... 40

# បញ្ជីក្រាហ្វ

ក្រាហ្វទី 1៖ បង្ហាញពីការចូលរួមចំពោះកិច្ចការផ្ទះរបស់កូន ........................................................24
ក្រាហ្វទី 2៖ បង្ហាញពីការជំរុញ និងលើកទឹកចិត្តកូន ....................................................................29
ក្រាហ្វទី 3៖ បង្ហាញពីកម្រិតសិក្សារបស់ឪពុកម្តាយ..................................................................33
ក្រាហ្វទី 4៖ បង្ហាញពីបញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយ ........................35
ក្រាហ្វទី 5៖ បង្ហាញពីកត្តាចំណេះដឹងរបស់ឪពុកម្តាយ ................................................................36
ក្រាហ្វទី 6៖ បង្ហាញពីប្រាក់ចំណូលរបស់ឪពុកម្តាយ ...................................................................39

# អក្សរកាត់

Q : Question

Pa : Parent

T : Teacher

Stu : Student

# ជំពូកទី១ ៖ សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

ការអប់រំមានសារៈសំខាន់ខ្លាំងណាស់ចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនិងការលុបបំបាត់ភាពក្រីក្រដែលពិភពលោកទទួលស្គាល់និងឱ្យតម្លៃ គ្មានការអភិវឌ្ឍសេដ្ឋកិច្ចណាដែលអាចធ្វើទៅបានបើគ្មានការអប់រំ (Omoniyi, 2013)។ ការអប់រំដែលមានគុណភាពល្អផ្តល់ឱ្យអ្នកសិក្សានូវសមត្ថភាពដែលពួកគេត្រូវការដើម្បីក្លាយជាអ្នកផលិតលើកកម្ពស់សេដ្ឋកិច្ចអភិវឌ្ឍជីវភាពប្រកបដោយនិរន្តរភាពរួមចំណែកដល់ការកសាងសង្គមសន្តិភាព លទ្ធិប្រជាធិតេយ្យ និងលើកកម្ពស់សុខុមាលភាពសង្គម ។ ជាមួយគ្នានេះដែរ ការអប់រំគឺត្រូវចាប់ផ្តើមពីកុមារភាព និងត្រូវយកចិត្តទុកដាក់ជាចាំបាច់ ពីព្រោះកុមារ គឺជាសសរ ទ្រូងប្រទេសជាតិ និងជាក្តីសង្ឃឹមអនាគតនៃពិភពលោក។ ការអប់រំកុមារទាមទារឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន គ្រួសារ សាលារៀន សហគមន៍ សហការគ្នាទើបធ្វើឱ្យគ្រាប់ពូជនេះអាចក្លាយជាមូលធនមនុស្សដែលមានសក្តានុពលសម្រាប់អភិវឌ្ឍប្រទេសប្រកបដោយសុវត្ថិភាព និងនិរន្តរភាព។ ដើម្បីអភិវឌ្ឍប្រទេសមួយ ពេលអនាគតដែលប្រកបដោយសុវត្ថិភាព កុមារគឺជាអាវុធសម្រាប់កសាងប្រទេសជាតិជាមួយនឹងចំណេះដឹង និងការអប់រំរបស់ពួកគេ។ ជាក់ស្តែងនៅអូកឡែនដ៍ សហរដ្ឋអាមេរិច គេជឿថាគ្រួសារ និងគ្រូគឺជាកត្តាបឋមនិងមានឥទ្ធិពលចំពោះភាពជោគជ័យរបស់សិស្ស ហើយគួរតែគាំទ្រដោយស្រុក សាលារៀន និងសហគមន៍ក្នុងការបង្កើតឱកាសសិក្សាសម្រាប់សិស្សក្នុងម៉ោង និងក្រៅម៉ោង (សាលារៀនសហគមន៍, 2013)។

ស្របគ្នានេះដែរនៅក្នុងបរិបទកម្ពុជា ដើម្បីលើកកម្ពស់ការអប់រំ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំយុវជននិងកីឡាបានជំរុញ និងលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាននិងពីគ្រប់ភាគីពាក់ព័ន្ធ។ ក្នុងន័យនេះដើម្បី ជំរុញនិងលើកកម្ពស់គុណភាពអប់រំឱ្យមានលក្ខណៈសកលកម្ម រដ្ឋាភិបាលបានដាក់ចេញគោលដៅអប់រំជាតិ គឺកសាងមនុស្សពេញលេញដែលមានការរីកចម្រើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នាប្រកបដោយតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបកាយ ពោលគឺពលរដ្ឋដែលមានលក្ខណៈថ្លៃថ្នូរ មានមនសិការស្នេហាជាតិ ស្រលាញ់យុត្តិធម៌ គោរពច្បាប់ និងសិទ្ធិមនុស្ស ចេះថែរក្សាការពារបរិស្ថាន ចេះ

ផ្សព្វផ្សាយ និងលើកកម្ពស់តម្លៃវប្បធម៌ អរិយធម៌ជាតិ មានភាពម្ចាស់ការទទួលខុសត្រូវ មានទំនុកចិត្តលើខ្លួនឯង ចេះដោះស្រាយបញ្ហាក្នុងជីវភាព ចេះច្នៃប្រឌិត ចេះធ្វើពលីកម្ម មានស្មារតីទទួលខុសត្រូវខ្ពស់មានសមត្ថភាពកសាងសុខុមាលភាពគ្រួសារ ហើយអាចចូលរួមយ៉ាងសកម្មក្នុងការបង្រួបបង្រួមជាតិ ស្តារនិងអភិវឌ្ឍមាតុភូមិ ជាទីស្នេហាដោយផ្អែកលើស្មារតីប្រជាធិតេយ្យសេរីពហុបក្ស (រាជរដ្ឋាភិបាល, ២០០៧)។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជននិងកីឡាជាស្ថាប័នសាមីក្នុងការធ្វើឱ្យសម្រេចគោលដៅអប់រំជាតិនេះ បានដាក់ចេញគោលនយោបាយជាយុទ្ធសាស្ត្រទាំងបួន ក្នុងនោះបានផ្តោតសំខាន់ផងដែរទៅលើទំនើបកម្ម និងកំណែលម្អគុណភាពអប់រំ តាមរយៈកំណែទម្រង់ដ៏មានប្រសិទ្ធភាព គឺការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ។ ការអនុវត្តតាមប្រព័ន្ធនៃការគាំទ្ររួមគ្នា សាលារៀនត្រូវបង្កើនភាពជាដៃគូជាមួយឪពុកម្តាយ និងអភិវឌ្ឍទំនួលខុសត្រូវទៅវិញទៅមកចំពោះភាពជោគជ័យនៃប្រពន្ធ័អបរំ (Studies, 2017)ការចូលរួមរបស់មាតាបិតា ត្រូវបានជំរុញពីរដ្ឋាភិបាលយ៉ាងពេញទំហឹងតាមរយៈគោលនយោបាយ និងច្បាប់ផ្សេងៗ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាទូទៅឪពុកម្តាយមានតួនាទីយ៉ាងសំខាន់ ក្នុងការណែនាំអប់រំកូនឱ្យក្លាយជាមនុស្សល្អ ក៏ជាគ្រូទី១របស់សិស្ស ដែលបានបង្ហាត់កូន ឱ្យចេះដើរ និយាយ រាប់លេខ អក្សរ និងចេះគូសវាស។ បណ្តុះមូលដ្ឋានផ្នែកបញ្ញា ស្មារតី សតិអារម្មណ៍ អភិវឌ្ឍប្រពន្ធ័តម្លៃ សីលធម៌ អាកប្បកិរិយារបស់កូន មុនពេលចូលសាលា និងក្រោយពេលចូលសាលា។ ប៉ុន្តែទោះជាយ៉ាងនេះក្តី មានឪពុកម្តាយមួយចំនួនពឹងផ្អែកទាំងស្រុងទៅលើសាលារៀន ពួកគាត់យល់ថាការអប់រំកូនៗ ពួកគាត់ គឺជាបន្ទុក និងតួនាទីរបស់សាលារៀនហើយក៏មានឪពុកម្តាយខ្លះមិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងកាជួយកូនដែរដូចជា ពួកគាត់មិនមានពេលវេលាគ្រប់គ្រាន់ ចំណេះដឹងមានកម្រិត ជីវភាពខ្វះខាតជាដើម ។ ឪពុកម្តាយខ្លះយល់ថា កម្មវិធីសិក្សា បច្ចុប្បន្នមានលក្ខណៈខុសគ្នាពីកម្មវិធីសិក្សាដែលពួកគាត់ធ្លាប់បានរៀន ដូចនេះពួកគាត់មិនសូវយល់ដឹងស៊ីជំរៅនូវខ្លឹមសារមេរៀននិងពិបាកពន្យល់កូន (Sophoat, 2011) ។

បច្ចុប្បន្នទស្សនៈមានមួយចំនួនលេចឡើងពីក្នុងមជ្ឈដ្ឋានសង្គមផ្តោតការយកចិត្តទុកដាក់លើលទ្ធផលសិក្សារបស់កូនៗតាមរយៈ ការវិនិយោគការអប់រំកូនជាមួយសាលាដែលមានបង់ថ្លៃឈ្នួលខ្ពស់។ មាតាបិតារំពឹងថាការអប់រំកុមារ(កូនៗ)ជាកាតព្វកិច្ចរបស់សាលារៀន ដូចមានទស្សនៈលើកឡើងថា ពេលកូនរៀនពូកែគឺមកពីកត្តាពូជពង្សគេល្អ តែលទ្ធសិក្សាមិនល្អគឺមកពីកត្តាគ្រូបង្រៀនទៅវិញ។ យោងតាមការសង្កេតជាក់ស្តែង មាតាបិតាតែងតែផ្តល់លទ្ធភាពឱ្យកូនរៀនជាលក្ខណៈបំប៉នជាមួយគ្រូក្រៅម៉ោងតែជាជាងពួកគាត់ចំណាយពេលជួយបង្រៀន ឬតាមដានការសិក្សារបស់កូន។ ម្យ៉ាងទៀត ទំនាក់ទំនងរវាងឪពុកម្តាយនិងសាលារៀនជារឿងសំខាន់ ប៉ុន្តែទំនាក់ទំនងនេះមិនទាន់ ផ្តោតឲ្យចំទៅលើការផ្តល់ព័ត៌មានស៊ីជម្រៅលើកិច្ចសហការដើម្បីធ្វើឱ្យការសិក្សានិងអប់រំទាន់ពេលវេលានិងប្រសើរឡើងទេ។ ជាលទ្ធផលនៃការជួយមិនទាន់ពេលវេលាអាចធ្វើឱ្យកុមារខាតបង់ឱកាសកែលម្អ និងអភិវឌ្ឍសមត្ថភាពតាមកម្រិតនឹងឈានទៅដល់ការបោះបង់ការសិក្សាទៀតផង ។ឪពុកម្តាយភាគច្រើនយល់ថា សាលាផ្តល់ពត៌មានដល់ឪពុកម្តាយពេលដែលសិស្សមានអវិជ្ជមាននៃកំហុសជាជាងផ្តល់ពត៌មានអំពីសាលាកាលវិភាគ ឬការអនុវត្តនៅក្នុងថ្នាក់រៀនរបស់សិស្ស។ជាក់ស្តែងតាមការសិក្សាស្រាវជ្រាវមួយចំនួនបានបង្ហាញឱ្យឃើញថាការមិនចូលរួមរបស់ឪពុកម្តាយដោយសារកាបាក់បែកគ្រួសារឪពុកម្តាយប្រើអំពើហិង្សា គ្រួសារមានជីវភាពលំបាក ការមិនឱ្យតម្លៃទៅលើការសិក្សារបស់កូន ចំណេះដឹងរបស់ឪពុកម្តាយមិនគ្រប់គ្រាន់។ ឪពុកម្តាយដែលមានជីវភាពនិងចំណេះដឹងចូលរួមការអប់រំកូន ជាងឪពុកម្តាយដែលមានជីវភាពខ្វះខាតនិងចំណេះដឹងតិចតួច (Sokhea, 2013) ។ ឪពុកម្តាយខ្លះពុំមានពេលគ្រប់គ្រាន់ក្នុងការចូលរួមចំពោះការអប់រំកូនទេ ពួកគាត់ជាប់រវល់មុខរបរឬការងារ (Sophoat, 2011; Sophondarith, 2012; Sokhea, 2013)។

បច្ចុប្បន្នមាតាបិតាឬអ្នកអាណាព្យាបាលបានចូលរួម យកចិត្តទុកអនុវត្តតាមគោលនយោបាយ និងច្បាប់ក្នុងសកម្មភាពអប់រំតាមបែបណាដែរ ដើម្បីធានាបាននូវគុណភាពសិក្សារបស់កូនៗពួកគាត់។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងធំៗពីរគឺ

១.ឈ្វេងយល់ពីដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកុមារនៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ។

២.រកឱ្យឃើញនូវកត្តាដែលជះឥទ្ធិពលដល់ដំណើរការចូលរួមរបស់ឪពុកម្តាយ និងយុទ្ធសាស្រ្តក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយ ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់កូន។

## ១.៤. សំណួរស្រាវជ្រាវ

១. តើការចូលរួមរបស់ឪពុកម្តាយ ចំពោះការអប់រំកូន មានដំណើរការយ៉ាងដូចម្តេច?

២. តើមានកត្តា អ្វីខ្លះដែលជះឥទ្ធិពលដល់ការចូលរួមរបស់ពួកគាត់ចំពោះការអប់រំកូន?

៣. តើមានយុទ្ធសាស្រ្តអ្វីខ្លះក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយ ក្នុងការចូលរួមការសិក្សារបស់កូន?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ក្នុងការស្វែងយល់ពីបទពិសោធន៍ ការអនុវត្ត បញ្ហាប្រឈមនៃការចូលរួមរបស់ឪពុកម្តាយ ចំពោះការអប់រំកូន នៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ។ លទ្ធផលនៃការស្រាវជ្រាវនេះនឹងផ្តល់ពត៌មានផងដែរអំពីអត្ថប្រយោជន៍នៃការចូលរួមរបស់ឪពុកម្តាយដែលជាបទពិសោធន៍ និងជាចំនេះដឹងសម្រាប់ឪពុកម្តាយដទៃទៀត សម្រាប់លោកគ្រូ អ្នកគ្រូ និងសាលារៀន ក្នុងន័យបង្កើនការសហការរវាងឪពុកម្តាយ និងសាលារៀនឱ្យកាន់តែមានភាពប្រសើរឡើង។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះផ្តល់អត្ថប្រយោជន៍ ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំឆ្លើយតបទៅនឹងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៤និតីកាលទី៦ នៅក្នុងចតុកោណទី១គឺ ការអភិវឌ្ឍធនធានមនុស្សដើម្បីឆ្លើយតបទៅនឹងគោលដៅអប់រំជាតិ (រដ្ឋាភិបាល, យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤និតិកាលទី៦, ២០១៣) តាមរយៈការចូលរួមរបស់ឪពុកម្តាយ និងសហគមន៍។ ការសិក្សាស្រាវជ្រាវនេះអាចជាឯកសារជំនួយឬ ជាចំណេះដឹងសម្រាប់ការស្រាវជ្រាវលើកក្រោយទៀតផងដែរ។

## ១.៦. ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវធ្វើឡើងនៅសាលាបឋមសិក្សាមួយចំនួនក្នុងរាជធានីភ្នំពេញ។ ការសិក្សាស្រាវជ្រាវលើប្រធានបទ ″ការចូលរួមរបស់ឪពុកម្ដាយ ចំពោះការសិក្សារបស់កូននៅរាជធានីភ្នំពេញ″ នេះធ្វើឡើងនៅខណ្ឌចំនួន៧គឺ ខណ្ឌឫស្សីកែវ ខណ្ឌជ្រោយចង្វារ ខណ្ឌប្រាំពីរមករា ខណ្ឌចំការមន ខណ្ឌមានជ័យ ខណ្ឌព្រែកព្នៅ និងខណ្ឌសែនសុខ ដោយជ្រើសរើសសាលាបឋមសិក្សាគោលដៅចំនួន៨ មកធ្វើជាភាគសំណាកក្នុងការសិក្សាស្រាវជ្រាវ។ ការជ្រើសរើសខណ្ឌទាំង៧មកធ្វើការសិក្សាស្រាវជ្រាវនេះដោយផ្អែកទៅលើ ទីតាំងភូមិសាស្ត្រ និងរបាយប្រជាជន កម្រិតជីវភាពក្នុងការរស់នៅប្រចាំថ្ងៃ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះរួមមាន ៖

**ជំពូកទី១ ៖ សេចក្ដីផ្ដើម**

នៅក្នុងជំពូកនេះមានលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែលកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ ៖ រំលឹកទ្រឹស្ដី**

នៅជំពូកនេះផ្ដោតលើនិយមន័យ និងទ្រឹស្ដីមួយចំនួនរបស់អ្នកស្រាវជ្រាវមុនៗដែលទាក់ទងទៅនឹងប្រធានបទនៃការស្រាវជ្រាវ ដើម្បីធ្វើការគាំទ្រ និងផ្ទៀងផ្ទាត់លទ្ធផលនៃការសិក្សានេះ ដែលរួមមានដូចជាដំណើរការនៃការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំកូន កត្តាដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្ដាយ និងយុទ្ធសាស្ត្រក្នុងការជំរុញនិងលើកទឹកចិត្តឪពុកម្ដាយក្នុងការអប់រំរបស់កូន។

**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ**

ជំពូកនេះរួមមាន ការជ្រើសរើសសំណាក ឧបករណ៍ស្រាវជ្រាវ រចនាសម្ព័ន្ធនៃកម្រងសំណួរ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។

**ជំពូកទី៤ ៖ ការបកស្រាយ និងការពិភាក្សា**

ក្នុងជំពូកនេះអ្នកសិក្សាធ្វើការបកស្រាយ និងវិភាគទៅលើចំណុចធំៗ៣គឺ ១) ដំណើរការនៃការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូន ២)កត្តាដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូន ៣) យុទ្ធសាស្ត្រក្នុងការជំរុញនិងលើកទឹកចិត្តឪពុកម្ដាយឱ្យចូលរួមចំពោះការអប់រំរបស់កូន។

**ជំពូកទី៥ ៖ សន្និដ្ឋាននិងសំណូមពរ**

ក្នុងជំពូកនេះជាការសង្ខេបលម្អិតឡើងវិញ អំពីលទ្ធផលនៃការវិភាគ និងការបកស្រាយទិន្នន័យដែលបានពីការចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅទាំង៨។ ជាមួយគ្នានេះដែរ ការសន្និដ្ឋាន និងសំណូមពរទៅលើ ចំណុចខ្វះខាតមួយចំនួនដែលជាបញ្ហាប្រឈមនៃការចូលរួមរបស់ឪពុកម្ដាយសម្រាប់អ្នកសិក្សាក្រោយបំពេញបន្ថែម។

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

## ២.១. សេចក្តីផ្តើម

ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន ដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមសហការជាមួយសាលារៀន បង្កើតភាពជាដៃគូរដើម្បីអភិវឌ្ឍការទទួលខុសត្រូវទៅវិញទៅមកចំពោះភាពជោគជ័យរបស់កុមារនៅក្នុងប្រព័ន្ធអប់រំ។ ការស្រាវជ្រាវជាច្រើនបានបង្ហាញឱ្យឃើញថានៅពេលដែលសាលារៀន និងក្រុមគ្រួសារធ្វើការរួមគ្នា ដើម្បីគាំទ្រដល់ការការរៀនរបស់កុមារ កុមារមានទំនោរទៅរកភាពជោគជ័យ មិនត្រឹមតែនៅសាលារៀនប៉ុណ្ណោះទេ តែថែមទាំងទទួលបានជោគជ័យពេញមួយជីវិតរបស់ពួកគេ។ ទន្ទឹមគ្នានេះដែរ កម្មវិធីសិក្សារបស់សាលាបឋមសិក្សាមានគោលបំណងបណ្តុះបណ្តាលបុគ្គលិកលក្ខណៈល្អប្រពៃ និងលើកកម្ពស់សមត្ថភាព ផ្លូវកាយ ផ្លូវចិត្ត និងប្រាជ្ញាស្មារតីដល់សិស្សទាំងអស់។ ម្យ៉ាងទៀតនៅបឋមសិក្សាត្រូវជំរុញឱ្យរីកចម្រើននៅសេរីភាពខាងគំនិត និង អធ្យាស្រ័យ ហើយខិតខំបង្កលក្ខណៈ ឱ្យមានការអភិវឌ្ឍព្រមគ្នានូវផ្នែកទេពកោសល្យ ឥរិយាបទ តម្លៃ ការច្នៃប្រឌិត សីលធម៌ សង្គម និងសិល្ប៍សោភណ្ឌ។ ទទឹមនឹងនេះត្រូវតែជំរុញឱ្យមានការសហការយ៉ាងជិតស្និតរវាងគ្រូ និងសិស្ស ហើយ រវាងសាលារៀន គ្រួសារ និងសហគមន៍ (អយក, ២០០៦)។ នៅជំពូកទី២នេះ មានរំលឹកទ្រឹស្តី ឬការដកស្រង់លទ្ធផលនៃការសិក្សាស្រាវជ្រាវពីមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទស្រាវជ្រាវនេះ ដើម្បីជាគន្លឹះ ការគាំទ្រ និងចំណុចខ្វះខាតដើម្បីអ្នកសិក្សាស្រាវជ្រាវនេះធ្វើបន្ត។

## ២.២. និយមន័យ

ដើម្បីឲ្យការបកស្រាយប្រធានបទនេះមានលក្ខណៈជាក់លាក់អ្នកសិក្សាធ្វើការពន្យល់ពាក្យ និងកន្សោមពាក្យមួយចំនួនរួមមានពាក្យឪពុកម្តាយ ការអប់រំ ដំណើរការ។ឪពុកម្តាយមានន័យស្មើនឹងមាតាបិតាដែរ ( សម្តេចសង្ឃរាជ ជួន ណាត )។យោងតាម លោកDockter ឪពុកម្តាយមាននន័យថាជាអ្នកផ្តល់រូបរាងកាយ អារម្មណ៍ បញ្ញាស្មារតីដល់កូន។ពួកគាត់ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សា សុវត្ថិភាព និងសុខុមាលភាពកូនៗ ព្រមទាំងអប់រំ បង្ហាត់បង្រៀនកូនពីអ្វីដែលខុសនិងត្រូវ វិន័យនិងជួយកូនឲ្យសម្រេច

សក្ដានុពលពួកគេ (Dockter, 2017)។ចំណែកឯការអប់រំវិញមានន័យថា ការអប់រំគឺជាដំណើរដែលរៀបចំដោយសង្គមនៃការផ្ទេរជាបន្តបន្ទាប់នូវចំណេះដឹង និងបទពិសោធន៍ពីជំនាន់មុនដល់មនុស្សជំនាន់ក្រោយ (Naziew, 2017)។ ការអប់រំគឺជាដំណើរការនៃការរៀនសូត្រនិងផ្ដល់ចំណេះដឹង។ការអប់រំត្រូវបានធ្វើនៅគ្រប់ទីកន្លែងមិនមែនកំណត់តែនៅសាលានោះទេ (Hassan)។រីឯដំណើរការ មានន័យថា លំនាំ ទំនង (សម្ដេចសង្ឃរាជ ជួន ណាត)។ដំណើរការនៃការចូលរួមសំដៅដល់លំនាំប្រព្រឹត្តនៃសកម្មភាពក្នុងការចូលរួមរបស់ឪពុកម្ដាយ ចំពោះការសិក្សា និងការអប់រំកូនៗក្នុងជីវិតរបស់ពួក។

ដូចនេះដំណើរការនៃការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំកូនមានន័យថា ជាលំនាំដែលឪពុកម្ដាយចូលរួមក្នុងសកម្មភាពបង្ហាត់បង្រៀន អប់រំទូន្មានកូនដើម្បីឲ្យកូនទទួលបានលទ្ធផលសិក្សាល្អនិងក្លាយជាពលរដ្ឋពេញលេញនៅក្នុងសង្គម។

ការចូលរួមរបស់មាតាបិតាត្រូវបានគេជឿថា ជាយុទ្ធសាស្ត្រដ៏សំខាន់មួយនៅក្នុងការលើកកម្ពស់គុណភាពអប់រំ (Ireland, 2017)។ការចូលរួមរបស់ឪពុកម្ដាយអាចត្រូវបានផ្លាស់ប្ដូរតាមរបៀបខុសគ្នា (U.K essays, 2017) ។ការចូលរួមរបស់ឪពុកម្ដាយជាសកម្មភាពដែលកើតឡើង រវាងឪពុកម្ដាយ និងកូនៗ ឬរវាងឪពុកម្ដាយនិងសាលារៀនដែលអាចជួយដល់លទ្ធផលសិក្សា និងការអភិវឌ្ឍការអប់រំរបស់កុមារ (Abdullah, 2011)។ ការចូលរួមរបស់ឪពុកម្ដាយគឺ ជាដំណើរអន្តរកម្មប្រកបទៅដោយថាមពលដែលឪពុកម្ដាយទាញយកបទពិសោធន៍ និងធនធានជាច្រើន ដើម្បីកំណត់អន្តរកម្មរបស់ពួកគេជាមួយសាលារៀន ( (Barton, 2004)។

## ២.៣. ដំណើរការនៃការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំកូន

ដំណើរការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំរបស់កូនគឺជាលំនាំសកម្មភាពក្នុងការអប់រកូនដែលស្ដែងឡើងច្រើនទម្រង់ និងរូបភាព ស្របតាមបរិបទនៃប្រទេសនីមួយៗ។ នៅប្រទេសកម្ពុជាការចូលរួមការអប់រំកូនត្រូវបានជំរុញនិងលើកទឹកចិត្តដោយច្បាប់និងគោលនយោបាយផ្សេងៗ។ ការចូលរួមការអប់រំកូនគឺជាសិទ្ធិនិងករណីយកិច្ចរបស់ឪពុកម្ដាយដើម្បីឲ្យការសិក្សារបស់កូនទទួលបានលទ្ធផលគួរជាទីគាប់ចិត្ត

មានការអភិវឌ្ឍផ្នែកបុគ្គលិកលក្ខណៈ និងក្លាយជាពលរដ្ឋពេញលេញ។ជាក់ស្តែងឪពុកម្តាយមានសិទ្ធិនិងករណីយកិច្ចគាំទ្រការសិក្សារបស់កូន អប់រំកូន សហការជាមួយសាលាដើម្បីកែលំអបរិស្ថានសិក្សា និងលើកកម្ពស់គុណភាពអប់រំឲ្យកាន់តែប្រសើរឡើង។

ស្របជាមួយគ្នានេះដែរក៏មានការសិក្សាស្រាវជ្រាវនិងទ្រឹស្តីជាច្រើនទាក់ទងទៅនឹងទម្រង់នៃការចូលរួមរបស់ឪពុកម្តាយចំពោះការសិក្សារបស់កូន ។យោងទៅតាមគំរូរបស់លោក Epstein ការចូលរួមរបស់ឪពុកម្តាយ មាន៦ ប្រភេទគឺ ឪពុកម្តាយចូលរួមគ្រប់សកម្មភាពទាក់ទងទៅនឹងការអភិវឌ្ឍ កាយសម្បទា បញ្ញាសម្បទា សុខុមាលភាព និងសុវត្ថិភាពរបស់កុមារ ការប្រាស្រ័យទាក់ទងជាមួយនឹងសាលា ឬលោកគ្រូ អ្នកគ្រូ ការស្មគ្រចិត្តរបស់ឪពុកម្តាយ ការសម្រេចចិត្ត និងការសហការគ្នាជាមួយសហគមន៍។ ចំណែកឯលោក (Walker, 2004) បានបញ្ជាក់ថាការចូលរួមរបស់ពុកម្តាយចំពោះកិច្ចការសិក្សារបស់កូនមានច្រើនទម្រង់ ឪពុកម្តាយដែលចូលរួមលើការពង្រឹងពុទ្ធិរបស់កូនៗ ពួកគាត់ផ្តោតលើសកម្មភាពរៀនសូត្ររបស់កូនដូចជា ពង្រឹងលើការអាន សរសេរ ការគណនាលេខ ធ្វើកិច្ចការផ្ទះ ផ្តត់ផ្គង់សម្ភារៈសិក្សា ការទស្សនាកម្មវិធីទូរទស្សន៍ និងដំណើរកំសាន្ត ដូចជា ការទស្សនាមជ្ឈមណ្ឌលវប្បធម៌ផ្សេងៗ ដែលនាំឱ្យមានការរីកលូតលាស់ផ្នែកសតិបញ្ញា និងស្មារតី និងទំនាក់ទំនងល្អក្នុងការរស់នៅ។ ការចំណាយពេលវេលាជាមួយកូនពិតជាការងារដែលឪពុកម្តាយត្រូវយកចិត្តទុកដាក់ ដើម្បីជួយកុមារឱ្យមានទម្លាប់ល្អ ក្នុងការសិក្សា និងផ្តល់ភាពកក់ក្តៅដល់កូន។ ឧទហរណ៍ ក្នុងសកម្មភាពល្បែងកំសាន្ត ការអានរឿងនិទានអប់រំឱ្យកូនស្តាប់មុនពេលចូលគេង ( ចិត្តសាស្ត្រអប់រំ កុមារតូច)។ លើសពីនេះទៀត តាមការសង្កេត សិស្សមានបទពិសោធន៍នៃការរៀនប្រកបដោយឥរិយាបថវិជ្ជមាន អាស្រ័យលើការយកគំរូតាមមាតាបិតាដែលជោគជ័យក្នុងជីវិតសិក្សា ក៏ដូចជាក្នុងជីវិតការងារ។ ជាងនេះទៀត សាលាក៏ជាផ្នែកសំខាន់មួយក្នុងការផ្តល់នូវការគាំទ្រ កាលើកទឹកចិត្ត និងគុណភាពនៃការបង្រៀនប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានទំនាក់ទំនងល្អរវាងសាលារៀន និងឪពុកម្តាយផងដែរ (Swap, 1993)។

### ២.៣.១. ការចូលរួមចំពោះកិច្ចការផ្ទះរបស់កូន

ការចូលរួមជួយកូនធ្វើកិច្ចការផ្ទះគ្រូដាក់ឱ្យគឺជាផ្នែកមួយដ៏សំខាន់ដើម្បីជំរុញការសិក្សារបស់កូនឱ្យបានល្អប្រសើរ។ឪពុកម្តាយជារឿយៗចូលរួមជួយការងារសាលារបស់កូនពួកគាត់តាមរយៈការជួយកិច្ចការផ្ទះ។ ការចូលរួមជួយកូនធ្វើកិច្ចការផ្ទះ ធ្វើឱ្យឪពុកម្តាយនៅក្បែរកូន ដឹងពីអ្វីដែលពួកគេកំពុងរៀន ឪពុកម្តាយមានឱកាសផ្តល់ពត៌មានទៅសាលាវិញទាក់ទងទៅនឹងចំណុចខ្វះខាត និងការលំបាករបស់កូនក្នុងការសិក្សា និងទទួលពត៌មានត្រឡប់វិញ (Dempsey, Kathleen V. Hoover-, 2004)។ យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់លោក Echoune បង្ហាញថាប្រភេទផ្សេងៗនៃការចូលរួមរបស់ឪពុកម្តាយក្នុងការធ្វើកិច្ចការផ្ទះមាន ទំនាក់ទំនងខុសគ្នាចំពោះសមិទ្ធិផលសិក្សារបស់កូន ហើយប្រភេទនៃការចូលរួមរបស់ឪពុកម្តាយផ្លាស់ប្តូរនៅពេលដែលកូនឡើងថ្នាក់ (Echoune, 2015)។ វត្តមានរបស់ឪពុកម្តាយ គឺជាការលើកទឹកចិត្តរបស់កូនចំពោះការធ្វើកិច្ចការផ្ទះដោយផ្ទាល់ ការសរសើរដោយស្មោះត្រង់ចំពោះការងារ និងការផ្តល់យោបល់ជាក់លាក់នៅពេលដែលកុមារអនុវត្តមិនសូវល្អ។ ពួកគាត់ជាអ្នកគាំទ្រផ្នែកស្មារតី ផ្តល់ទំនុកចិត្តនិងភាពជឿជាក់ចំពោះកុមារខ្លួនឯង ដោយពួកគាត់គ្រាន់តែ ដើរតួជាអ្នកណែនាំ ឱ្យកូនអាចធ្វើកិច្ចការផ្ទះដោយដោយផ្អែកលើករណីគំរូ ពីស្ថានភាពសិក្សាថ្មី។ ផ្អែកលើការស្រាវជ្រាវរបស់លោក (Sandler, 1999) បានបង្ហាញឱ្យឃើញថា ការចូលរួមជួយធ្វើកិច្ចការផ្ទះរបស់កូន រួមមានទំនាក់ទំនងជាមួយគ្រូអំពីកិច្ចការផ្ទះរបស់កូន ការបំពេញតាមសំណូមពរសាលា ការកំណត់ពេលវេលាទៀងទាត់នៃការធ្វើកិច្ចការផ្ទះសម្រាប់កូន រៀបចំរចនាសម្ព័ន្ធពេលវេលា ទីកន្លែង និងសម្ភារៈសម្រាប់ធ្វើកិច្ចការផ្ទះ ត្រួតពិនិត្យទូទៅនៃដំណើរការនៃការធ្វើកិច្ចផ្ទះ និងពិនិត្យឡើងវិញ ផ្តល់ការគាំទ្រផ្នែកស្មារតី ដោយមានការលើកទឹកចិត្ត និងមានការរំពឹងទុកពីលទ្ធផលនៃការសិក្សារបស់កូនផងដែរ។

### ២.៣.២. ការបង្ហាត់បង្រៀន និងការពិនិត្យតាមដានការសិក្សា

ការបង្ហាត់បង្រៀន និងការពិនិត្យតាមដានការសិក្សារបស់កុមារគឺជាកាតព្វកិច្ចរបស់ឪពុកម្តាយ។

ការបង្ហាត់បង្រៀន និងការពិនិត្យតាមដានការសិក្សារបស់កូនមានសារៈសំខាន់ខ្លាំងណាស់ចំពោះការសិក្សារបស់កូនធ្វើឲ្យកូនមានការលូតលាស់ផ្នែកប្រាជ្ញា ស្មារតី ការច្នៃប្រឌិត ចង់ចេះ ចង់ដឹង និងមាន

អាកប្បកិរិយាវិជ្ជមានចំពោះការសិក្សារៀនសូត្រ។ចំណែកឯការត្រួតពិនិត្យតាមដានក៏មានសារៈសំខាន់នៅក្នុងដំណើរការនៃការបង្រៀននិងរៀនដែលធ្វើឲ្យកុមារមានទម្លាប់ល្អ មានភាពម្ចាស់ការប្រកបទៅដោយស្មារតីទទួលខុសត្រូវ មានការប្រុងប្រយ័ត្នខ្ពស់ក្នុងការសរសេរមេរៀន ធ្វើកិច្ចការផ្ទះ ធ្វើលំហាត់ជាដើម។

តាមការស្រាវជ្រាវជាច្រើនបង្ហាញឱ្យឃើញថា ការយកចិត្តទុកដាក់ បង្ហាត់បង្រៀនកូនរបស់ឪពុកម្តាយគឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្កើនបញ្ញាស្មារតី ចំណេះដឹង និងការលើកកម្ពស់លទ្ធផលសិក្សារបស់កូនឱ្យកាន់តែប្រសើរ ធ្វើឱ្យកូន កាន់តែខិតខំប្រឹងប្រែងរៀនសូត្រ ចង់ចេះចង់ដឹងជាងមុន ជាពិសេសធ្វើឱ្យមានភាពស្វាហាប់ក្នុងការទទួលបានចំណេះដឹងថ្មី និងមានមោទនភាពក្នុងកការសិក្សា។ លទ្ធផលនៃការសិក្សាស្រាវជ្រាវជាច្រើនបង្ហាញថាឪពុកម្តាយភាគច្រើនបានចូលរួមបង្ហាត់បង្រៀនកូននៅកម្រិតបឋមសិក្សាផ្តោតតែទៅលើមុខវិជ្ជាគោល និងជាមុខវិជ្ជាមូលដ្ឋានគ្រឹះ នៃមុខវិជ្ជាដទៃទៀត ដូចជាភាសារ និងគំណិតវិទ្យា។ យោងតាម (Ball &Blachman, 1991) បានបង្ហាញថា ឪពុកម្តាយដែលបង្រៀនពាក្យ ឬបញ្ញត្តិក្នុងអត្ថបទអំណាន នាំឱ្យកូនចូលចិត្តអាន និងចង់ធ្វើកិច្ចការផ្ទះ ដែលគ្រូដាក់ឱ្យយ៉ាងសប្បាយ និងធ្វើឱ្យកុមារបំពេញការសិក្សារៀនសូត្របានល្អនៅសាលារៀន ជាងកុមារមិនព្រមមិនទទួលបានការបង្រៀនពីឪពុកម្តាយ។ ចំណែកឯ (Dampsey, 2001)បានបង្ហាញថាសកម្មភាពចូលរួមរបស់ឪពុកម្តាយ បានជះឥទ្ធិពលដល់លទ្ធផលនៃការសិក្សារបស់សិស្សតាមរយៈការបង្រៀនរបស់ពួកគាត់។ ជាងនេះទៀត ការពិនិត្យតាមដានទៅលើការសិក្សាគឺជាជំហានសំខាន់មួយនៅក្នុងដំណើរការរៀន និងការបង្រៀន។ ការពិនិត្យមើលកំហុស និងការយល់ច្រឡំរបស់សិស្ស រួចធ្វើការផ្តល់មតិយោបល់ត្រឡប់បន្ទាប់មករៀបចំផែនការបង្រៀន ដោយផ្អែកលើកំហុសឆ្គង និងចំណុចខ្វះខាតទាំងនោះ (Douglas Fisher and Nancy Frey, 2014)។ការសិក្សាជាច្រើនក៏បានផ្តោតការយកចិត្តទុកដាក់លើការត្រួតពិនិត្យតាមដានការសិក្សាផងដែរ ។ជាក់ស្តែងផ្អែកតាមការសិក្សាលោក(J.C .Nuner, 2014)បានបង្ហាញពីការពង្រីកការសិក្សាមុនៗ អំពីកត្តាជះឥទ្ធិពលដល់ សមិទ្ធិផលសិក្សារបស់សិស្សដែល យកចិត្តទុកដាក់ផ្តោតលើវិមាត្រពីរគឺទី១ការចូលរួមការត្រួតពិនិត្យតាមដាននិងការគាំទ្ររបស់ឪពុកម្តាយចំពោះការសិក្សារបស់

កូន ទី២គឺឥរិយាបថរបស់សិស្សក្នុងការចំណាយពេលវេលានិងការគ្រប់គ្រងពេលវេលា និងការផ្តោតអារម្មណ៍ទៅលើការសិក្សា។ការត្រួតពិនិត្យ និងការតាមដានការសិក្សារបស់កូនមានប្រយោជន៍សម្រាប់កូន ឪពុកម្តាយអាចដឹងពីកំហុស និងចំណុចខ្វះខាតរបស់កូន រួចធ្វើការបំពេញបន្ថែមនៅចំណុចទាំងនេះ។

### ២.៣.៣. ការជំរុញ និងការលើកទឹកចិត្ត

ការជំរុញនិងលើកទឹកចិត្តរបស់ឪពុកម្តាយ ឬលោកគ្រូអ្នកគ្រូពិតជាមានឥទ្ធិពលដល់ការសិក្សារបស់កូនឱ្យកាន់តែប្រសើរឡើង។ យោងតាមទ្រឹស្តីនៃការអប់រំកុមាររបស់លោក Rechard ការលើកទឹកចិត្តគឺជាការជំរុញនរណាម្នាក់ឱ្យចង់ធ្វើអ្វីមួយ។ ការលើកទឹកចិត្តចែកជាពីរ គឺការលើកទឹកចិត្តខាងក្រៅ និងការលើកទឹកចិត្តខាងក្នុង (Richard M. Ray&Edward , 2000)។ការលើកទឹកចិត្តត្រូវបានគេចាត់ទុកថាជាហេតុផលសំខាន់បំផុតមួយដែលជំរុញ ឱ្យមនុស្សម្នាក់ឈានមុខក្នុងជីវិត (wikipedia) ។ កុមារត្រូវការជាចាំបាច់នូវការជំរុញ និងលើកទឹកចិត្តពីមនុស្សធំដែលនៅជុំវិញខ្លួនពួកគេ ជាពិសេសគឺឪពុកម្តាយ (Bando, 2013)។ គ្រូនិងឪពុកម្តាយ ទទួលខុសត្រូវក្នុងការគាំទ្រ ផ្តល់ការលើកទឹកចិត្តដល់កុមារ នៅពេលដែលពួកគេបំពេញកិច្ចការសាលា។សកម្មភាពចូលរួមរបស់ឪពុកម្តាយជះឥទ្ធិពលដល់សមិទ្ធិផលសិក្សារបស់សិស្សតាមរយៈការបង្កើតគំរូ ការជំរុញលើកទឹកចិត្ត និងការណែនាំបង្ហាត់បង្រៀន (Dampsey, 2001)។ ការជំរុញនិងផ្តល់រង្វាន់ចំពោះការខិតខំប្រឹងប្រែងធ្វើការផ្ទះ ទទួលស្គាល់និងផ្តល់ការគាំទ្រផ្នែកស្មារតី ដល់ការអនុវត្ត សមត្ថភាពការខិតខំប្រឹងប្រែងរបស់កូន ។ សិស្សម្នាក់ៗមានតម្រូវការផ្ទាល់ខ្លួនខុសៗគ្នានៅពេលឪពុកម្តាយផ្តល់នូវតម្រូវការនិងការលើកទឹកចិត្តសមស្រប ពួកគេនឹងទទួលបានអត្ថប្រយោជន៍ដ៏ច្រើន (Hong and Lee, 2012)។ ឧទាហរណ៍ សិស្សងាយនឹងធុញថប់ ឬរឹងទទឹងនឹងការសិក្សាត្រូវបានទទួលប្រយោជន៍ពីការត្រួតពិនិត្យ និងតាមដានពីឪពុកម្តាយ ដូចសិស្សដែលចូលចិត្តរៀនសូត្រដែរ។ ចំណែកឯ (Ball &Blachman, 1991) បានបង្ហាញថាការចូលរួមរបស់ឪពុកម្តាយអាចលើកទឹកចិត្តដល់កូនៗ នូវសមិទ្ធិផលជាច្រើនតាមមធ្យោបាយផ្សេងៗ។ការជំរុញនិងការលើកទឹកចិត្តរបស់ឪពុកម្តាយចំពោះការសិក្សារបស់កូនមានសារៈសំខាន់ណាស់មិនថាការលើកទឹកចិត្តផ្នែកសម្ភារៈឬក៏

ស្មារតីទេ។ ក្នុងការលើកទឹកចិត្តកូនឪពុកម្ដាយត្រូវប្រើវិធីសាស្ត្រដូចជា ឪពុកម្ដាយពិភាក្សាជាញឹកញាប់អំពីសារៈសំខាន់នៃការអប់រំដល់កូន នាំកូនធ្វើលំហាត់ឬកិច្ចការផ្ទះ ការនាំកូនអានសៀវភៅ និទានរឿងឲ្យពួកគេស្ដាប់ និង នាំពួកគាត់ដើរសម្បាន្តជាដើម ។ឪពុកម្ដាយលើកទឹកចិត្តកូនតាម រយៈការសរសើរនូវអ្វីដែលគេធ្វើបានល្អប្រសើរ ធ្វើជាគំរូល្អដល់កូន ផ្ដល់អាហារ ដែលមានតុល្យភាព និងថែទាំសុខភាពកុមារឱ្យបានល្អ ផ្ដល់រង្វាន់ដល់ពួកគេ ផ្ដល់ឱកាសឲ្យពួកគាត់មានភាពម្ចាស់ការ ផ្ដល់ក្ដីស្រលាញ់ដល់ពួកគាត់ជាដើម (Safdar Rehman Ghazi, 2010)

## ២.៣.៤. ភាពជាដៃគូរវាងសាលារៀន និងគ្រួសារ

ភាពជាដៃគូរវាងគ្រួសារនិងសាលារៀនគឺជាផ្នែកមួយសំខាន់ក្នុងការផ្លាស់ប្ដូរព័ត៌មានរវាងឪពុកម្ដាយនិងសាលារៀន គ្រូ ទាក់ទងទៅនឹងការសិក្សារបស់កុមារ ហើយក៏ជាផ្នែកមួយនៃការត្រួតពិនិត្យតាមដានលទ្ធផលសិក្សា និងឥរិយាបថរបស់កុមារផងដែរដែលនាំឲ្យឪពុកម្ដាយ គ្រូជួយកុមារទាន់ពេលវេលា។យោងតាមការសិក្សាស្រាវជ្រាវជាច្រើន បានបង្ហាញថាឲ្យឃើញថា ភាពជាដៃគូរវាងគ្រួសារ និងសាលារៀនបានផ្ដល់មកនូវអត្ថប្រយោជន៍ជាច្រើនសម្រាប់សិស្ស និងគាំទ្រប្រពន្ធ័អប់រំទាំងមូល ដែលក្នុងនោះរួមមានធ្វើឱ្យប្រសើរឡើងនូវឥរិយាបថរបស់សិស្ស បង្កើនសកម្មភាពក្នុងថ្នាក់ កាត់បន្ថយអត្រាបោះបង់ការសិក្សា កាត់បន្ថយអត្រាត្រួតថ្នាក់ និងធ្វើឱ្យសិស្សមានការគោរពខ្លួនឯងខ្ពស់។ ឪពុកម្ដាយពេញចិត្តនឹងការទំនាក់ទំនងជាមួយសាលារៀនកាន់តែខ្លាំង កូនរបស់ពួកគាត់ ទទួលបានភាពជោគជ័យរឹតតែខ្លាំង (Sylvie Normandeau and Isabell Nadon, 2020)។ ទំនាក់ទំនងរវាងឪពុកម្ដាយ និងគ្រូ គឺអាស្រ័យទៅលើឥរិយាបថរបស់គ្រូផងដែរ។ឥរិយាបថរបស់គ្រូគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអនុវត្តសកម្មភាពអប់រំប្រកបដោយជោគជ័យ (Shai, 2016)។គ្រូបង្រៀនគឺជាកត្តាកំណត់ខ្ពស់បំផុតទី២ ក្នុងការអភិវឌ្ឍបុគ្គលិកលក្ខណៈបន្ទាប់ពីឪពុកម្ដាយ។ គ្រូជាគម្រូរបស់សិស្ស គ្រូក៏ជាអ្នកផ្ដល់ព័ត៌មាន ហើយគ្រូជាអ្នកចំណាយពេលច្រើនជាងគេបន្ទាប់ពីឪពុកម្ដាយ ទាំងនេះជាមូលហេតុដែលឥរិយាបថ និងអាកប្បកិរិយារបស់គ្រូមានឥទ្ធិពលទៅលើការអភិវឌ្ឍរបស់សិស្សថាពួកគាត់ទទួលបានជោគជ័យឬអត់។តាមរយៈការសិក្សាស្រាវជ្រាវ

របស់លោក Mucella បានបង្ហាញថាអាកប្បកិរិយា និងឥរិយាបថវិជ្ជមានរបស់គ្រូ ជាកត្តាជះឥទ្ធិពលវិជ្ជមានទៅលើការអភិវឌ្ឍចរិតលក្ខណៈ និងភាពជោគជ័យរបស់សិស្ស ផ្ទុយទៅវិញអាកប្បកិរិយាអវិជ្ជមានរបស់គ្រូមានឥទ្ធិពល អវិជ្ជមានទៅលើការអភិវឌ្ឍ ចរិតលក្ខណៈ និងភាពជោគជ័យរបស់កុមារផងដែរ (Mucella, 2011)។គ្រូ និងឪពុកម្តាយផ្តល់នូវប្រព័ន្ធគាំទ្រដ៏សំខាន់មួយ ដើម្បីជួយឱ្យសិស្សមានការរីកចម្រើន ព្រោះឪពុកម្តាយនិងគ្រូមានតួនាទីសំខាន់នៅពេលដែលពួកគាត់ធ្វើការទំនាក់ទំនង និងធ្វើការសហការគ្នាបានល្អ ផ្តល់នូវប្រសិទ្ធភាពការអប់រំ និងភាពជោគជ័យដល់សិស្សក្នុងរយៈពេលវែង។ ដំណើរការរបស់សាលា និងសមិទ្ធផលរបស់សិស្សនឹងថយប្រសិទ្ធភាព បើគ្មានការជួយពីឪពុកម្តាយ (Menon, 2013)។ ក្នុងការទំនាក់ទំនងជាមួយមាតាបិតាសិស្ស គ្រូបង្រៀន មានតួនាទីផ្តល់ជាគំនិត និងព័ត៌មានត្រឡប់ទៅឪពុកម្តាយទៅលើការសម្រេចចិត្ត ទាក់ទងទៅនឹងរបៀបនៃការជួយធ្វើកិច្ចការផ្ទះ ឥរិយាបថសិស្ស កម្មវិធីសិក្សា ព្រឹត្តការណ៍នៅសាលា និងលទ្ធផលនៃការសិក្សារបស់សិស្ស។ ទំនាក់ទំនងវិជ្ជមានរបស់គ្រូ និងឪពុកម្តាយបានលើកម្ពស់លទ្ធផលនៃការសិក្សារបស់សិស្ស សមត្ថភាពសង្គម និងសុខុមាលភាពផ្លូវចិត្តសិស្សផងដែរ។ នៅពេលដែលឪពុកម្តាយ និងគ្រូជាដៃគូនឹងគ្នា សិស្សបំពេញការសិក្សារៀនសូត្រកាន់តែល្អប្រសើរ និងមានអាកប្បកិរិយាល្អ មិនថានៅសាលារៀនឬនៅផ្ទះឡើយ។

### ២.៣.៥. ចំណេះដឹងរបស់ឪពុកម្តាយ

ចំណេះដឹងរបស់ឪពុកម្តាយដើរតួយ៉ាងសំខាន់ក្នុងការពង្រឹងការចូលរួមចំពោះការអប់រំកូនឲ្យកាន់តែមានប្រសិទ្ធភាព និងប្រកបទៅដោយសក្តានុពល។ឪពុកម្តាយដែលមានចំណេះដឹងអាចជួយកូនបានទៅតាមតម្រូវការនៅគ្រប់ដំណាក់កាលនៃការអភិវឌ្ឍរបស់កូន។ផ្ទុយទៅវិញចំពោះឪពុកម្តាយដែលមានចំណេះដឹងតិចតួចមានការពិបាកនិងរារែកចំពោះការចូលរួមការអប់រំរបស់កូន។ម្យ៉ាងទៀតកម្រិតចំណេះដឹងរបស់ឪពុកម្តាយមានទំនាក់ទំនងទៅនឹងប្រាក់ចំណូលគ្រួសារផងដែរ។ភាគច្រើននៃឪពុកម្តាយដែលមានចំណេះដឹងខ្ពស់មានប្រាក់ចំណូលខ្ពស់។ជាក់ស្តែងផ្អែកតាមការសិក្សាស្រាវជ្រាវជាច្រើនបង្ហាញឱ្យឃើញថាសិស្សដែលមានឪពុកម្តាយមានការអប់រំខ្ពស់ និងមានទ្រព្យសម្បត្តិធ្វើឱ្យប្រសើរឡើងក្នុងអាជីព

របស់ពួកគេនាពេលអនាគត (Jaiswal, 2018)។ ចំណេះដឹងរបស់ឪពុកម្តាយត្រូវបានគេគិតថា ផ្តល់នូវចំណេះដឹងសាកលសម្រាប់សម្របខ្លួនទៅ និងការផ្លាស់ប្តូរការអភិវឌ្ឍរបស់កូន ( Mathew R. Sander et Alina Moraws, 2014)។ ឪពុកម្តាយជួយកូន របស់ពួកគាត់ក្នុងការបំពេញកិច្ចការផ្ទះផ្អែកលើស្វ័យភាព និងសមត្ថភាពតាមការគាំទ្រពីឪពុកម្តាយ (Dettmers, 2019)។ ចំណែកឯលោកលោក (Dbow, 2019) លទ្ធផលនៃការសិក្សារបស់គាត់បានបង្ហាញថា ផលប្រយោជន៍នៃកម្រិតនៃការអប់រំរបស់ឪពុកម្តាយមិនមែនជះឥទ្ធិពលលើសមិទ្ធិផលការសិក្សារបស់កូនរយៈពេលខ្លីនោះទេ ប៉ុន្តែវាមានផលប៉ះពាល់យូរអង្វែងចំពោះលទ្ធផលវិជ្ជមាននៅពេលដែលពួកគេចូលដល់វ័យកណ្តាល។ឪពុកម្តាយដែលមានការអប់រំមានទំនោរក្នុងការចូលរួមអប់រំរបស់កូនៗជាងឪពុកម្តាយដែលមានការអប់រំទាប (Jaiswal, 2018)។ ចំណេះដឹងរបស់ឪពុកម្តាយនិងធនធានសេដ្ឋកិច្ចមានទំនាក់ទំនងគ្នា រវាងកម្រិតអប់រំរបស់ឪពុកម្តាយ និងកម្រិតចំណូលរបស់គ្រួសារផងដែរ។ យោងតាមមជ្ឈមណ្ឌលជាតិសម្រាប់កុមារក្រីក្រ ឪពុកម្តាយដែលមានការអប់រំទាប គ្រួសារនិងមានប្រាក់ចំណូលទាប។ ហើយការសិក្សាផ្សេងទៀតបង្ហាញឱ្យឃើញថា ស្ថានភាពសេដ្ឋកិច្ចសង្គមទាបអាចប៉ះពាល់អន្តរគ្រួសារ និងនាំយកបញ្ហាអាកប្បកិរិយា ដែលអាចជះឥទ្ធិពលដល់ការសិក្សានិងការអភិវឌ្ឍរបស់កុមារ (UNIVERSITY LAMAR, 2019)។ សាវតាគ្រួសារជះឥទ្ធិពលដល់ការសិក្សារបស់កុមារ គឺទីមួយ គ្រួសារប្រើប្រាស់ធនធានដើម្បីគាំទ្រដល់ការអប់រំកូនប្រកបដោយសក្តានុពលដែលជះឥទ្ធិពលដល់សមិទ្ធិផលការសិក្សារបស់កុមារ។ ទីពីរ ឪពុកម្តាយបណ្តុះចំណាប់អារម្មណ៍របស់កូនឲ្យស្រលាញ់ការសិក្សារៀនសូត្រ និងផ្តល់អាកប្បកិរិយាគំរូដល់កូនៗពួកគាត់យ៉ាងមានប្រសិទ្ធភាព ហើយទាំងនេះជះឥទ្ធិពលដល់សមិទ្ធិផលនៃការសិក្សារបស់កូនពេញមួយជីវិត ( Li and i Qiu, 2018)

## ២.៤. កត្តាដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយ

ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំរបស់កូនគឺជាតួនាទីនិងករណីយកិច្ចរបស់ឪពុកម្តាយដើម្បីឲ្យកាសិក្សារបស់កូនទទួលបានភាពជោគជ័យពិតប្រាកដ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយឪពុកម្តាយសិស្សមួយចំនួនមិនបានយកចិត្តទុកដាក់ទៅលើបញ្ហានេះទេ ហើយក៏មានឪពុកម្តាយខ្លះមិនបានចូលរួមដោយសារកត្តាជាច្រើនដូចជា កត្តាពេលវេលា កត្តាជីវភាព កត្តាចំណេះដឹងជាដើម។ការខ្វះទំនាក់ទំនង

រវាងឪពុកម្តាយ និងសាលារៀន គ្រូបង្រៀន គឺជាកត្តាជះឥទ្ធិពលជាអវិជ្ជមានដល់កិច្ចសហការ និងឈាន ដល់ការលើកកម្ពស់គុណភាពអប់រំ។ ជាមួយគ្នានេះដែរ យោងតាម លោក Pomerant និង Hornby បង្ហាញ ថា លទ្ធផលល្អប្រសើរ នៃការសិក្សារបស់សិស្សផ្អែកលើការលើកកម្ពស់ទំនាក់ទំនងរវាងឪពុកម្តាយ និងគ្រូ បង្រៀន ការចូលរួមផ្តល់ទំនុកចិត្តរបស់ឪពុកម្តាយចំពោះសាលា និងការចាប់អារម្មណ៍លើការអភិវឌ្ឍសមត្ថ ភាពរបស់ឪពុកម្តាយ។ (Pomerantz, 2007)។ ទោះជាយ៉ាងណាក៏ដោយ កម្រិតនៃការចូលរួមនិងការយក ចិត្តទុកដាក់របស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលចំពោះការសិក្សារបស់កូនមិនដូចគ្នាទេ។ តាមការសង្កេត ក្នុងជីវភាពរស់នៅ ឪពុកម្តាយទាំងអស់សុទ្ធតែចង់ឱ្យកូនទទួលបានលទ្ធផលនៃការសិក្សាល្អ តែមិនបានចាប់ អារម្មណ៍ក្នុងការរួមចំណែកលើការទទួលខុសត្រូវ ដោយផ្តេកផ្តួលឬដាក់បន្ទុកលើសាលារៀន ឬគ្រូតែម្ខាង។ ដូចនេះ ទាមទារឱ្យមានការពិនិត្យឡើងវិញ ស្វែងរកការបញ្ជាក់ពីឧបសគ្គមួយចំនួនចំពោះការចូលរួមរបស់ ឪពុកម្តាយក្នុងការអប់រំកូនៗរបស់ពួកគាត់។យោងតាមការសិក្សាស្រាវជ្រាវរបស់ (Statistic,U.K Department of Education National Center for Education, 2015) បានបង្ហាញថា ឧបសគ្គនៃការចូល រួមរបស់ឪពុកម្តាយមានដូចជា ពួកគាត់មិនមានពេលគ្រប់គ្រាន់ ឬខ្វះចំណេះដឹងក្នុងការជួយបង្ហាត់បង្រៀន កូន ក៏ដូចជាជួយកូនក្នុងការធ្វើកិច្ចការផ្ទះ ចំណែកមាតាបិតាមួយចំនួន មិនមានឥរិយាបថក្នុងការចូលរួម ចំណែកដល់ការសិក្សារបស់កូន ហើយពេលខ្លះសាលាផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ ធ្វើឲ្យឪពុកម្តាយគ្មាន ឱកាស ក្នុងការចូលរួមចូលរួមចំពោះការសិក្សារបស់កូន។

### ២.៤.១. កត្តាចំណេះដឹងរបស់ឪពុកម្តាយ

ចំណេះដឹងរបស់ឪពុកម្តាយគឺជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមអប់រំកូនគ្រប់ទម្រង់។ភាពខ្វះ ចំណេះដឹងរបស់ឪពុកម្តាយគឺជាឧបសគ្គមួយដ៏ធំដែលរារាំងដល់ការជួយកូនក្នុងការសិក្សា។ តាមរយៈការ សិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញឱ្យឃើញថាឪពុកម្តាយខ្លះខ្វះចំណេះដឹងមូលដ្ឋាន ឯឪពុកម្តាយខ្លះ ទៀតមិនយល់ពីកម្មវិធីសិក្សាថ្មី ឬក៏ភ្លេចអស់នូវអ្វីដែលពួកគាត់បានរៀនកន្លងមក។ យោងតាមការសិក្សា របស់ (Yamato , Holloway & Suzuki , 2016) បានរកឃើញថាឪពុកម្តាយភាគច្រើន មានអារម្មណ៍

អៀនខ្មាស់ចំពោះការមានចំណេះដឹង និងជំនាញមិនគ្រប់គ្រាន់ពាក់ពន្ធ័ទៅនឹងការចូលរួមរបស់ពួកគេនៅក្នុងអភិបាលកិច្ចសាលារៀន។ ឪពុកម្តាយមួយចំនួនទៀតមានការភ្ញាក់ផ្អើល អំពីចំណេះដឹង និងសាវតារបស់ពួកគេ ដែលអាចបង្កើនប្រសិទ្ធភាពនៃការចូលរួមរបស់ខ្លួនក្នុងការចូលរួមការអប់រំកូន។ នៅក្នុងការស្ទង់មតិរបស់ (Chiu, 2018) ឪពុកម្តាយជាច្រើន បានអះអាងថា ពួកគេមានចំណេះដឹងមិនគ្រប់គ្រាន់ ដើម្បីធ្វើការចូលរួមចំពោះសកម្មភាពសាលារៀនឡើយ។

## ២.៤.២. កត្តាទំនាក់ទំនងរវាងគ្រួសារ និងសាលារៀន

បំណិនទំនាក់ទំនងត្រូវបានគេទទួលស្គាល់ថាជាជំនាញសំខាន់មួយក្នុងចំណោមជំនាញផ្សេងៗទៀត ដែលពិភពលោកឱ្យឈ្មោះថា បំណិនសតវត្សទី២១ និងតម្រូវឱ្យការអប់រំយកចិត្តទុកដាក់ក្នុងយុគសម័យ ឌីជីថលនេះ។ ទំនាក់ទំនងរវាងឪពុកម្តាយ និងគ្រូគឺជាការចែករំលែកព័ត៌មានសិក្សា ការផ្តល់ភាពជឿជាក់ ផ្សារភ្ជាប់សាមគ្គី គ្នាយ៉ាងជិតស្និទ និងបង្ហាញពីការសហការយ៉ាងសំខាន់ ក្នុងការជួយឱ្យកុមារទទួលបានផលល្អក្នុងការសិក្សា។ ផ្ទុយទៅវិញ កង្វះទំនាក់ទំនងរបស់ពួកគេអាចជារបាំង ដ៏រឹងមាំដែលរារាំងដល់ការផ្តល់និងទទួលព័ត៌មានពីការលូតលាស់ការសិក្សារបស់កុមារ។ ផ្អែកតាមការសិក្សារបស់លោក (Horny and Lafade, 2018) បានរកឃើញថា គ្រូមិនមានពេលគ្រប់គ្រាន់ដើម្បីផ្តោតលើទំនាក់ទំនងជាមួយឪពុកម្តាយទេ។ គ្រូមិនត្រូវបាន បណ្តុះបណ្តាលដើម្បីដោះស្រាយបញ្ហាជាមួយឪពុកម្តាយ និងការកសាងទំនុកចិត្តសម្រាប់ឪពុកម្តាយដែរ ជាពិសេសគ្រូពិបាកនឹងយល់ច្បាស់អំពីស្ថានគ្រួសាររបស់សិស្សដែលមិនមែនជារបស់គាត់។ ចំណែកការសិក្សារបស់ (Chiu, 2018) បានបង្ហាញថា តាមរយៈការសង្កេតលើឥរិយាបថរបស់គ្រូ និងសាលារៀន មិនសូវមានភាពអំណោយផលដល់ឪពុកម្តាយជាច្រើន ក្នុងការការបង្កើតទំនាក់ទំនងសង្គមសម្រាប់ការចូលរួមរបស់ឪពុកម្តាយក្នុងអភិបាលកិច្ចសាលា។លទ្ធផលនៃការសិក្សានេះដដែលបានបង្ហាញថាឪពុកម្តាយទូទៅត្អូញត្អែរថាការប្រាស្រ័យទាក់ទងរបស់ពួកគាត់ជាមួយសាលាគឺមិនមានភាពអនុគ្រោះ។គ្រូមិនមានពេលគ្រប់គ្រាន់ក្នុងការទាក់ទងជាមួយឪពុកម្តាយសិស្ស ចំណែកឪពុកម្តាយវិញកម្រនឹងទៅសាលាដើម្បីពិភាក្សាលើបញ្ហាការសិក្សារបស់កូនៗពួកគេនៅសាលារៀន ដោយសារកង្វះពេល

វេលា និងអក្ខរកម្មជាដើម (Drajea, 2014)។នៅក្នុងលទ្ធផលនៃការស្ទង់មតិ ៥៨%នៃឪពុកម្ដាយមិនបានទាក់ទងទៀងទាត់ជាមួយគ្រូ សាលារៀនដើម្បីតាមដានការសិក្សារបស់កូនៗទេ។តាមរយៈការស្ទង់មតិនេះបានបញ្ជាក់ពីមូលហេតុនៃការកង្វះទំនាក់ទំនងនេះគឺដោយសារ ឪពុកម្ដាយភាគច្រើនធ្វើការពេញម៉ោង មិនមានពេលវេលាគ្រប់គ្រាន់ ឬរវល់ជាមួយនឹងការងាររអាជីវកម្ម (Menon, 2013)។

## ២.៤.៣. កត្តាជីវភាពគ្រួសារ

បញ្ហាជីវភាពគ្រួសារ គឺជាកត្តាចម្បងដ៏សំខាន់ដែលឪពុកម្ដាយគ្រប់រូបយកចិត្តទុកដាក់បំផុតលើបញ្ហានេះ។គ្រួសារដែលមានជីវភាពលំបាកជាឧបសគ្គរារាំងដល់ការចូលរួមចំពោះការអប់រំរបស់កូន និងជះឥទ្ធិពលអវិជ្ជមានលើលទ្ធផលនៃការសិក្សារបស់កូន។មាតាបិតាគ្រប់រូបមិនមែនសុទ្ធតែមានលទ្ធភាពគ្រប់គ្រាន់ និងធនធានដើម្បីដឹកនាំកូនៗរបស់ពួកគេឆ្ពោះទៅរកការសម្រេចចិត្តប្រកបដោយភាពឆ្លាតវៃក្នុងការអប់រំនោះទេ (Ismic, 2020) ។ ការផ្គត់ផ្គង់មិនគ្រប់គ្រាន់សម្រាប់តម្រូវការសាលារៀនរបស់កុមារ ដោយសារតែប្រាក់ចំណូលទាប និងភាពក្រីក្រ ការរាប់រងបន្ទុកជីវភាពក្នុងក្រុមគ្រួសារទាំងមូល ជំនួសឱ្យការផ្ដោតលើបញ្ហាសិក្សារបស់កូនរបស់ពួកគាត់ (Drajea, 2014)។ យោងតាមការស្រាវជ្រាវលោក (Tao Lin and Han LV, 2017) បានបង្ហាញថាស្ថានភាពសេដ្ឋកិច្ចគ្រួសារមានឥទ្ធិពលលើការអប់រំកុមារ។ គ្រួសារដែលមានប្រាក់ចំណូលទាបមិនអាចជួយជំរុញកូនឱ្យទទួលបានការអប់រំនៅសាលាល្អៗ ឬបន្តការសិក្សានៅឧត្តមសិក្សាឡើយ។ ផ្ទុយទៅវិញ ប្រសិនបើប្រាក់ចំណូលមានការកើនឡើង ពោលគឺហិរញ្ញវត្ថុល្អ ពួកគាត់អាចផ្ដល់ការអប់រំជាពិសេសដល់កូន។ ស្របគ្នានេះដែរលោក ( Gordon Gahl and Lance Lochner, 2012) បានបញ្ជាក់ឱ្យឃើញថា ប្រាក់ចំណូលបច្ចុប្បន្នមានឥទ្ធិពល គួរឱ្យកត់សម្គាល់លើពិន្ទុគណិតវិទ្យា និងអំណានរបស់កុមារ។ ការប៉ាន់ស្មានជាមូលដ្ឋាន បង្ហាញការកើនឡើងនៃប្រាក់ចំណូល អាចបង្កើនពិន្ទុគណិតវិទ្យា និងការអានបាន៦ភាគរយនៃគម្លាតគម្រូ។ ដូចនេះប្រាក់ចំណូលមានការប៉ះពាល់ដ៏ធំធេងដល់លទ្ធផលនៃការសិក្សារបស់កុមារ។

## ២.៤.៤. ការផ្តល់ព័ត៌មានដល់ឪពុកម្តាយ

ការផ្តល់ព័ត៌មានរបស់សាលាទាក់ទងទៅនឹងការសិក្សារបស់កុមារមានភាពចាំបាច់ណាស់ក្នុងការជួយលើកកម្ពស់លទ្ធផលនៃការសិក្សារបស់កុមារ និងអាចជួយកុមារបានទាន់ពេលវេលាតាមដែលអាចធ្វើទៅបាន ។ កិច្ចការនេះពឹងផ្អែកទៅលើសាលាទាំងស្រុងក្នុងការទំនាក់ទំនងនិងផ្តល់ព័ត៌មានទៅឪពុកម្តាយសិស្សឲ្យបានទៀងទាត់ និងជាប្រចាំ។ឪពុកម្តាយភាគច្រើនបានរាយការណ៍ថា ពួកគាត់មិនបានទទួលព័ត៌មានគ្រប់គ្រាន់ទាក់ទងទៅនឹងការសិក្សារបស់កូន ។ ភាពមិនគ្រប់គ្រាន់ ឬអវត្តមាននៃបណ្តាញទំនាក់ទំនងរបស់បុគ្គលិកសាលារៀននាំឲ្យរាំងស្ទះដល់ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការចូលរួមអប់រំកូន និងចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលា។ ឪពុកម្តាយត្រូវការព័ត៌មានគ្រប់គ្រាន់ដើម្បីធ្វើការចូលរួមចំពោះការអប់រំកូន (Chiu, 2018)។ផ្ទុយទៅវិញសាលាមានកង្វះខាតមួយចំនួនដូចជា គ្រូមិនមានពេលគ្រប់គ្រាន់ដើម្បីផ្តោតទៅលើឪពុកម្តាយ ឬគ្រូមិនមានការបណ្តុះបណ្តាលផ្នែកទំនាក់ទំនងជាមួយឪពុកម្តាយ (Horny and Lafade, 2018)។

## ២.៥.យុទ្ធសាស្ត្រក្នុងការជំរុញ និងការលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមការសិក្សារបស់កូន

ការលើកទឹកចិត្ត គឺជាកម្លាំងចលករដ៏សំខាន់ ដែលអាចជួយបង្កើនប្រសិទ្ធភាពរបស់មនុស្សនៅពេលពួកគេធ្វើការឆ្ពោះទៅរកគោលដៅណាមួយ។ យោងតាមការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញឱ្យឃើញថាមានយុទ្ធសាស្ត្រជាច្រើនដែលសាលារៀនអាចប្រើដើម្បីធ្វើការជំរុញ និងលើកទឹកចិត្តឪពុកម្តាយ ក្នុងការចូលរួមការអប់រំរបស់កូនៗពួកគាត់។ ការលើកទឹកចិត្តនេះធ្វើឡើងតាមរយៈការចុះទៅដល់សហគមន៍ ការផ្សព្វផ្សាយតាមបណ្តាញសង្គមផ្សេងៗ។ ចំណែកឯ (Grace Hui Chen Huang, Kimberly, 2015) បានបង្ហាញថាឪពុកម្តាយត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងការសិក្សារបស់កូនដោយផ្អែកលើតម្រូវការក្នុងការកសាងទំនាក់ទំនងជាមួយអ្នកដទៃជាពិសេសគឺគ្រូដើម្បីបង្កើនឥទ្ធិពលលើការរៀនសូត្ររបស់កូនៗ និងដើម្បីធានាបាននូវភាពជោគជ័យរបស់កុមារ។ការសិក្សានេះបានបង្ហាញផងដែរពីការបង្កើនចំណេះដឹង

និងសមត្ថភាពជំនាញរបស់ឪពុកម្តាយដែលមានឥទ្ធិពលលើការអប់រំកូន។ ម្យ៉ាងទៀតផ្អែកតាមការសិក្សារបស់ (Reed, 2020) បានបង្ហាញថា ឪពុកម្តាយផ្ទាល់មានជំនឿ និងយល់ច្បាស់ពីតួនាទីរបស់ពួកក្នុងការចូលរួមចំពោះការអប់រំរបស់កូនព្រោះ វាជាការទទួលខុសត្រូវរបស់ពួកគាត់។ ពួកគាត់មានជំនឿ និងការរំពឹងទុកខ្ពស់ទៅលើលទ្ធផលនៃការចូលរួមរបស់ពួកគាត់។យ៉ាងណាមិញ ការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមការសិក្សារបស់កូន លោកគ្រូអ្នកគ្រូ និងនាយកគួរបង្កើនទំនាក់ទំនងជាមួយឪពុកម្តាយតាមរយៈមធ្យោបាយផ្សេងៗ ទាក់ទងទៅនឹងកម្មវិធីសាលា កម្មវិធីសិក្សា ព្រឹត្តិការណ៍សាលា។ល។ ផ្តល់ពត៌មានទាក់ទងទៅនឹងការសិក្សារបស់កូនពួកគាត់ឱ្យបានជាប្រចាំ បង្ហាញភាពស្និតស្នាលដើម្បីឲ្យពួកគាត់មានអារម្មណ៍កក់ក្តៅក្នុងការផ្តល់ពត៌មានត្រលប់វិញ (WIKI How'Staf, 2010)។

# ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការជ្រើសរើសភាគសំណាក

យោងតាមស្ថិតិនាឆ្នាំ ២០១៧ ទៅ ២០១៨ នៃក្រសួងអប់រំយុវជន និងកីឡា នៅរាជធានីភ្នំពេញ មានសាលាបឋមសិក្សាចំនួន ១៥១ (មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ឆ្នាំ ២០១៧ ២០១៨ ) ។ ក្នុងនោះដែរសាលាបឋមចំនួន ៨ ត្រូវបានរើសចេញពីខណ្ឌចំនួន ៧ ក្នុងចំណោមខណ្ឌទាំង១៤ នៅរាជធានីភ្នំពេញ ដោយជ្រើសរើសខណ្ឌមួយសាលា១ ក្នុងនោះមានដូចជា ខណ្ឌចំការមន ខណ្ឌមានជ័យ ខណ្ឌឫស្សីកែវ ខណ្ឌព្រែកព្នៅ ខណ្ឌសែនសុខ ខណ្ឌជ្រោយចង្វា និងខណ្ឌ៧មករា។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសភាគសំណាកឪពុកម្តាយសិស្ស ចំនួន ៨៥ នាក់ សិស្សចំនួន ៨៥នាក់ លោកគ្រូ អ្នកគ្រូចំនួន ៥០នាក់ ចំណែកនាយកចំនួន ៨ នាក់

### ភាគសំណាកតាមសាលាគោលដៅនីមួយៗ

| ល.រ | ឈ្មោះសាលាបឋមសិក្សា | ភាគសំណាក | | |
|---|---|---|---|---|
| | | នាយក | គ្រូ | សិស្ស |
| 1 | សាលាបឋមសិក្សាចំរើនរដ្ឋ | 1 | 4 | 10 |
| 2 | សាលាបឋមសិក្សាឫស្សីកែវ | 1 | 8 | 15 |
| 3 | សាលាបឋមសិក្សាព្រែកលាប | 1 | 5 | 110 |
| 4 | សាលាបឋមសិក្សាបាក់ទូក | 1 | 10 | 15 |
| 5 | សាលាបឋមសិក្សាទួលទំពូង | 1 | 7 | 6 |
| 6 | សាលាបឋមសិក្សាចំរើនផល | 1 | 6 | 10 |
| 7 | សាលាបឋមសិក្សាភ្នំពេញថ្មី | 1 | 7 | 15 |
| 8 | សាលាបឋមសិក្សាសំរោងជើង | 1 | 3 | 4 |
| សរុប | 8 | 50 | 85 | 188 នាក់ |
| ឪពុកម្តាយសិស្ស | 45 នាក់ជាក់ស្តែង | | | |

## ៣.២. ឧបករណ៍ស្រាវជ្រាវ

ដើម្បីសម្រេចតាមគោលបំណងនៃការស្រាវជ្រាវកម្រងសំណួរចំនួន៤ត្រូវបានរៀបចំឡើងសម្រាប់ឪពុកម្តាយសិស្ស នាយក នាយិកា លោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្សបំពេញ។ កម្រងសំណួរទាំងនោះត្រូវបានរៀបចំឡើងតាមបែបបរិមាណវិស័យ។ រាល់សំណួរជាទម្រង់បិទមានលក្ខណៈជាក់លាក់តាមលំដាប់លំដោយ និងមានសំណួរបន្ថែម បញ្ហាប្រឈមនិងសំណូមពរ តាមទម្រង់បើក។ ចំពោះកម្រងសំណួរទាំងបួន ផ្តោតសំខាន់ទៅ ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន និងយុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមចំពោះការអប់រំរបស់កូន។កម្រងសំណួរចំនួន៤ត្រូវបានយកទៅប្រើដើម្បីប្រមូលព័ត៌មានពីក្រុមគោលដៅរួមមាន៖ កម្រងសំណួរសម្រាប់ឪពុកម្តាយ សិស្ស នាយក នាយិកាសាលានិងគ្រូបង្រៀន។ កម្រងសំណួរនីមួយៗចែកជា ផ្នែកតាមមូលន័យដែលជាគោលបំណងនៃសិក្សាស្រាវជ្រាវ។

កម្រងសំណួរសម្រាប់ឪពុកម្តាយចែកជា ៥ផ្នែក។ ផ្នែកទី១ស្តីពីព័ត៌មានផ្ទាល់ខ្លួន ដោយសួរអំពី ភេទ អាយុ កម្រិតសិក្សា ស្ថានភាពគ្រួសារ និនមានបន្ថែមផងដែរពីមុខរបរ ពេលវេលាធ្វើការ និងប្រាក់ចំណូល ផ្នែកទី២ ស្តីពីដំណើរការនៃការចូលរួមរបស់ឪពុកម្តាយ ចំពោះការសិក្សារបស់កូន ផ្នែកនេះផ្តោតទៅលើការត្រួតពិនិត្យ និងតាមដានការសិក្សារបស់កូន ការបង្ហាត់បង្រៀនកូន ការចូលរួមធ្វើកិច្ចការផ្ទះ បទពិសោធន៍របស់ឪពុកម្តាយ ក្នុងការអប់រំកូន។ផ្នែកទី៣ផ្តោតទៅលើការជំរុញនិងលើកទឹកចិត្តកូនដោយមានការរំពឹងខ្ពស់របស់ឪពុកម្តាយ។ផ្នែកទី៤ផ្តោតលើទំនាក់ទំនងរវាងឪពុកម្តាយ សាលារៀននិងគ្រូបង្រៀន ផ្នែកទី៥បង្ហាញពីឥរិយាបថគំរូរបស់ឪពុកម្តាយ ផ្នែកនេះ បង្ហាញពីគំរូល្អ និងការអប់រំការទូន្មានកូនរបស់ឪពុកម្តាយ ការកំណត់ពេលវេលាប្រើប្រាស់ទូរសព្ទ ការបង្ហាញពីសារៈសំខាន់នៃការសិក្សា។ហើយផ្នែកនីមួយៗសួរពីបញ្ហាប្រឈម និងមានសំណូមពរសម្រាប់ពួកគាត់ផងដែរ។

កម្រងសំនួរសម្រាប់សិស្សមានបីផ្នែក ។ផ្នែកទី១ ផ្តោតទៅលើពត៌មានផ្ទាល់ខ្លួនរបស់សិស្ស ទាក់ទងកម្រិតថ្នាក់ និងអាយុ។ ផ្នែកទី២ផ្តោតលើ ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំពួកគាត់ នោះមានដូចជាការចំណាយពេលវេលាបង្រៀនកូន នាំកូនអាន ធ្វើលំហាត់ ការចូលរួមធ្វើកិច្ចការផ្ទះរបស់ឪពុកម្តាយ។

ចំណែកឯ ផ្នែកទី៣ លើកឡើងពីបញ្ហាប្រឈមនានាទាក់ទងនឹងការសិក្សា ដែលពួកគាត់បានជួបប្រទះនៅផ្ទះ។

កម្រងសំណួរសម្រាប់នាយក នាយិកាសាលា កម្រងសំណួរចំណុចនេះមាន ចែកចេញជាបីផ្នែកផ្នែកទី១ ផ្តោតទៅលើព័ត៌មានផ្ទាល់ខ្លួនរបស់នាយក នាយិកាទាក់ទងទៅនឹងកម្រិតនៃការសិក្សា និង រយៈពេលនៃការគ្រប់គ្រង។ផ្នែកទី២ ផ្តោតទៅលើការគ្រប់គ្រងក្នុងនោះរួមមាន ចំនួនសិស្សសរុប ការផ្តល់ព័ត៌មានទៅឪពុកម្តាយ ការជំរុញ និងការលើកទឹកចិត្តឪពុកម្តាយក្នុងការចូលរួមការសិក្សារបស់កូន និងការអញ្ជើញឪពុកម្តាយមកចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលា។ចំណែកផ្នែកទី៣សួរពីបញ្ហាប្រឈមនានាដែលពួកគាត់បានជួបប្រទះក្នុងការទំនាក់ទំនងជាមួយឪពុកម្តាយសិស្ស និងសំណូមពរផ្សេងៗរបស់នាយកសាលាទាក់ទងទៅនឹងការចូលរួមរបស់ឪពុកម្តាយ។

កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូប្រចាំថ្នាក់ កម្រងសំណួរចំណុចនេះ ចែកចេញជាបីផ្នែក ផ្នែកទី១នេះលើកឡើងពីព័ត៌មានផ្ទាល់ខ្លួនទាក់ទងទៅនឹងរយៈពេលបំរើការងារ និងកម្រិតថ្នាក់ដែលគាត់បង្រៀន។ ផ្នែកទី២ ផ្នែកនេះលើកឡើងពីការដាក់កិច្ចការផ្ទះ និងភាគរយនៃលទ្ធផលត្រលប់ដែលសិស្សបានប្រគល់ជូនគ្រូ។ផ្នែកទី៣ ផ្តោតលើការជំរុញនិងលើកទឹកចិត្តឪពុកម្តាយចំពោះការចូលរួមក្នុងការអប់រំកូន និងបញ្ហានានាដែលគ្រូបានជួបប្រទះក្នុងការទំនាក់ទំនងជាមួយឪពុកម្តាយសិស្ស។

### ៣.៣.១.ដំណើរការនៃការប្រមូលទិន្នន័យ

យោងតាមលិខិតលេខ ១១៤ វជអ. ផក ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០២០ របស់វិទ្យាស្ថានជាតិអប់រំ និង ទទួលបានការឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ការចុះប្រមូលទិន្នន័យ គឺ ចាប់ពីថ្ងៃទី១៧ ខែកក្កដា រហូតដល់ថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ តាមសាលាគោលដៅនីមួយៗ រួមមាន ៖ សាលាបឋមសិក្សាចំរើនរដ្ឋ សាលាបឋមសិក្សាឬស្សីកែវ សាលាបឋមសិក្សាព្រែកលាប សាលាបឋមសិក្សាបាក់ទូក សាលាបឋមសិក្សាទួលទំពូង សាលាបឋមសិក្សាចំរើនផល សាលាបឋមសិក្សាភ្នំពេញថ្មី និងសាលាបឋមសិក្សាសំរោងជើង ។

### ៣.៣.១.១ ការសាកល្បង

មុននឹងចុះប្រមូលទិន្នន័យជាផ្លូវការណ៍ អ្នកសិក្សាស្រាវជ្រាវបានយកកម្រងសំណួរទៅប្រើប្រាស់សាកល្បងដោយជ្រើសរើសយកនាយកពីរនាក់ លោកគ្រូអ្នកគ្រូចំនួនប្រាំបីនាក់ កូនសិស្សចំនួនដប់ប្រាំនាក់ មកសម្ភាសន៍ និងជួបផ្ទាល់ជាមួយឪពុកម្ដាយសិស្សចំនួនដប់នាក់ដោយដាក់កម្រងសំណួរឲ្យគាត់បំពេញសំណួរប្រើសម្រាប់សម្ភាសន៍ជាមួយនឹងសិស្សមិនសូវមានបញ្ហាប៉ុន្មានទេ ងាយស្រួលយល់សម្រាប់ពួកគាត់ ប៉ុន្តែសម្រាប់ឪពុកម្ដាយអ្នកសិក្សាស្រាវជ្រាវរកឃើញកំហុសមួយចំនួនក្នុងកម្រងសំណួរ បន្ទាប់មកអ្នកស្រាវជ្រាវពិភាក្សារជាមួយ សាស្ត្រាចារ្យដឹកនាំដើម្បីធ្វើការកែសម្រួលម្ដងទៀត។

### ៣.៣.១.២. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យប្រព្រឹត្តទៅតាមពេលវេលាកំណត់ដែលបានគ្រោងទុក។ អ្នកស្រាវជ្រាវ ចុះទៅប្រមូលផ្ទាល់តាមសាលាគោលដៅទាំងប្រាំបី ចាប់ផ្ដើមពីការផ្ដល់ព័ត៌មានរហូតដល់ការជួបតាមការណាត់។ ជាដំបូងអ្នកសិក្សាបានធ្វើការទំនាក់ទំនងជាមួយនាយក នាយិកា ជាមុន ដើម្បីដឹងថាថ្ងៃណាសាលាចែកសន្លឹកកិច្ចការដល់សិស្ស ងាយស្រួលអ្នកសិក្សាបានជួបសិស្សនិងឪពុកម្ដាយរបស់ពួកគាត់។ បន្ទាប់មកអ្នកសិក្សាបានចុះទៅតាមសាលាគោលដៅនីមួយៗតាមការណាត់ទុក។ ក្នុងការប្រមូលទិន្នន័យអ្នកសិក្សាបានជូនកម្រងសំណួរទៅលោកនាយក នាយិកា និងលោកគ្រូ អ្នកគ្រូទៅតាមចំនួននិងកម្រិតថ្នាក់ដែលបានគ្រោងទុកគឺលោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី៣ ទី៤ និង ទី៦ ដូចគ្នានេះដែរចំពោះសិស្សអ្នកសិក្សាបានជ្រើសរើសសិស្សថ្នាក់ទី៣ ទី៤ ទី៦ និងឪពុកម្ដាយដែលបានជូនពួកគាត់មកសាលា អ្នកសិក្សាបានប្រាប់ពួកគាត់ពីគោលបំណងរបស់ខ្លួនរួចសុំការអនុញ្ញាតិពួកគាត់ឲ្យជួយបំពេញកម្រងសំណួរ។ ការស្រាវជ្រាវនេះត្រូវបានជ្រើសរើសភាគសំណាកដោយចៃដន្យ ដោយជ្រើសរើសមាតាបិតាសិស្ស ចំនួន ៨៥ រូប សិស្សចំនួន ៨៥រូប សិស្សម្នាក់ ឪពុកឬម្ដាយម្នាក់ លោកគ្រូ អ្នកគ្រូ ចំនួន ៥០នាក់ ចំណែកនាយកចំនួន ៨នាក់ ។ ស្ថិតក្នុងបរិបទប្រទេសជួបបញ្ហារីករាលដាលនៃជំងឺ កូវីដ ១៩នេះ ការប្រមូលទិន្នន័យ ជួបការលំបាកមួយចំនួន ផងដែរដូចជា សាលារៀនត្រូវបិទមួយរយៈ រាល់ការជួបគ្នាតម្រូវឲ្យម្នាក់ៗស្ថិតនៅគម្លាតពីគ្នា និងត្រូវគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល។ម៉្យាងទៀតឪពុកម្ដាយខ្លះមិនសូវមានពេល ដើម្បី

បំពេញកម្រងសំណួរព្រោះគាត់ប្រញាប់ទៅធ្វើការ ឬប្រកបរបរទទួលទាន ដូច្នេះចំពោះភាគសំណាកឪពុកម្ដាយដែលបានបំពេញកម្រងសំណួរមានចំនួនតែ៤៥នាក់តែប៉ុណ្ណោះ ពោលគឺមិនបានឆ្លើយតបទៅតាមចំនួនដែលបានគ្រោងទុកឡើយ។

### ៣.៣.២. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យធ្វើឡើងតាមបរិមាណវិស័យបែបពណ៌នា (Descriptive statistic) បកស្រាយនិងវិភាគទិន្នន័យផ្អែកលើតួលេខតារាង ក្រាប ភាគរយ និងកម្រិតតម្លៃមធ្យមដោយប្រើកម្មវិធី SPSS និង EXCEL ។ ចំពោះកម្មវិធី SPSS អ្នកសិក្សាបញ្ចូលចម្លើយនីមួយៗទៅក្នុងកម្មវិធីSPSS ដោយចម្លើយនីមួយៗអ្នកស្រាវជ្រាវធ្វើការបង់លេខកូដត្រឹមត្រូវស្របតាមកម្រិតនៃការវាស់វែង សូចនាករនីមួយៗ និងធ្វើការបកស្រាយនិងវិភាគតាមភាគរយនិងតាមកម្រិតតម្លៃមធ្យមដោយផ្អែកតាមទ្រឹស្ដី Oxfords & Burry Stocks (1995) វាស់តម្លៃនៃកម្រិតមធ្យម ៖ (1 – 2.4 ) ទាប ( 2.5 – 3.4 ) មធ្យម (3.5 – 5 ) ខ្ពស់ ។ ជាមួយគ្នានេះដែរ អ្នកសិក្សាប្រើកម្មវិធី Excel ដើម្បីបង្កើត ក្រាបសសរ។ ចំណែកឯសំណួរបើកវិញ អ្នកសិក្សាបានអានគ្រប់ទិន្នន័យទាំងអស់ រួចធ្វើការផ្ដុំតាមមូលន័យ និងចាប់តាមគំនិតសំខាន់ៗ រួចធ្វើការស្រង់យកគំនិតយោបល់ទាំងនោះមកធ្វើការបកស្រាយនិងវិភាគទៅតាមចំណុចនីមួយៗ។

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

ក្នុងជំពូកនេះ  អ្នកសិក្សាស្រាវជ្រាវធ្វើការបកស្រាយនិង វិភាគតាមទិន្នន័យដែលទទួលបានពីការបំពេញកម្រងសំណួររបស់ឪពុកម្តាយសិស្ស នាយក នាយិកាសាលា លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សតាមសាលាគោលដៅទាំងប្រាំបី  ។ការបកស្រាយផ្តោតទៅលើបីចំណុចសំខាន់ៗ ដែលឆ្លើយតបទៅនឹងវត្ថុបំណងនៃការស្រាវជ្រាវ រួមមាន ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយ និងយុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឲ្យចូលរួមចំពោះការអប់រំកូន។

## ៤.១. លទ្ធផល

### ៤.១.១. ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំរបស់កូន

ក្នុងដំណើរការ  ឬលំនាំនៃការចូលរួមរបស់ឪពុកម្តាយរួមចំណែកយ៉ាងខ្លាំងដល់ការអប់រំកូន។ ដំណើរការចូលរួមនោះទៀតសោតមានលក្ខណៈខុសគ្នាពីម្នាក់ទៅម្នាក់ ផ្អែកលើស្ថានភាពជាក់ស្តែងរបស់ក្រុមគ្រួសារ ដូចជា ចំណេះដឹង សេដ្ឋកិច្ច ពេលវេលា កត្តាទំនាក់ទំនងសាលា និងកត្តាផ្សេងៗទៀត។ ខាងក្រោមនេះគឺជាលទ្ធផលដែលបានពីការវិភាគលើផ្នែកសំខាន់ៗដែលអ្នកសិក្សាស្រាវជ្រាវបង្ហាញក្នុងរូបភាព និងតារាងគិតជាភាគរយ និងមធ្យម ដោយ យោងតាម តម្លៃមធ្យម៖ កម្រិតទាប (1- 2.4) កម្រិតមធ្យម (2.5 - 3.4)  និងកម្រិតខ្ពស់ (3.5 - 5) (Oxford & Burry – stock 1995)។

#### ៤.១.១.១. ការចូលរួមចំពោះកិច្ចការផ្ទះរបស់កូន



ពិនិត្យមើលសំណួរទី11 កម្រិតតម្លៃមធ្យម (Q.11Pa) ( Mean = 2.83 ) បង្ហាញថាឪពុកម្តាយមានការយល់ពីតួនាទីរបស់ខ្លួនចំពោះការសិក្សារបស់កូន ក្នុងកម្រិតមធ្យម ដោយឪពុកម្តាយ 56.25% បានយល់ច្បាស់ពីតួនាទីរបស់ខ្លួន។ ផ្អែកលើ (Q.12) ( Mean = 2.96 ) បង្ហាញថាឪពុកម្តាយយល់ពីសារៈសំខាន់នៃការចូលរួមចំពោះការអប់រំកូនក្នុងកម្រិតមធ្យមដោយ70.83% យល់ច្បាស់ពីសារៈសំខាន់នៃការចូលរួម ពិនិត្យមើលសំណួរទី16 កម្រិតមធ្យមនៃការចូលរួមធ្វើកិច្ចការផ្ទះ របស់ឪពុកម្តាយ (Q.16) ( mean = 2.77 ) បានបង្ហាញថាឪពុកម្តាយបានចូលរួមជួយកូនក្នុងការធ្វើកិច្ចការផ្ទះក្នុងកម្រិតមធ្យម បើទោះបីជាគាត់ពុំសូវមានពេលវេលាគ្រប់គ្រាន់ក៏ដោយផ្អែកលើសំណួរទី6 (Q.6) (Mean = 2.26) ហើយសិស្សភាគច្រើនតែងតែយកកិច្ចការ ដែលពួកគេបានធ្វើមកប្រគល់ឱ្យលោកគ្រូអ្នកគ្រូពិនិត្យវិញក្នុងកម្រិតមធ្យម ផ្អែកលើសំណួរទី (Q.5) (Mean = 2.92) នៃការត្រួតពិនិត្យកិច្ចការផ្ទះរបស់លោកគ្រូ អ្នកគ្រូ។ ជាមួយគ្នានេះដែរកូនក៏បានស្នើសុំឱ្យឪពុកម្តាយជួយធ្វើម្តងម្កាលក្នុងកម្រិតទាប (Q4.stu) ( mean = 2.01) ប៉ុន្តែទន្ទឹមនឹងនេះ ឪពុកម្តាយតែងតែជួយធ្វើកិច្ចការផ្ទះកូនជាប្រចាំ ក្នុងកម្រិតមធ្យមដោយផ្អែកទៅលើ (Q5. stu) ( Mean = 2.6)។ តាមរយៈសំណួរបើក (Q7) សិស្សបង្ហាញថាឪពុកម្តាយពួកគេ បានជួយពន្យល់នូវអ្វីដែលគេមិនយល់បន្ទាប់ពីគេសិក្សានៅសាលា។ ចំណែកឯអ្នកខ្លះបានអះអាងថា ឪពុកម្តាយពួកគេបានជួយធ្វើកិច្ចការផ្ទះ (P55) បានរៀបរាប់ថា ៖ " គាត់ជួយខ្លះៗ គាត់បង្រៀន ភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ សិក្សាសង្គម ធ្វើលំហាត់ និងកិច្ចការផ្ទះ " ។ រីឯ P(31)លើកឡើងថា ៖ " គាត់បាននាំកូន ធ្វើលំហាត់ អានសៀវភៅ ធ្វើកិច្ចការផ្ទះ និងបង្រៀនកូនសរសេរ"។ជាមួយគ្នានេះតាមរយៈសំណួរបើក (Q20.Pa)ឪពុកម្តាយមួយចំនួនបាននាំកូនធ្វើលំហាត់ រំលឹកមេរៀន និងធ្វើកិច្ចការផ្ទះ។ ចំណែកឯអ្នកខ្លះទៀតជួយពន្យល់កូនពីរបៀបធ្វើកិច្ចការផ្ទះ និងជំរុញកូនឱ្យខិតខំអានសៀវភៅ។ (P40) បានប្រាប់ថា"ខ្ញុំបានជួយឱ្យកូនអាន និងធ្វើកិច្ចការផ្ទះ។ យោងតាមលទ្ធផលនៃការសិក្សាបង្ហាញឲយើញថាឪពុកម្តាយនៅរាជធានីភ្នំពេញបានចូលរួមជួយធ្វើកិច្ចការសាលារបស់កូនក្នុងកម្រិតមធ្យម ។

[illegible]

| បរិយាយ (ឪពុកម្ដាយ) | មិនដែលសោះ (%) | ម្ដងម្កាល(%) | ជាប្រចាំ (%) | ញឹកញាប់(%) | ញឹកញាប់ណាស់ (%) | មធ្យម | គំលាតស្តង់ដា |
|---|---|---|---|---|---|---|---|
| Q16.បានចូលរួមធ្វើកិច្ចការផ្ទះរបស់កូន | 4.16 | 39.58 | 31.24 | 14.58 | 6.25 | 2.77 | 1.005 |
| Q18.ធ្លាប់នាំកូនអានឬធ្វើលំហាត់ | 6.26 | 47.91 | 33.33 | 12.5 | 2.08 | 2.66 | 0.515 |
| Q3ឪពុកម្ដាយ.ធ្លាប់នាំកូនអានសៀវភៅ ឬ ធ្វើលំហាត់ | 8.23 | 54.12 | 37.65 | 0 | 0.61 | 2.29 | 0.61 |
| Q5.ពួកគាត់ជួយធ្វើកិច្ចការផ្ទះកូន | 9.41 | 74.1 | 16.47 | 0 | 0.50 | 2.60 | 0.50 |
| Q6.ពួកគាត់មានពេលគ្រប់គ្រាន់ដើម្បីជួយកូន | 2.35 | 71.76 | 25.88 | 0 | 0.49 | 2.26 | 0.49 |

## ៤.១.១.២. ការបង្ហាត់បង្រៀន និងការពិនិត្យតាមដាន

[illegible]

| បរិយាយ៖ ឪពុកម្ដាយ អប់រំកូន បង្ហាត់បង្រៀន និងពិនិត្យតាមដាន) | មិនដែលសោះ (%) | ម្ដងម្កាល % (%) | ជាប្រចាំ (%) | ញឹកញាប់ (%) | ញឹកញាប់ណាស់ (%) | មធ្យម | គំលាតស្តង់ដា |
|---|---|---|---|---|---|---|---|
| Q17. ការជួយបង្រៀនកូន | 6.24 | 43.75 | 31.25 | 14.58 | 4.16 | 2.7 | 0.93 |
| Q.18.នាំកូនអានឬធ្វើលំហាត់ | 6.26 | 47.91 | 33.33 | 12.5 | 2.08 | 2.66 | 0.52 |
| Q3. ឪពុកម្ដាយនាំកូនអានសៀវភៅ ឬ ធ្វើលំហាត់ (សិស្ស) | 8.23 | 54.12 | 37.65 | 0 | 0 | 2.29 | 0.61 |
| Q,38 ផ្ដល់ការអប់រំទូន្មានដល់កូន | 0 | 14.59 | 85.4 | 0 | 0 | 2.29 | 0.29 |
| Q14.ពិនិត្យសៀវភៅតាមដានរបស់កូន | 0 | 22.93 | 60.41 | 10.41 | 6.25 | 3.02 | 0.77 |
| Q15.ពិនិត្យសៀវភៅសរសេររបស់កូន | 2.08 | 33.33 | 43′75 | 18.75 | 2.08 | 2.87 | 0.82 |
| Q37.កំណត់ពេលដាក់លាក់ចំពោះការប្រើប្រាស់ទូរសព្ទ័របស់កូន | 6.24 | 25 | 68. 75 | 0 | 0 | 2.73 | 0.5 |

ពិនិត្យមើលសំណួរទី17 (Q17.Pa) (Mean = 2.70) បានបង្ហាញថាឪពុកម្តាយសិស្សបានបង្ហាត់បង្រៀនកូនក្នុងកម្រិតមធ្យម ដោយ 31.25% បានជួយបង្រៀនកូនជាប្រចាំ 14.56%បានយកចិត្តទុកដាក់បង្ហាត់បង្រៀនកូនជាញឹកញាប់ និងមានតែ4.16% ប៉ុណ្ណោះ ដែលមិនធ្លាប់បង្រៀនកូនទាល់តែសោះ ហើយ 4.16% ដដែលបានឱ្យតម្លៃខ្ពស់ទៅលើការសិក្សាហើយបានបង្រៀនកូនញឹកញាប់។ ផ្អែកលើ (Q18. Pa)( Mean = 2.66) បានបង្ហាញថាឪពុកម្តាយបាននាំកូនធ្វើលំហាត់ ឬអាននៅក្នុងកម្រិតមធ្យម ដោយ33.33%បាននាំកូនអាន និងធ្វើលំហាត់ជាប្រចាំ 45.83%បាននាំកូនអាន និងធ្វើលំហាត់ម្តងម្កាល។ រីឯ 12.50% បានយកចិត្តទុកដាក់ជាខ្លាំងក្នុងការនាំកូនរៀន ហើយ 2.08% បានចាត់ទុកការបង្រៀនកូនជាការសំខាន់ និងបានបង្ហាត់បង្រៀនកូន និងនាំកូនរៀនញឹកញាប់បំផុត ហើយ 2.08% ដដែលពុំសូវឱ្យតម្លៃទៅលើការសិក្សារៀនសូត្រទេ និងមិនបានបង្រៀនកូនទាល់តែសោះ។ស្របគ្នានេះដែរ ផ្អែកលើសំណួរបើក (Q20.Pa) បានបង្ហាញថាឪពុកម្តាយភាគច្រើនបាននាំកូន អានសៀវភៅ ធ្វើលំហាត់ រំលឹកមេរៀន។ (P.23. Pa) បានលើកឡើងថា " ពេលខ្លះខ្ញុំជួយមើលមេរៀន និងសួរនូវចំណុច ដែលគាត់មិនសូវយល់ និងជួយពិនិត្យមើលការងាររបស់គាត់ " ។ ចំណែង (P12.Pa) បានបង្ហាញថា "ខ្ញុំជួយបង្រៀនកូនជារៀងរាល់ថ្ងៃ និងផ្តល់យោបល់ល្អៗឱ្យគាត់ ព្រមទាំងប្រាប់កូនពីសារៈសំខាន់នៃការសិក្សា"។ (P11) បានបង្ហាញថា ខ្ញុំជំរុញឱ្យកូនរៀន និងធ្វើលំហាត់ជាញឹកញាប់ និងមើលកិច្ចការដែលបានមកពីសាលា" ។ រីឯសំណួរ (Q7 Stu) សិស្សភាគច្រើនបានបង្ហាញថា ឪពុកម្តាយពួកគេបានបង្រៀន គណិតវិទ្យា រៀនលេខ អានសៀវភៅ និងធ្វើលំហាត់។ ឯមួយចំនួនទៀតបានអះអាងថាឪពុកម្តាយពួកគេបានបង្រៀនគេ គ្រប់មុខវិជ្ជា។ ចំណែក (P51 Stu) គាត់បានបង្រៀនអក្សរ ភាសារខ្មែរ គណិតវិទ្យា និង វិទ្យាសាស្រ្ត ចំណែកឯ (P16) បានលើកឡើងថាគាត់បានបង្រៀនគណិតវិទ្យា ភាសាខ្មែរ និងភាសាអង់គ្លេស ការចូលរួមរបស់ឪពុកម្តាយចំពោះការសិក្សាបានធ្វើឱ្យការសិក្សារបស់កូនមានការផ្លាស់ប្តូរ និងកាន់តែប្រសើរឡើងជារឿយៗ។ ជាក់ស្តែង (Q8) សិស្សភាគច្រើនបានអះអាងថា ពួកគេទទួលបានលទ្ធផលសិក្សាល្អជាងមុន ធ្វើលំហាត់ត្រូវច្រើនជាងមុន។ អ្នកខ្លះទៀតបានបង្ហាញថា ពួកគេប្រឹងប្រែងរៀនសូត្រជាងមុន ដោយសារតែ

មានការចូលរួមពីឪពុកម្តាយ។ (P9) បានរៀបរាប់ថា ៖ ការជួយរបស់គាត់ធ្វើឱ្យខ្ញុំយល់ដឹងមុខវិជ្ជាណាមួយ ធ្វើឱ្យខ្ញុំចងចាំមេរៀន និងយល់មេរៀនជាច្រើនទៀត។ ចំណែកឯ (P10) បានលើកឡើងថា ៖ " ការជួយរបស់ឪពុកម្តាយធ្វើអោយខ្ញុំចេះគ្រប់ពាក្យ ធ្វើលំហាត់ បានពិន្ទុល្អ និងប្រលងជាប់ " ។ (P 80) បានអះអាងថា ៖ " ការជួយរបស់គាត់ធ្វើឱ្យខ្ញុំ អាចអានបាន និងចេះគុណចែក បូកដកបានត្រឹមត្រូវ "។ ស្របជាមួយគ្នានេះដែរ ពីនិត្យមើលសំណួរទី13 ដដែល កម្រិតតម្លៃមធ្យមនៃ លទ្ធផលសិក្សារបស់សិស្សដែលឪពុកម្តាយបានចូលរួម(Q13Pa) (Mean = 2.79) បានបង្ហាញថាលទ្ធផលសិក្សារបស់កូនពួកគាត់ល្អបង្គួរក្នុងកម្រិតមធ្យម។ លើសពីនេះទៅទៀ ត ឪពុកម្តាយភាគច្រើនក៏បានយកចិត្តទុកដាក់ចំពោះការត្រួតពិនិត្យសៀវភៅតាមដាន ជាប្រចាំក្នុងកម្រិតមធ្យមផ្អែកលើ(Q14.Pa) ( Mean = 3.02) ។ ចំណែកឯការត្រួតពិនិត្យសៀវភៅសរសេរវិញ ឪពុកម្តាយ 43.75% បានត្រួតពិនិត្យសៀវភៅសរសេររបស់កូនជាប្រចាំ 18.73% បានត្រួតពិនិត្យមើលញឹកញាប់និង2.08%បានយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះសៀវភៅសរសេររបស់ កូន។ម៉្យាងទៀតឪពុកម្តាយក៏បានកំណត់ពេលក្នុងការប្រើប្រាស់ទូរសព្ទ័របស់កូនយ៉ាងប្រុងប្រយត្ន័ជាប្រចាំក្នុងកម្រិតមធ្យមផងដែរ ដោយសំអាងទៅលើ (Q37)( Mean = 2.73)។ក្រៅពីនេះ ឪពុកម្តាយក៏បានយកចិត្តទុកដាក់ទៅលើការទូន្មានអប់រំកូនក្នុងកម្រិតមធ្យម(Q38)(Mean=2.91)និ (Q39)(Mean= 2.85) បង្ហាញថាឪពុកម្តាយបានប្រាប់ពីសារៈសំខាន់នៃការសិក្សាកូនក្នុងកម្រិតមធ្យម។ ដោយផ្អែកលើតម្លៃមធ្យមសរុប នៃការបង្ហាត់បង្រៀន និងពិនិត្យតាមដានការសិក្សារបស់កូន (Mean = 2.80) បានបង្ហាញថា ឪពុកម្តាយនៅរាជធានីភ្នំពេញបានចូលរួមបង្ហាត់បង្រៀតកូននិងពិនិត្យតាមដានការសិក្សារបស់កូនក្នុងកម្រិតមធ្យម ។

### ៤.១.១.៣. ការជំរុញ និងការលើកទឹកចិត្ត




ការចូលរួមជំរុញ និងលើកទឹកចិត្តរបស់ឪពុកម្តាយចំពោះ ការសិក្សារបស់កូនគឺជាកម្លាំងចលករដ៏សំខាន់ក្នុងការបង្កើនឆន្ទៈរបស់កូនឲខិតខំប្រឹងប្រែងរៀនសូត្រកាន់តែខ្លាំងឡើង។ ការលើកទឹកចិត្តកូនធ្វើឡើងតាមសកម្មភាពជាច្រើនដូចជា ការឱ្យរង្វាន់ ការពោលពាក្យសរសើរ ការបង្ហាញឥរិយាបថគំរូ ការផ្តល់ជាកម្លាំងចិត្ត ការបង្ហាញពីសារៈសំខាន់នៃការសិក្សាដល់កូន។ល។ ពិនិត្យមើលសំណួរទី23 កម្រិតតម្លៃមធ្យមនៃការកំណត់ការរំពឹងទុក លទ្ធផលនៃការសិក្សារបស់កូន (Q 23)( Mean = 2.69) បានបង្ហាញថាឪពុកម្តាយមានការរំពឹងខ្ពស់ទៅលើលទ្ធផលនៃការសិក្សារបស់កូនក្នុងកម្រិតមធ្យម ដោយ 68.75% បានកំណត់ការរំពឹងទុកលទ្ធផលនៃការសិក្សារបស់កូនខ្ពស់ ។ ផ្អែកទៅលើ (Q.24)( Mean = 2.98) បង្ហាញថាឪពុកម្តាយចង់ឱ្យកូនរៀនបានខ្ពង់ខ្ពស់ក្នុងកម្រិតមធ្យម ដោយ70.83% មានបំណងចង់ឱ្យកូនបន្តការសិក្សាបានខ្ពស់។ ពិនិត្យមើលសំណួរទី39 (Q.39Pa) (Mean = 2.85) បង្ហាញថាឪពុកម្តាយបានប្រាប់ពីសារៈសំខាន់នៃការសិក្សាដល់កូនជាប្រចាំក្នុងកម្រិតមធ្យម ហើយឪពុកម្តាយ 85.41% បានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់ការអប់រំទូន្មានដល់កូនជាប្រចាំ ក្នុងកម្រិតមធ្យមដោយផ្អែកលើ(Q38) (Mean = 2.91 ។ (Q.40) ផ្អែកតាមសំណួរបើក (Q.40) (P47) បានអះអាងថា " ខ្ញុំប្រាប់កូនជាប្រចាំ ពីសារៈសំខាន់នៃការសិក្សា"។ ចំណែកឯ (P40) (Q40) បានប្រាប់កូនថា ៖ " ការសិក្សាអាចជួយកូនបាន កូនអាចគិតបានវែងឆ្ងាយ សម្រេចចិត្តបានត្រឹមត្រូវ " " ចំណេះដឹងគឺជាពន្លឺនៃជីវិតរបស់កូនវា អាចជួយនៅ

ពេលដែលកូនជួបឧបសគ្គ មិនថាតិចឬច្រើន ៉ ការអះអាងរបស់ (P.17) ចំណែកឯ (P21) បានប្រាប់ថា ៖ "ខ្ញុំនិយាយពន្យល់គាត់ឱ្យគាត់ខិតខំរៀនសូត្រព្រោះចំណេះដឹងនេះហើយធ្វើឱ្យកូនមានអនាគតល្អ" សំអាងលើសំណួរបើក(Q.25) ឪពុកម្ដាយភាគច្រើនបានលើកចិត្តកូនដោយឱ្យរង្វាន់ដល់កូន សរសើរកូននៅពេលដែលកូនទទួលបានលទ្ធផលសិក្សាល្អ។ ជាក់ស្ដែង P(26) បានអះអាងថា " ខ្ញុំលើកទឹកចិត្តជារង្វាន់ និងជូនគាត់ដើរលេង ៉ ។ចំណែក P(44)បានប្រាប់ថា " ខ្ញុំនិយាយពន្យល់ណែនាំ ឱ្យស្គាល់ពីតម្លៃនៃការខិតខំសិក្សារៀនសូត្រផលប្រយោជន៍ដែលទទួលបានពីការខិតខំរៀនសូត្រ"។ពិនិត្យមើលសំណួរទី៣៦ (Q.36)(Mean=2.67) បង្ហាញថាឪពុកម្ដាយមានឥរិយាបថគំរូដល់កូនជាប្រចាំក្នុងកម្រិតមធ្យម ជាក់ស្ដែង P(18) បានបញ្ជាក់ថា៖ " ខ្ញុំធ្វើជាគំរូក្នុងការសិក្សាដល់កូនជាប្រចាំ" ចំណែក P(45) "ខ្ញុំទិញសៀវភៅល្អៗមកអាននៅពេលទំនេរដើម្បីឱ្យកូនយកគំរូតាមនិងបណ្ដុះគំនិតឱ្យកូនស្រលាញ់ការអាននិងការសិក្សារៀនសូត្រ"។ ផ្អែកតាមកម្រិតតម្លៃមធ្យមនីមួយៗ និងស្រង់មតិឪពុកម្ដាយ ខាងលើបង្ហាញឱ្យឃើញថា ឪពុកម្ដាយភាគច្រើននៅក្នុងរាជធានីភ្នំពេញ បានយកចិត្តទុកដាក់ខ្ពស់ និងព្យាយាមធ្វើការជំរុញ និងលើកទឹកចិត្តកូនខ្ពស់ ទាំងផ្នែកស្មារតី និង សម្ភារៈ ធ្វើយ៉ាងណាឱ្យកូនមានកម្លាំងចិត្ត និងសេចក្ដីសង្ឃឹមនៅក្នុងការសិក្សា។

## ៤.១.១.៤. ភាពជាដៃគូរវាងគ្រួសារ និងសាលារៀន

| បរិយាយ៖ ( ឪពុកម្ដាយ) | មិនដែលសោះ % | ម្ដងម្កាល % | ជាប្រចាំ (%) | ញឹកញាប់ (%) | ញឹកញាប់ណាស់ (%) | មធ្យម | គំលាតស្តង់ដារ |
|---|---|---|---|---|---|---|---|
| Q27. ធ្លាប់ទៅសាកសួរពត៌មានអំពីការសិក្សារបស់កូននៅសាលារៀន | 20.43 | 49.91 | 18.75 | 8.83 | 2.08 | 2.24 | 0.95 |
| Q28. ទទួលបានពត៌មានទាក់ទងនឹងការសិក្សារបស់កូន | 8.34 | 43.75 | 33.33 | 6.25 | 4.16 | 2.57 | 0.83 |
| Q29. សាលាឬ លោកគ្រូ អ្នកគ្រូតែងតែលើកទឹកចិត្តលោក/លោកស្រីក្នុងការចូលរួមចំពោះការសិក្សាកូន | 8.34 | 39.58 | 31.25 | 12.5 | 4.16 | 2.67 | 0.94 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| Q31.សាលារៀនធ្លាប់អញ្ជើញលោក/លោកស្រី ចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលា | 27.07 | 56.25 | 4.16 | 6.25 | 2.08 | 2.02 | 0.89 |
| Q5. ឪពុកម្ដាយសិស្សឧស្សាហ៍មកសាកសួរពត៌មានអំពីការសិក្សារបស់កូនគាត់( នាយក) | 0 | 50 | 50 | 0 | 0 | 2.5 | 0 |
| Q.7. ការអញ្ជើញឪពុកម្តាយរបស់សិស្សឱ្យចូលរួមសកម្មភាពផ្សេងៗរបស់សាលា( នាយក) | 0 | 87.6 | 12.5 | 0 | 0 | 2.13 | 0.35 |
| Q.6. លោកគ្រូ /អ្នកគ្រូតែងតែទំនាក់ទំនងទៅឪពុកម្តាយ សិស្សទាក់ទងនឹងការសិក្សារបស់កូនៗពួកគាត់ | 0 | 18 | 82 | 0 | 0 | 2.82 | 0.38 |

ការទំនាក់ទំនងរវាងឪពុកម្តាយសិស្សនិងសាលារៀន បានផ្តល់អត្ថប្រយោជន៏ជាច្រើន ដល់សិស្ស រួមមានបង្កើនសមត្ថភាពក្នុងថ្នាក់ ពង្រឹងផ្នែកវិន័យសណ្តាប់ធ្នាប់ កែលម្អអាកប្បកិរិយារបស់សិស្សតាមរយៈការផ្តល់ពត៌មានទៅវិញទៅមករវាងគ្រួសារនិងសាលារៀន។ ផ្អែកលើសំណួរ ( Q.27. Pa) ( Mean = 2.24)បានបង្ហាញថា ឪពុកម្តាយបានទៅសាកសួរពត៌មានទាក់ទងនឹងការសិក្សារបស់កូនស្ថិតនៅក្នុងកម្រិតទាបដោយ 18.75% មិនដែលទៅសាកសួរពត៌មានសាលាទាល់តែសោះ រីឯ 49.91% បានទៅសាកសួរ និងផ្តល់ពត៌មានអំពីការសិក្សាកូនម្តងម្កាល ចំណែក 18.75% បានទៅជាប្រចាំ មានតែ 8.83% និង 2.08% បានទៅសាកសួរពត៌មានបានញឹកញាប់ និងញឹកញាប់បំផុត។ នេះបញ្ជាក់ឱ្យឃើញថា ការទៅសាកសួរពត៌មាននៅសាលរៀនរបស់ឪពុកម្តាយ ទាក់ទងនឹងការសិក្សាកូនគឺស្ថិតនៅក្នុងកម្រិតទាបនៅឡើយ។ ប៉ុន្តែបើផ្អែកលើសំណួរទី៥ដែលបំពេញដោយនាយក (Q.5.D) (Mean= 2.5) បានបង្ហាញថាឪពុកម្តាយសិស្សបានមកសាកសួរពត៌មានស្តីពីការសិក្សារបស់កូនក្នុងកម្រិតមធ្យម ដោយ 50% មកសួរម្តងម្កាល និង50%មកសាកសួរព័ត៌មានទាក់ទងនឹងការសិក្សារបស់កូនជាប្រចាំ ហើយមិនមានឪពុកម្តាយណាម្នាក់ដែលមិនបានមកសួរពត៌មានទេ។ លើសពីនេះបើពិនិត្យលើតារាងដដែល សំណួរទី 28 ដែលបំពេញដោយឪពុកម្តាយ (Q.28Pa) (Mean= 2.57) បានបង្ហាញថាលោកគ្រូ អ្នកគ្រូតែងតែផ្តល់ពត៌មានទាក់ទងនឹងការសិក្សារបស់សិស្សក្នុងកម្រិតមធ្យម ដោយ 33.33% ទទួលបានព័ត៌មានជាប្រចាំ រីឯ 6.25% និង 4.16% បានទទួលព័ត៌មានពីសាលាញឹកញប់ និងញឹកញាប់បំផុត។ ចំណែក 6.25%មិនដែលបានទទួលព័ត៌មានទាក់ទងទៅ

នឹងការសិក្សារបស់កូនទាល់តែសោះ។ តាមរយៈសំណួរ (Q.33Pa) ឪពុកម្តាយភាគច្រើនបានអះអាងថា ពួកគាត់ទទួលព័ត៌មានពីសាលាទាក់ទងនឹងលទ្ធផលសិក្សារបស់កូន។ ស្របជាមួយគ្នានេះដែរ ផ្អែកលើសំណួរទី6 ដែលបានបំពេញដោយលោកគ្រូ អ្នកគ្រូ (Q. 6) (Mean= 2.64) បង្ហាញថា លោកគ្រូ អ្នកគ្រូ តែងតែទំនាក់ទំនងទៅឪពុកម្តាយ ទាក់ទងនឹងការសិក្សារបស់កូនពួកគាត់ជាប្រចាំ ក្នុងកម្រិតមធ្យម ដោយ 64% បានផ្តល់ព័ត៌មានដល់ឪពុកម្តាយជាប្រចាំ ចំណែក 36% នៃលោកគ្រូ អ្នកគ្រូបានផ្តល់ទៅឪពុកម្តាយសិស្សម្តងម្កាល ហើយគ្មានលោកគ្រូអ្នកគ្រូណាម្នាក់ដែលមិនដែលផ្តល់ពត៌មានទៅឪពុកម្តាយសិស្សឡើយ។ យោងតាមសំណួរបើក (Q. 8.t) បានបញ្ជាក់ថា លោកគ្រូអ្នកគ្រូភាគច្រើន បានផ្តល់ពត៌មានទៅពុកម្តាយឱ្យពួកគាត់ជួយជំរុញកូនបន្ថែមក្នុងការខិតខំរៀនសូត្រ និងធ្វើកិច្ចការផ្ទះ ឯមួយចំនួនទៀតបានផ្តល់ព័ត៌មានទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស ហើយអ្នកខ្លះទៀតបានផ្តល់ពត៌មានទាក់ទងទៅនឹងអាកប្បកិរិយារបស់សិស្ស ដូចជា ការមករៀនយឺត ភាពខ្ជិលច្រអូសមិនធ្វើកិច្ចការផ្ទះ សិស្សឧស្សាហ៍ឈប់ញឹកញាប់ជាដើម។ តាមរយៈសំណួរទី27 និង28 ដែលបំពេញដោយឪពុកម្តាយ បានសបញ្ជាក់ឱ្យឃើញថា កម្រិតមធ្យមនៃការទៅសាកសួរពត៌មានទាក់ទងនឹងការសិក្សារបស់កូន (Mean =2.24)តូចជាងតម្លៃមធ្យមនៃការទទួលពត៌មានទាក់ទងនឹងការសិក្សារបស់កូនពីលោកគ្រូអ្នកគ្រូ(Mean=2.57)មានន័យថាឪពុកម្តាយមិនសូវយកចិត្តទុកដាក់ទៅសាកសួរពត៌មាននៅសាលាទេ ប៉ុន្តែពួកគាត់រងចាំទទួលពត៌មានពីសាលាវិញ។ ចំពោះការអញ្ជើញឪពុកម្តាយឱ្យចូលរួមក្នុងកម្មវិធីផ្សេងៗរបស់សាលានៅមានធកល្វេងដែរ ផ្អែកលើ (Q.31Pa)(Mean=2.08) បានបង្ហាញឱ្យឃើញថាសាលាអញ្ជើញឪពុកម្តាយចូលរួមសកម្មភាពសាលាក្នុងកម្រិតទាប ក្នុងនោះដែរ 22.91% មិនទទួលបានការអញ្ជើញពីសាលាទាល់តែសោះ ដោយឡែក 56.25% ទទួទបានការអញ្ជើញម្តងម្កាល 4.16% ទទួលបានការអញ្ជើញជាប្រចាំ ចំណែកឯ 6.25% និង2.08% បានទទួលការអញ្ជើញពីសាលាញឹកញាប់ និងញឹកញាប់បំផុត។ ទន្ទឹមនឹងនេះពិនិត្យមើលសំណួរទី7 ដែលបានបំពេញដោយនាយក (Q.7)( Mean= 2.13) បង្ហាញថាសាលាបានអញ្ជើញឪពុកម្តាយឱ្យចូលរួមសកម្មភាពផ្សេងៗរបស់សាលាក្នុងកម្រិតទាបដែរ។ ( P.10) (Q.34) " នាងខ្ញុំមិនធ្លាប់បានអញ្ជើញឱ្យចូល

រួមក្នុងកម្មវិធីសាលាទេ” ហើយបើយោងទៅតាមសំណួរបើក (Q.8) ដែលបានបំពេញដោយនាយក នាយិកាដដែលបានបញ្ជាក់ឱ្យឃើញថា នាយកភាគច្រើនបានអញ្ជើញឪពុកម្តាយចូលរួមក្នុងកម្មវិធីសាលាដូចជា បើកបវេសនកាល បុណ្យផ្កាសាមគ្គី ទិវាកុមារអន្តរជាតិ។ ដូច្នេះការអញ្ជើញឪពុកម្តាយឱ្យចូលរួមកម្មវិធីសាលា មិនទាន់ឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងនៅមានចន្លោះទេព្រោះថាសាលាមានកម្មវិធីផ្សេងៗជាច្រើនទៀត តម្រូវឱ្យឪពុកម្តាយមានទំនាក់ទំនងល្អរវាងគ្នាឱ្យបានជាប្រចាំ ដើម្បីលើកកម្ពស់គុណភាពសិក្សារបស់សិស្ស។ផ្អែកតាមលទ្ធផលខាងលើបង្ហាញ ឲ្យឃើញថាសាលាបានផ្តល់ព័ត៌មានទាក់ទងទៅនឹងការសិក្សារបស់សិស្សក្នុងកម្រិតមធ្យម ចំណែកឪពុកម្តាយសិស្សទៅទំនាក់ទំនងសាលាក្នុងកម្រិតទាប ។ ចំពោះការអញ្ជើញឪពុកម្តាយឲចូលរួមកម្មវិធីផ្សេងៗរបស់សាលាក៏ស្ថិតក្នុងកម្រិតទាបដែរ។

### ៤.១.១.៥. កន្លាចំណេះដឹងឪពុកម្តាយ និងធនធានសេដ្ឋកិច្ច



ចំណេះដឹងឪពុកម្ដាយ និងធនធានគ្រួសាររួមចំណែកជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់កូន។ ពិនិត្យមើលសំណួរទី៣ កម្រិតតម្លៃមធ្យមនៃការបញ្ចប់ការសិក្សារបស់ឪពុកម្ដាយសិស្ស (Q3) (Mean= 2.24) បានបង្ហាញថាឪពុកម្ដាយបានបញ្ចប់ការសិក្សាក្នុងកម្រិតទាប ដោយឪពុកម្ដាយ 53.86% បានបញ្ចប់ការសិក្សាខ្ពស់បំផុតត្រឹមកម្រិតអនុវិទ្យាល័យ មានន័យថា ពួកគាត់មិនបានទទួលការអប់រំចំណេះទូទៅមូលដ្ឋាន 9 ឆ្នាំ ឱ្យបានពេញលេញទេ ហើយការបញ្ចប់ការសិក្សានៅអនុវិទ្យាល័យ និងវិទ្យាល័យគឺ 18.75% ដូចគ្នា ចំណែក 27.08% គឺបានបញ្ចប់ការសិក្សាត្រឹមបរិញ្ញាប័ត្រ ។ ពួកគាត់សុទ្ធតែបានចូលរួមចំពោះការសិក្សារបស់កូន មិនថាពួកគាត់បានបញ្ចប់ការសិក្សាកម្រិតណាទេ ប៉ុន្តែទំហំនៃការចូលរួមរបស់ឪពុកម្ដាយនីមួយៗអាស្រ័យទៅលើចំណេះដឹង ពេលវេលា និងកម្រិតជីវភាពផងដែរ។ ជាក់ស្ដែង P(42) (Q.42) បានប្រាប់ឱ្យដឹងថា ៖ " ខ្ញុំមានចំណេះដឹងមានកម្រិតពុំអាចពន្យល់កូនបានគ្រប់ពេល "។ ចំណែកឯ P(39) បានអះអាង " មុខវិជ្ជាខ្លះអត់ចេះ និងអត់យល់ រួចពិបាកពន្យល់កូន"។ ចំណែក P(14) បានលើកឡើងថា " ក្នុងការអប់រំកូន នាងខ្ញុំជួបការលំបាកខ្លះ ព្រោះមិនសូវមានបទពិសោធន៍ "។ បើពិនិត្យទៅលើប្រាក់ចំណូលរបស់ឪពុកម្ដាយដែលបានចូលរួមឆ្លើយសំណួរវិញ គិតជាមធ្យមពួកគាត់ ទទួលប្រាក់កម្រៃប្រហែល 310$ - 400$ ក្នុងមួយខែ ហើយ 39.58% ទទួលបានប្រាក់កម្រៃ ប្រហែល 200$-300$ ហើយ 25% ទទួលបាន310$ - 400$ និង 16.16% ទទួលបាន 410$ - 500$ មានតែ 10.46% នៃឪពុកម្ដាយដែលបានចូលរួមឆ្លើយសំណួរប៉ុណ្ណោះ ដែលទទួលបានប្រាក់កម្រៃចាប់ពី 500$ ឡើង នេះបង្ហាញឱ្យឃើញថាឪពុកម្ដាយភាគច្រើនគាត់មានបញ្ហាប្រឈមក្នុងជីវភាពប្រចាំថ្ងៃ។ បើពិនិត្យទៅលើពេលវេលានៃការបំពេញការងារវិញ ឪពុកម្ដាយភាគច្រើនធ្វើការពេញម៉ោង មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀនកូនទេ ផ្អែកលើ Q(16) (Mean=1.17) ដោយ 64.58% ធ្វើការពេញម៉ោង ហើយមានតែ 8.33% និង 6.25% ប៉ុណ្ណោះដែលធ្វើការក្រៅម៉ោង និងកន្លះថ្ងៃ។ នេះសឱ្យឃើញថា គ្រួសារមិនសូវមានពេលវេលានៅក្នុងការបង្ហាត់បង្រៀនកូន។ ស្របជាមួយគ្នានេះដែរ P(33) បានលើកឡើងថា " ពួកគាត់មិនដែលបានបង្រៀនទេ " ពួកគាត់បានបន្ថែមទៀតថា " ការសិក្សានៅផ្ទះមានការលំបាកណាស់ គណិតវិទ្យា ឪពុកម្ដាយរវល់ធ្វើការ" ។

ចំណែកឯ P(76) បានរៀបរាប់ថា៖ " ម៉ាក់ខ្ញុំមិនដែលបង្រៀនខ្ញុំទេ ព្រោះគាត់រវល់ធ្វើការ" គាត់បានបន្ថែមទៀតថា៖" មិនសូវចេះ ខ្លះមិនយល់ ចង់ឱ្យគេពន្យល់ " រីឯ P(44) បានអះអាងថា៖ " ការសិក្សានៅផ្ទះមានការលំបាកខ្លាំងណាស់ ប៉ាម៉ាក់រវល់ធ្វើការ មិនបានជួយបង្រៀនខ្ញុំ" ។ P(38) បានត្អូញត្អែថា " ការសិក្សានៅផ្ទះ ខ្ញុំគ្មានអ្នកបង្រៀន ខ្ញុំជួបការលំបាក ឪពុកធ្វើការ ម្តាយលក់ដូរ " ។ P(43) បានរៀបរាប់ថា " ការសិក្សានៅផ្ទះជួបការលំបាកខ្លាំងណាស់ព្រោះ ប៉ាម៉ាក់ខ្ញុំមិនសូវបានបង្រៀនខ្ញុំទេ ប៉ាខ្ញុំរវល់ ម៉ាក់ខ្ញុំគាត់មិនចេះ " ។ យោងទៅតាមការអះអាងខាងលើបង្ហាញឱ្យឃើញថា ក្នុងចំណោមឪពុកម្តាយដែលបានចូលរួមបំពេញកម្រងសំណួរ ភាគច្រើនទទួលការអប់រំនៅមានកម្រិត ជាហេតុធ្វើឱ្យគាត់មានការលំបាកក្នុងការចូលរួមការអប់រំរបស់កូន។ ដូច្នេះកត្តាចំណេះដឹងរបស់ឪពុកម្តាយ ធនធានសេដ្ឋកិច្ច និងពេលវេលារបស់ឪពុកម្តាយជះឥទ្ធិពលទៅលើលទ្ធផលសិក្សារបស់កូនដោយជៀសមិនរួចឡើយ។

## ៤.១.២.បញ្ហាប្រឈមក្នុងការចូលរួមរបស់ឪពុកម្តាយ



#### ៤.១.២.១. កម្រិតចំណេះដឹងរបស់ឪពុកម្តាយ




ចំណេះដឹងរបស់ឪពុកម្តាយជះឥទ្ធិពល យ៉ាងខ្លាំងទៅលើលទ្ធផលសិក្សារបស់កូន កាលណាឪពុកម្តាយ មានចំណេះដឹង អាចជួយសម្រួលដល់ដំណើរការរៀនរបស់កូនប្រកបដោយប្រសិទ្ធភាព ផ្ទុយទៅវិញ ចំពោះឪពុកម្តាយដែលទទួលបានការអប់រំទាប អាចមានភាពស្ទាក់ស្ទើរក្នុងការជួយបង្រៀនកូន នាំកូនធ្វើលំហាត់ អាន ឬធ្វើកិច្ចការផ្ទះជាដើម។ បើពិនិត្យមើលសំណួរទី3ដែលបំពេញដោយឪពុកម្តាយកម្រិតមធ្យមនៃការបញ្ចប់ការសិក្សារបស់ឪពុកម្តាយ (Q.3.Pa) (Mean= 2.46) បង្ហាញថាឪពុកម្តាយសិស្សបានបញ្ចប់ការសិក្សាក្នុងកម្រិតទាប ដោយ 35.41% បានបញ្ចប់ការសិក្សាត្រឹមថ្នាក់បឋមសិក្សា និង 18.75% បានបញ្ចប់ការសិក្សាត្រឹមថ្នាក់ អនុវិទ្យាល័យ ផ្អែកតាមតួលេខខាងលើបង្ហាញឱ្យឃើញថា 54.16% នៃឪពុកម្តាយសិស្សដែលបានចូលរួម ឆ្លើយសំណួរ បានបញ្ចប់ការសិក្សារបស់ខ្លួនខ្ពស់បំផុតត្រឹមអនុវិទ្យាល័យ។ នេះជាការប្រឈមដែលពួកគាត់ជួបការលំបាក និងមានភាពស្ទាក់ស្ទើរក្នុងការជួយបង្ហាត់បង្រៀនកូន។ ជាមួយគ្នានេះដែរ P(39) បានត្អូញត្អែរថា៖ "មុខវិជ្ជាខ្លះអត់ចេះ និងអត់យល់ រួចពិបាកពន្យល់កូន " ចំណែកឯ P(30) បានបង្ហើបថា៖ " មេរៀនខុសពីមុន រៀនបានតិចតួច " រីឯ P(42) បានលើកឡើងថា៖ " ខ្ញុំមានចំណេះដឹងមានកម្រិត ពុំអាចពន្យល់កូនបានគ្រប់ពេល " ឯ P(34) បានបង្ហើបថា ៖ " មានការ

លំបាក ដោយសាររៀនបានតិច" ។ ជាមួយគ្នានេះដែរ ក៏មានសិស្សមួយចំនួនបានត្អូញត្អែ អំពីការលំបាកចំពោះការសិក្សានៅផ្ទះ ព្រោះគ្មានអ្នកជួយពន្យល់ ជួយធ្វើកិច្ចការផ្ទះ ព្រោះឪពុកម្តាយមិនសូវចេះ។ ទាំងនេះបង្ហាញឱ្យឃើញថា ចំណេះដឹងរបស់ឪពុកម្តាយជះឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលសិក្សារបស់កូន បើឪពុកម្តាយមានចំណេះដឹងតិចតួច ធ្វើឱ្យគាត់មានភាពស្ទាក់ស្ទើរ ក្នុងការចូលរួមចំណែកជួយធ្វើកិច្ចការផ្ទះ ឬបង្ហាត់បង្រៀនកូន។

## ៤.១.២.២. កត្តាទំនាក់ទំនងរវាងឪពុកម្តាយ និងសាលារៀន

*តារាងទី 5*

| បរិយាយ ( ឪពុកម្តាយ) | មិនដែលសោះ % | ម្ដងម្កាល % | ជាប្រចាំ (%) | ញឹកញាប់ (%) | ញឹកញាប់ណាស់ (%) | មធ្យម | គំលាតស្តង់ដា |
|---|---|---|---|---|---|---|---|
| Q27.ការទៅសាកសួរព័ត៌មានអំពីការសិក្សារបស់កូននៅសាលារៀន | 20.43 | 49.91 | 18.75 | 8.83 | 2.08 | 2.24 | 0.947 |
| Q31.ការអញ្ជើញឪពុកម្តាយចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលា | 27.07 | 56.25 | 4.16 | 6.25 | 2.08 | 2.02 | 0.892 |
| Q.7. ធ្លាប់អញ្ជើញឪពុកម្តាយរបស់សិស្សឱ្យចូលរួមសកម្មភាពផ្សេងៗរបស់សាលា ( នាយក) | 0 | 876 | 12.5 | 0 | 0 | 2.13 | 0.354 |

ពិនិត្យមើលសំណួរទី6 (Q.6.t) (Mean= 2.64) បង្ហាញថាគ្រូតែងតែទំនាក់ទំនងទៅឪពុកម្តាយសសិស្ស ជាប្រចាំទាក់ទងទៅនឹងការសិក្សារបស់សិស្ស ប៉ុន្តែបើយើងពិនិត្តមើលសំណួរទី23 (Q.23.Pa)(Mean= 2.24)បានបង្ហាញឱ្យឃើញថាឪពុកម្តាយសិស្សមកសាកសួរពត៌មានទាក់ទងទៅនឹងការសិក្សារបស់កូនក្នុង កម្រិតទាប ផ្អែកទៅលើសំណួរទី11 ដែលបំពេញដោយលោកគ្រូអ្នកគ្រូ និង Q(12) ដែលបំពេញដោយនាយក នាយិកា លទ្ធផលមានចម្លើយប្រហាក់ប្រហែលគ្នា បានរៀបរាប់អោយដឹងថា ឪពុកម្តាយខ្លះពិបាកក្នុងការ ទំនាក់ទំនង ព្រោះពួកគាត់រវល់ធ្វើការកទទួលទាន ឪពុកម្តាយមួយចំនួនទៀតមិនរវីរវល់នឹងការសិក្សា របស់កូន។ នាយក នាយិកាមួយចំនួនមានការលើកឡើងប្រហាក់ប្រហែលគ្នាដោយ P(3) បានបង្ហាញថា៖ "ឪពុកម្តាយរបស់សិស្សខ្លះមិនរវល់នឹងការសិក្សារបស់កូន មិនជំរុញកូន ពិបាកក្នុងការទំនាក់ទំនងមិនចូលរួមសហការជាមួយគ្រូ" ។ ចំណែកឯ P(7) បានរៀបរាប់ថា៖ " ឪពុកម្តាយមួយចំនួនមិនសូវយកចិត្តទុកដាក់ក្នុងការសិក្សារបស់កូន រវល់លក់ដូ" ចំណែក៖ P(5) បានលើកឡើងថា៖ " ឪពុកម្តាយសិស្សមួយចំនួនមិនមានពេលវេលាគ្រប់គ្រាន់ ឪពុកម្តាយមួយចំនួនទៀតមិនយកចិត្តទុកដាក់ក្នុងការអញ្ជើញចូលរួមកម្មវិធីផ្សេងៗរបស់សាលា"។ ពិនិត្យទៅលើលទ្ធផលខាងលើបង្ហាញឱ្យឃើញថា លោកគ្រូ អ្នកគ្រូព្យាយាមផ្តល់ពត៌មានទាក់ទងទៅនឹងការសិក្សាដល់ឪពុកម្តាយរបស់សិស្សក្នុងកម្រិតមធ្យម ប៉ុន្តែឪពុកម្តាយបានទៅទំនាក់ទំនងជាមួយនឹងសាលា ឬលោកគ្រូ អ្នកគ្រូដើម្បីសាកសួរព័ត៌មាន ទាក់ទងនឹងការសិក្សារបស់កូនក្នុងកម្រិតទាប (Q)(Mean = 2.24) ។ ពិនិត្យមើលសំនួរទី៧(Q7)(Mean = 2.13)ដែលពំពេញដោយនាយក នាយិកាសាលានិងសំណួរទី(Q31)(Mean= 2.08) ដែលបំពេញដោយឪពុកម្តាយសិស្សបានបង្ហាញឲឃើញថាសាលាបានអញ្ជើញឪពុកម្តាយសិស្សចូលរួមក្នុងកម្មវិធីសាលាក្នុងកម្រិតទាប។

### ៤.១.២.៣. កត្តាជីវភាព



*ក្រាហ្វិកទី4 ៖ បង្ហាញពីប្រាក់ចំណូលរបស់ឪពុកម្ដាយ*

ធនធានសេដ្ឋកិច្ចគ្រួសារជាប្រភពដ៏សំខាន់ក្នុងការចូលរួមការផ្ដត់ផ្គង់ការសិក្សារបស់កូនឲ្យមានលក្ខណៈល្អប្រសើរ។ ចំពោះគ្រួសារដែលមានជីវភាពធូធារ អាចផ្ដល់លទ្ធភាពពេញលេញក្នុងការចូលរួមការសិក្សារបស់កូន ផ្ទុយទៅវិញចំពោះគ្រួសារដែលមានជីវភាពខ្វះខាត មានការលំបាកក្នុងកាផ្គត់ផ្គង់ការសិក្សារបស់កូន។ ពិនិត្យមើលសំណួរទី 7 (Q.7. Pa)(Mean= 2.02) បង្ហាញថាកម្រិតមធ្យមនៃប្រាក់ចំណូលប្រចាំខែរបស់ពួកគាត់គឺស្ថិតក្នុងកម្រិតទាប។ពិនិត្យមើលក្រាបខាងលើបង្ហាញឲឃើញថា៤១,៥៣%ទទួលបានប្រាក់ចំណូលប្រចាំខែពួកគាត់ក្នុងចន្លោះពី២០០$ទៅ៣១០$ ក្នុង១ខែ ។ ផ្អែកទៅលើសំណួរបើក (Q.8) បង្ហាញថាឪពុកម្ដាយសិស្សមួយចំនួន មានបញ្ហាប្រឈមនៅក្នុងជីវភាព ដោយពួកគាត់មានការខ្វះខាតលុយកាក់។ ស្របជាមួយគ្នានេះដែរ (P 17) បានលើកឡើងថា ៖ " ខ្វះខាតលុយកាក់ មិនសូវមានពេលនៅផ្ទះ" ។ ទាំងនេះបញ្ជាក់ឱ្យឃើញថាឪពុកម្ដាយចំនួនមានការខ្វល់ខ្វាយខ្លាំងអំពីជីវភាពប្រចាំថ្ងៃ គាត់ប្រឹងប្រែងធ្វើការ ប្រឹងប្រែងប្រកបរបរដើម្បីផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ជាហេតុនាំឱ្យពួកគាត់មិនសូវមានពេលវេលាក្នុងការចូលរួមការសិក្សារបស់កូន។

### ៤.១.២.៤. កត្តាពេលវេលា

ចំពោះឪពុកម្ដាយដែលបានចូលរួមបំពេញកម្រងសំណួរទាំងអស់ ភាគច្រើនជាអាជីវករ និងមន្ត្រីរាជការ ពួកគាត់ភាគច្រើនធ្វើការពេញម៉ោង មិនសូវមានពេលវេលាច្រើន។ ផ្អែកលើ (Q.6.Pa) (Mean= 1.17)បង្ហាញថាឲពុកម្ដាយមានពេលវេលាតិចតួចបំផុតសម្រាប់កូន។ ស្របគ្នានេះដែរ P(22) បានប្រាប់ថា ៖ " មិនសូវមានពេលអប់រំ ព្រោះគាត់រវល់" ។ ចំណែក P(3) បានបង្ហាញថា៖ " ក្នុងការអប់រំកូន មានការលំបាកព្រោះមិនសូវមានពេលវេលាគ្រប់គ្រាន់" ។ បើពិនិត្យមើលសំណួរទី៦ដែលបំពេញដោយសិស្សានុសិស្ស (Q.6.St) (Mena= 2.26) បង្ហាញថា ឪពុកម្ដាយពួគគេមិនសូវមានពេលគ្រប់គ្រាន់ក្នុងការបង្ហាត់បង្រៀនកូន និងជួយធ្វើកិច្ចការផ្ទះកូនទេ។ បើយោងតាមស្រង់មតិរបស់សិស្ស (Q9) បានបង្ហាញឱ្យឃើញថាសិស្សភាគច្រើនមានការលំបាកចំពោះការសិក្សានៅផ្ទះ ព្រោះពួកគាត់គ្មានអ្នកណាជួយបង្រៀន ឪពុកម្ដាយជាប់រវល់ធ្វើ

ការ។ ជាក់ស្តែង P(45) បានរៀបរាប់ថា៖ " ការសិក្សាខ្ញុំមានការលំបាកខ្លាំង ដោយមិនមានអ្នកបង្រៀនម្តាយរវល់ឪពុករវល់" រីឯ P(51) បានលើកឡើងថា៖ "ការសិក្សានៅផ្ទះ ខ្ញុំជួបការលំបាកយ៉ាងខ្លាំង ប៉ា ម៉ាក់ មិនសូវបានបង្រៀន ព្រោះពួកគាត់រវល់" ។ យោងតាមលទ្ធផល និងការស្រង់មតិខាងលើ បង្ហាញឱ្យឃើញថា ឪពុកម្តាយភាគច្រើនមិនសូវមានពេលវេលានៅផ្ទះទេ ពោលគឺពួកគាត់មានការមមារញឹកនឹងការប្រកបរបរទទួលទាន មិនសូវមានពេលវេលាគ្រប់គ្រាន់ ក្នុងការជួយបង្ហាត់បង្រៀនកូន ដូច្នេះហើយ ធ្វើឱ្យកូនមានការលំបាក ចំពោះការសិក្សានៅផ្ទះ។ ផ្អែកតាមលទ្ធផលនៃការសិក្សានេះបង្ហាញឲ្យឃើញថាឪពុកម្តាយសិស្សភាគច្រើនមានភាពមមាញឹកចំពោះការងារឬមុខរបររៀងៗខ្លួនពុំសូវមានពេលទៅទំនាក់ទំនងជាមួយសាលសរៀន មិនសូវមានពេលក្នុងការបង្ហាត់បង្រៀនកូន នាំកូនអានឬ ធ្វើលំហាត់ឡើយ ។

## ៤.១.៣.យុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមក្នុងការសិក្សារបស់កូន

*តារាងទី4៖ បង្ហាញពីយុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយ*

| នាយក | មធ្យម | គំលាតស្តង់ដា |
|---|---|---|
| 4. ការផ្តល់ពត៍មានទាក់ទងទៅនឹងការសិក្សារបស់សិស្សទៅឪពុកម្តាយ | 2.87 | 0.54 |
| 6.ការជំរុញ និងលើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមក្នុងការសិក្សាកូនៗ | 3 | 0 |
| 7. ការអញ្ជើញឪពុកម្តាយរបស់សិស្សឱ្យចូលរួមសកម្មភាពផ្សេងៗរបស់សាលា | 2.13 | 0.35 |
| 8. ការផ្សព្វផ្សាយព័ត៌មានថ្មីស្តីពីកម្មវិធីសិក្សាដល់ឪពុកម្តាយសិស្ស | 2.75 | 0.46 |
| 11. ការយល់ពីការចូលរួមរបស់ឪពុកម្តាយ ចំពោះការសិក្សារបស់កូន (ឪពុកម្តាយ) | 2.83 | 0.54 |
| 12. ការគិតថាការចូលរួមរបស់ឪពុកម្តាយមានសារៈសំខាន់ (ឪពុកម្តាយ) | 2.96 | 0.54 |
| 23 ការ កំណត់ការរំពឹងទុកលទ្ធផលនៃការសិក្សារបស់កូន (ឪពុកម្តាយ) | 2.69 | 0.46 |
| 24. មានបំណងចង់ឱ្យកូនរៀនបានខ្ពស់ (ឪពុកម្តាយ) | 2.5 | 0.14 |
| 6. លោកគ្រូ / អ្នកគ្រូទំនាក់ទំនងទៅឪពុកម្តាយ សិស្សទាក់ទងនឹងការសិក្សារបស់កូនៗពួកគាត់(គ្រូ) | 2.64 | 0.48 |
| 7. លោកគ្រូ / អ្នកគ្រូតែងជំរុញនិង លើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមក្នុងការសិក្សាកូន(គ្រូ) | 2.82 | 0.38 |

ការជំរុញ និងការលើកទឹកចិត្តឪពុកម្តាយតាមរយៈការជំរុញពីខាងក្នុង និងពីខាងក្រៅ។ ការជំរុញ និងលើកទឹកចិត្តពីខាងក្នុង គឺជាកម្លាំងចិត្តចេញពីឆន្ទៈស្មារតីនិងការសង្ឃឹមខ្ពស់ របស់ឪពុកម្តាយដែលជំរុញឱ្យពួកគាត់ចូលរួមការសិក្សារបស់កូន ដោយមានជំនឿ ការរំពឹងទុកខ្ពស់ទៅលើលទ្ធផលសិក្សារបស់កូន ជាពិសេសឪពុកម្តាយឱ្យតម្លៃទៅលើសារៈសំខាន់នៃការសិក្សា និងការអប់រំ។ ចំណែកឯការលើកទឹកចិត្តខាងក្រៅ កើតឡើងដោយការជំរុញពីលោកគ្រូ អ្នកគ្រូ នាយកសាលា តាមរយៈការផ្តល់ពត៌មានត្រលប់ ការអញ្ជើញឪពុកម្តាយឱ្យចូលរួមនៅក្នុងកម្មវិធីផ្សេងៗរបស់សាលា ការផ្តល់ប័ណ្ណសរសើរឬឧបង្វាន់ចំពោះសិស្សពូកែ ជាដើម។ បើពិនិត្យមើលសំណួរទី11 កម្រិតមធ្យម (Q.11.Pa) (Mean= 2.83) បានបង្ហាញថា ឪពុកម្តាយយល់ច្បាស់ពីតួនាទីរបស់ខ្លួនក្នុងការសិក្សារបស់កូនក្នុងកម្រិតមធ្យម និងយល់ច្បាស់ពីសារៈសំខាន់នៃការចូលរួមរបស់ខ្លួនក្នុងកម្រិតមធ្យមដែរ ដោយផ្អែកលើសំណួរទី២៣(Q.23.Pa)(Mean= 2.69) ហើយនៅក្នុងចំណោមនោះដែរ 68.75%យល់ច្បាស់ពីសារៈសំខាន់នៃការចូលរួមរបស់ខ្លួន។ ពិនិត្យមើលQ.24.Pa) (Mean= 2.5)បង្ហាញថាឪពុកម្តាយចង់ឱ្យកូនបន្តការសិក្សាបានខ្ពង់ខ្ពស់ ក្នុងកម្រិតមធ្យម ក្នុងនោះ70.83% ចង់ឱ្យកូនបន្តការសិក្សាបានខ្ពង់ខ្ពស់ ។ ផ្អែកតាមលទ្ធផលខាងលើបង្ហាញឱ្យឃើញថា ឪពុកម្តាយមានការយល់ពីតួនាទីរបស់ខ្លួន និងយល់ពីសារៈសំខាន់នៃការសិក្សា។ ការមានជំនឿចិត្ត និងការរំពឹងខ្ពស់ទៅលើលទ្ធផលសិក្សារបស់កូន ជាហេតុធ្វើឱ្យឪពុកម្តាយមានកម្លាំងចិត្តជំរុញពីខាងក្នុងជួយអប់រំកូន។ ជាមួយគ្នានេះដែរ សាលាក៏បានយកចិត្តទុកដាក់ក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយផងដែរ ដោយបានផ្តល់ពត៌មានទាក់ទងទៅនឹងការសិក្សារបស់សិស្សជាប្រចាំក្នុងកម្រិតមធ្យម(Q.6.t) (Mean=2.64) និង (Q.7.t) (Mean= 2.82)ហើយតែងតែជំរុញគាត់ជាប្រចាំក្នុងកម្រិតមធ្យមដែរ។ យោងតាមសំណួរបើកទី៩ (Q9) អ្នកគ្រូ លោកគ្រូ ភាគច្រើនបានធ្វើការលើកទឹកចិត្តនិងជំរុញឪពុកម្តាយឱ្យចូលរួមក្នុងការសិក្សារបស់កូន ជួយអប់រំកូនបន្ថែម ដើម្បីឱ្យកូនទទួលបានលទ្ធផលកាន់តែប្រសើរ ចំណែកលោកគ្រូអ្នកគ្រូខ្លះបានជំរុញឪពុកម្តាយជួយពិនិត្យតាមដាន កិច្ចការផ្ទះដែលពួកគាត់បានដាក់ឱ្យ អ្នកខ្លះទៀតបានប្រាប់ពីលទ្ធផលសិក្សារបស់សិស្ស ហើយក៏មានមួយចំនួនទៀតសុំឱ្យឪពុកម្តាយធ្វើការ

សហការជាមួយខ្លួន។ ជាមួយគ្នានេះដែរ លោកគ្រូអ្នកគ្រូ ក៏បានធ្វើការប្រឹងប្រែង ជំរុញនិងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមក្នុងការសិក្សារបស់កូន។ចំណែកឯ P(17) បានបង្ហាញថា៖ "ខ្ញុំបានប្រាប់គាត់ពីសារៈសំខាន់និងអត្ថប្រយោជន៍នៃការចូលរួមពីឪពុកម្តាយចំពោះការសិក្សារបស់កូន ជះឥទ្ធិពលល្អដល់អនាគតកូន និងក្រុមគ្រួសាររបស់គាត់ និងជួយពន្យល់ពួកគាត់ឱ្យយល់ពីតម្លៃនៃតួនាទីរបស់គាត់សម្រាប់ការអប់រំកូនៗ" ។ រីឯ P(22)បានបញ្ជាក់ថា "ឱ្យមាតាបិតាសិស្សជួយបង្រៀនកូននៅផ្ទះបន្ថែម អប់រំផ្លូវចិត្តតាមដានការសិក្សាកូនជាប្រចាំ ជួយធ្វើកិច្ចការផ្ទះកូន" ។ រីឯ P(21) បានបង្ហាញថា " សូមឱ្យឪពុកម្តាយសិស្សតាមដានការសិក្សាកូនជាប្រចាំ ឧស្សាហ៍នាំកូនអាន និងជួយពន្យល់កូនរាល់ពេលដែលធ្វើកិច្ចការផ្ទះ"។ P(20)បានរៀបរាប់ថា " ពិនិត្យមើលសៀវភៅកិច្ចការដែលគ្រូដាក់ជាប្រចាំ ណែនាំគាត់ឱ្យបង្រៀនកូននៅផ្ទះបន្ថែម ចូលរួមពន្យល់កូនរាល់កិច្ចការដែលគ្រូដាក់ឱ្យ" ។ ចំណែកឯនាយកនាយិកានៃសាលាទាំងប្រាំបី ក៏បានចូលរូមជំរុញ និងលើកទឹកចិត្តឪពុកម្តាយឱ្យចូលរួមការសិក្សារបស់កូនដែរ (Q.6.D) (Mean= 3) បង្ហាញថាពួកគាត់បានលើកទឹកចិត្តឪពុកម្តាយជាប្រចាំក្នុងកម្រិតមធ្យម។ លើសពីនេះមាន 12.5% បានអញ្ជើញឪពុកម្តាយសិស្សឱ្យចូលរួមសកម្មភាពរបស់សាលាជាប្រចាំ រួមមានកម្មវិធីបើកបវេសនកាល បុណ្យផ្កា ទិវាកុមារ១ មិថុនា ជំនួបមាតាបិតាសិស្ស។ក្រៅពីនេះ នាយក នាយិកាសាលាក៏បានផ្សព្វផ្សាយព័ត៌មានថ្មីៗ ស្តីពីកម្មវិធិសិក្សាដល់ឪពុកម្តាយសិស្សជាប្រចាំក្នុងកម្រិតមធ្យមផងដែរ (Q.8.D) (Mean=2.75) ផ្អែកលើសំណួរបើក (Q.10.D) ក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយនាយកនាយិកាមានវិធីសាស្រ្តខុសៗគ្នា ចំពោះP(6) បានប្រាប់ថា " ផ្តល់ប័ណ្ណសរសើរ លិខិតសរសើរ រង្វាន់សម្ភារៈដល់សិស្សដែលរៀនពូកែឬមានស្នាដៃល្អ" ។ ឯ P(4) បានរៀបរាប់ថា៖ " ខ្ញុំបានជំរុញឪពុកម្តាយសិស្ស គឺបានប្រាប់ពួកគាត់ ធ្វើយ៉ាងណាជួយដាស់តឿនកូនឱ្យខិតខំរៀន ឱ្យកូនមករៀនទៀងទាត់" ចំណែក P(2) បានបង្ហាញថា" ក្នុងកម្មវិធីប្រជុំជាមួយអាជ្ញាធរ ផ្សព្វផ្សាយតាមអាជ្ញាធរ ភូមិ សង្កាត់ ជំរុញទំនាក់ទំនងផ្ទាល់ ជូនលិខិតសរសើរពីលទ្ធផលដំណាច់ឆ្នាំ" ចំណែកឯ P(3) បានលើកឡើងថា "ជួយពង្រឹងគុណភាពអប់រំឱ្យមានប្រសិទ្ធភាព កាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ការសិក្សា" ស្របគ្នានេះ

ដែរ P(8) បានបង្ហាញថា " សុំឱ្យអាណាព្យាបាលជួយជំរុញកូនចៅខខិតខំរៀន និងឱ្យតម្លៃការសិក្សា ជំរុញ និងណែនាំកូនចៅរបស់គាត់ កាត់បន្ថយការលេងទូរសព្ទ័ មើលទូរទស្សន៍" ។ ផ្អែកលើសំណួរទី11 Q(11) នាយក នាយិកាទាំងប្រាំបីសាលា បង្ហាញពីវិធីសាស្ត្រដែលពួកគាត់ប្រើទទួលបានលទ្ធផលពី 65% - 70% ព្រោះឪពុកម្តាយយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូនជាងមុន និងលទ្ធផលសិក្សារបស់សិស្សបានប្រសើរជាងមុន។ ទទឹមគ្នានេះដែរ ផ្អែកលើសំណួរទី10 (Q.10.t) លោកគ្រូ អ្នកគ្រូភាគច្រើនបានលើកឡើងថាការប្រើវិធីសាស្ត្រដើម្បីជំរុញ និងលើកទឹកចិត្តឪពុកម្តាយរបស់លោកគ្រូ អ្នកគ្រូទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់ ស្តែងឱ្យឃើញតាមរយៈលទ្ធផលសិក្សាសិស្សល្អជាងមុន ឪពុកម្តាយខ្លះតែងជួយសហការជាមួយគ្រូ និងយកចិត្តទុកដាក់ចំពោះការសិក្សារបស់កូនជាងមុន។ ចំណែកឯលោកគ្រូ អ្នកគ្រូមួយចំនួនទៀត បានលើកឡើងថាឪពុកម្តាយចំនួនទៀតកាន់តែយល់ពីតួនាទីរបស់ខ្លួនកាន់តែខ្លាំងឡើង ដោយមិនផ្អែកទាំងស្រុងទៅលើគ្រូទៀតទេ។ P(23) បានអះអាងថា៖ " បានទទួលលទ្ធផល ព្រោះគ្រូ និងឪពុកម្តាយតែងតែមានទំនាក់ទំនងគ្នាជានិច្ច ពីការសិក្សារបស់កូន"។ P(20) បានរៀបរាប់ថា " វិធីសាស្ត្រដែលប្រើទទួលផល ព្រោះរាល់កិច្ចការដែលដាក់ឱ្យ គឺសិស្សបានធ្វើស្ទើរតែគ្រប់គ្នា ហើយសិស្សទាំងនោះបានពិន្ទុច្រើនមុន" ។ ផ្អែកតាមលទ្ធផលខាងលើបង្ហាញឱ្យឃើញថា ឪពុកម្តាយយល់ច្បាស់ពីតួនាទីរបស់ខ្លួន និងសារៈសំខាន់នៃការសិក្សា មានរំពឹងខ្ពស់ទៅលើលទ្ធផលនៃការសិក្សារបស់កូន ដោយមានជំនឿថាការចូលរួមរបស់ពួកគាត់ជះឥទ្ធិពលជាវិជ្ជមានទៅលើលទ្ធផលសិក្សារបស់កូនៗ។ ស្របជាមួយគ្នានេះ ដែរសាលារៀនក៏បានយកចិត្តទុកដាក់ខ្ពស់ ក្នុងការចូលរួមធ្វើការជំរុញ និងលើកទឹកចិត្តខ្ពស់ ដល់ឪពុកម្តាយ ឱ្យចូលរួមការអប់រំរបស់កូន។

## ៤.២. ការពិភាក្សា

នៅចំណុចនេះអ្នកស្រាវជ្រាវធ្វើការពិភាក្សាផ្តោតទៅលើបីចំណុចធំៗរួមមាន ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន និងយុទ្ធសាស្ត្រក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឲចូលរួមចំពោះការសិក្សារបស់កូន។

## ៤.២.១. ដំណើរការនៃការចូលរួមរបស់ឪពុកម្ដាយចំពោះការអប់រំកូន

### ៤.២.១.១. ការចូលរួមជួយធ្វើកិច្ចការផ្ទះរបស់កូន

ការចូលរួមធ្វើកិច្ចការផ្ទះរបស់កូនជាប្រចាំរបស់ឪពុកម្ដាយនៅរាជធានីភ្នំពេញក្នុងកម្រិតមធ្យម ផ្អែកលើ(Q16) ( Mean = 2.77)និងផ្អែកលើ (Q 5. Stu) (Mean= 2.67) ។តាមការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថាកិច្ចការដែលលោកគ្រូដាក់ឲ្យសិស្សធ្វើមានសារៈសំខាន់ណាស់នៅក្នុងដំណើរការរៀន និងបង្រៀនធ្វើឲ្យសិស្សស្វែងយល់មេរៀនកាន់តែស៊ីជម្រៅ ពង្រឹងចំណេះដឹង ជំនាញនិងបទពិសោធន៍ផ្ទៃរបស់សិស្សនៅក្នុងការរៀន មានភាពម្ចាស់ការនិងទំនួលខុសត្រូវជាពិសេសធ្វើឲសិស្សមានសមត្ថភាពចាប់បានបញ្ញតិថ្មីៗផ្អែកលើសំណួរបើក (Q8 & Q9.St) ចំពោះសិស្សដែលទទួលបានការចូលរួមជួយកិច្ចការសាលាពីឪពុកម្ដាយធ្វើឱ្យពួកគេ មានភាពងាយស្រួលក្នុងការសិក្សានៅផ្ទះ ធ្វើឱ្យគេមានភាពច្បាស់លាស់នូវអ្វីដែលពួកគេមិនយល់នៅសាលា ធ្វើឱ្យពួកគេមានការប្រឹងប្រែងរៀនសូត្រ និងលើកកម្ពស់លទ្ធផលសិក្សារបស់ពួកគេឱ្យកាន់តែប្រសើរឡើង។ ស្របនឹងការស្ទង់មតិនេះលើកាសិក្សាមួយចំនួន ពីវិស័យសកលបានបង្ហាញថា ក្នុងចំណោមចំនួននៃការចូលរួមរបស់ឪពុកម្ដាយក្នុងការធ្វើកិច្ចការផ្ទះ ធ្វើឱ្យសិស្សទាំងនោះទទួលបានជោគជ័យ (Huang 2006, Hoover Demsey & Sandler 1999, Teverstein 2000)។ ទោះបីជាយ៉ាងនេះក្ដីមានឪពុកម្ដាយមួយចំនួន មិនបានយកចិត្តទុកដាក់ មិនបានចូលរួមធ្វើកិច្ចការសាលារបស់កូន ដោយហេតុថាឪពុកម្ដាយខ្លះ ពុំសូវមានពេលវេលាគ្រប់គ្រាន់ អ្នកខ្លះទៀតពុំបានទៅទំនាក់ទំនងជាមួយគ្រូ ដូចនេះបើទោះបីជាគ្រូដាក់កិច្ចការផ្ទះឬអត់ក៏ពួកគាត់មិនដឹង ចំណែកឯឪពុកម្ដាយខ្លះទៀតទទួលបានការអប់រំតិចតួច ជាហេតុធ្វើឱ្យពួកគាត់មានការលំបាក និងមានភាពស្ទាក់ស្ទើរក្នុងការជួយពន្យល់ និងពិនិត្យទៅលើកិច្ចការផ្ទះរបស់កូន។ ។ បើទោះបីជាយ៉ាងណាក៏ដោយចំពោះឪពុកម្ដាយ ដែលមិនបានចូលរួមក្នុងកិច្ចការផ្ទះ កូនៗរបស់ពួកគេ គួរតែបញ្ជ្រាបពត៌មានទាំងនេះ ចំណែកអ្នកដែលបានចូលរួមត្រូវបានលើកទឹកចិត្តឱ្យធ្វើបន្ត (Echoune, 2015)។

### ៤.២.១.២. ការបង្ហាត់បង្រៀន និងត្រួតពិនិត្យតាមដាន

ចំពោះការចូលរួមជួយបង្ហាត់បង្រៀនកូនរបស់ឪពុកម្តាយនៅសាលាបឋមសិក្សាក្នុងរាជធានីភ្នំពេញ ផ្អែកទៅលើ ( Q.17 Pa ) ( Mean= 2.70 ) បានបង្ហាញថាឪពុកម្តាយបានជួយបង្ហាត់បង្រៀន ក្នុងកម្រិតមធ្យម ហើយមានតែឪពុកម្តាយ 14.58% ប៉ុណ្ណោះទេដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀនកូនញឹកញាប់ ហើយមានតែ 4.16% ប៉ុណ្ណោះដែលបានបង្រៀនកូនញឹកញាប់បំផុត និងមានតែ 33.33% ប៉ុណ្ណោះដែលនាំកូនធ្វើលំហាត់ ឬអានជាប្រចាំ។ ទាំងនេះបង្ហាញឱ្យឃើញថាការចូលរួមរបស់ឪពុកម្តាយនៅមានកម្រិតនៅឡើយ។ ឪពុកម្តាយខ្លះមិនសូវអើពើរនឹងការរៀនសូត្ររបស់កូន ចំណែកអ្នកខ្លះទៀតមិនមានពេលវេលាគ្រប់គ្រាន់ ហើយក៏មានឪពុកម្តាយមួយចំនួនទៀតពិបាកក្នុងការបង្រៀនកូនដោយសារគាត់ទទួលបានការអប់រំតិចតួច។ ចំពោះសិស្សដែលឪពុកម្តាយបានបង្ហាត់បង្រៀនកូនជាប្រចាំ បានអះអាងថាកូនពួកគាត់ទទួលលទ្ធផលសិក្សាល្អជាងមុន ចំណែកឯអ្នកខ្លះទៀតបានប្រាប់ថា ធ្វើលំហាត់បានត្រូវច្រើនជាងមុន ប្រឹងប្រែងរៀនសូត្រជាងមុន ដោយសារមានការចូលរួមពីឪពុកម្តាយ។ ផ្អែកលើ (Q13) ( Mean= 2.79 ) បានបង្ហាញថាលទ្ធផលសិក្សាកូនរបស់ពួកគាត់ល្អបង្គួរក្នុងកម្រិតមធ្យម។ នេះសបញ្ជាក់ឲ្យឃើញថា សិស្សដែលមានឪពុកម្តាយជួយបង្ហាត់បង្រៀនធ្វើឲការសិក្សារបស់ពួកគេទទួលបានលទ្ធផលល្អបង្គួរនិងធ្វើឲគួកគេមានចំណេះដឹងមូលដ្ឋានរឹងមាំជាពិសេសផ្នែកអំណាន ភាសាខ្មែរ គណិតវិទ្យា ។ល។ ស្របនឹងការស្រាវជ្រាវរបស់លោក Ball and Blachman, 1991; Izzo et al 1999 ដែលបានរកឃើញថាឪពុកម្តាយដែលបានអានឱ្យកូនស្តាប់ នាំកូនអាន បង្ហាត់បង្រៀនកូន ដោយប្រើធនធានដែលផ្តល់ដោយគ្រូនាំឱ្យកុមារធ្វើបានល្អ នៅសាលាជាងកុមារដែលឪពុកម្តាយមិនបាននាំកូនរៀន។ ចំណែកឯការត្រួតពិនិត្យតាមដានការសិក្សារបស់កូនវិញ ឪពុកម្តាយបានយកចិត្តទុដាក់ត្រួតពិនិត្យសៀវភៅតាមដានប្រចាំ ក្នុងកម្រិតមធ្យម (Q. 14 Pa)( Mean= 3.02)នេះបង្ហាញឲឃើញថាឪពុកម្តាយយកចិត្តទុកដាក់ត្រួតពិនិត្យតាមដានទៅលើលទ្ធផលការសិក្សារបស់កូន ខ្លាចក្រែងកូនមិនចូលសាលា ក្រែងកូនមិនយកចិត្តទុកដាក់រៀននៅក្នុងថ្នាក់ ប៉ុន្តែចំពោះការពិនិត្យសៀវភៅសរសេររបស់កូន មិនសូវជាបានដិតដល់ប៉ុន្មានទេ តាមពិតការពិនិត្យសៀវភៅសរសេររបស់កូនបានទៀងទាត់ជារៀងរាល់ថ្ងៃគឺមានសារៈសំខាន់ណាស់ ធ្វើឲ្យកូនមាន

ការប្រុងប្រយ័ត្នខ្ពស់ចំពោះសកម្មភាពសិក្សាក្នុងថ្នាក់ព្រោះថាសិស្សខ្លះអាងថាឪពុកម្តាយធ្វេសប្រហែសនាំឲពួកគាត់ខ្ជីខ្ជារទៅតាមហ្នឹងដែរ។ លើសពីនេះឪពុកម្តាយភាគច្រើនបានចូលរួមទូន្មានអប់រំកូន និងប្រាប់ពីសារៈសំខាន់នៃការសិក្សាដល់កូនតាមដែលពួកគាត់ទទួលបានពីក្រុមគ្រួសារពួកគេតៗមក។ ជាមួយគ្នានេះដែរឪពុកម្តាយមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការប្រើប្រាស់ទូសព្ទ័របស់កូនដោយមានការកំណត់ពេលវេលាជាក់លាក់ផងដែរ។ ស្របតាមលទ្ធផលស្រាវជ្រាវរបស់លោក (Douglas Fisher and Nancy Frey, 2014)បានបង្ហាញថា ការពិនិត្យតាមដានទៅលើការសិក្សាគឺជាជំហានសំខាន់មួយនៅក្នុងដំណើរការរៀន និងការបង្រៀន។ ការពិនិត្យមើលកំហុស និងការយល់ច្រឡំរបស់សិស្ស រួចធ្វើការផ្តល់មតិយោបល់ ត្រឡប់ បន្ទាប់មករៀបចំផែនការបង្រៀន ដោយផ្អែកលើកំហុសឆ្គង និងចំណុចខ្វះខាតទាំងនោះ។

### ៤.២.១.៣. ការជំរុញ និងការលើកទឹកចិត្ត

ការជំរុញនិងលើកទឹកចិត្តជះឥទ្ធិពលយ៉ាងខ្លាំងដល់ដំណើរការរៀននិងបង្រៀនប្រកបដោយប្រសិទ្ធិភាព។ការសិក្សានេះបង្ហាញឲ្យឃើញថាមិនថាឪពុកម្តាយមានឬក្រទេ ភាគច្រើនតែងតែធ្វើការជំរុញ និងលើកទឹកចិត្តកូនឱ្យខិតចំរៀនសូត្រ ហើយឪពុកម្តាយភាគច្រើនបានរំពឹងទុកលទ្ធផលនៃការសិក្សារបស់កូនខ្ពស់ និងចង់ឱ្យកូនបន្តការសិក្សាបានវែងឆ្ងាយផងដែរ លើសពីនេះទៀតពួកគាត់បានបង្ហាញពីសារៈសំខាន់នៃការសិក្សាដល់កូនជាប្រចាំ និងព្រមទាំងធ្វើការលើកទ្ទឹកចិត្តដោយពោលពាក្យសរសើរ ឱ្យរង្វាន់ដល់កូន។ យោងតាមលោក (Safdar Rehman Ghazi, 2010)ឪពុកម្តាយធ្វើការលើកទឹកចិត្តកូនដោយប្រើវិធីសាស្រ្តដូចជា ការប្រាប់ពីសារៈសំខាន់នៃការសិក្សាដល់កូនសរសើកូននៅពេលដែលគេធ្វើអ្វីបានល្អប្រសើរ ផ្តល់ជារង្វាន់ ធ្វើជាគំរូដល់កូន ផ្តល់ឳកាសដល់កូនមានភាពម្ចាស់ការ និងផ្តល់ក្តីស្រលាញ់ដល់ពួកគេ។ ជាមួយគ្នានេះដែរចំពោះក្រុមសិស្សដែលទទួលបានការជំរុញនិងលើកតឹកចិត្តពីឪពុកម្តាយឬលោកគ្រូ អ្នកគ្រូ មានការអភិវឌ្ឍផ្នែកសមត្ថភាពនិងទទួលបានពិន្ទុខ្ពស់ជាងក្រុមសិស្សដែលមិនបានលើកតឹកចិត្ត។ (IOSR Journal of Humanities and Social Science , Volume 7 , 2013) ។ ទាំងនេះបង្ហាញឲ្យឃើញថាឪពុកម្តាយនៅទីក្រុងភ្នំពេញស្រលាញ់ការអប់រំ ឱ្យតម្លៃខ្ពស់ទៅលើការអប់រំរបស់កូនចៅ និងយក

ចិត្តទុកដាក់ខ្ពស់ក្នុងការជំរុញ និងលើកទឹកចិត្តកូន តាមលទ្ធភាពដែលអាចធ្វើទៅបាន មិនថាផ្នែកស្មារតី និងសម្ភារៈដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់កូននិងគុណភាពអប់រំឲ្យកាន់តែប្រសើរឡើង។

### ៤.២.១.៤. ការទំនាក់ទំនងរវាងគ្រួសារ និងសាលារៀន

ឪពុកម្តាយមានសិទ្ធិនិងករណីយកិច្ចដូចជា ...សិទ្ធិទទួលបាន ព័ត៌មាននិងរបាយការណ៍នៃការសិក្សាពីគ្រឹស្ថានសិក្សារបស់កូន ...។ ខិតខំឲ្យអស់លទ្ធភាពដើម្បីគាំទ្រការសិក្សារបស់កូន ជាពិសេសចំពោះការអប់រំនៅកម្រិតមូលដ្ឋាន យកចិត្តទុកដាក់ផ្សព្វភ្ជាប់សាលា គ្រួសារ និងសហគមន៍ ដើម្បីចូលរួមជួយបណ្តុះបណ្តាល និងកែលម្អបរិស្ថានសិក្សា (រដ្ឋាភិបាល, ២០០៧)។ ផ្អែកលើ (Q 27. Pa) ( Mean= 2.24) បង្ហាញឱ្យឃើញថាការទៅសាកសួរពត៌មាននៅសាលាទាក់ទងទៅនឹងការសិក្សារបស់កូនស្ថិតក្នុងកម្រិតទាបនៅឡើយទេ ហើយមានតែឪពុកម្តាយមួយចំនួនតូចប៉ុណ្ណោះដែលបានទៅទំនងទំនងជាមួយសាលា ចំណែកឯឪពុកម្តាយមួយចំនួនធំទៀត មិនដែលទៅទំនាក់ទំនងសាលាទេ។ ទាំងនេះមកពីពួកគាត់មានភាពមមារញឹកនឹងការប្រកបរបរចិញ្ចឹមជីវិត រីឯពួកគាត់មួយចំនួនទៀតធ្វើការពេញម៉ោង គ្មានពេលក្នុងការទំនាក់ទំនងជាមួយសាលា ឬ លោកគ្រូអ្នកគ្រូ ហើយក៏មានឪពុកម្តាយមួយចំនួនទៀតដែរ ដែលមិនខ្វល់ខ្វាយពីការចូលរួមការសិក្សារបស់កូន។ ចំពោះឪពុកម្តាយដែលមិនបានទៅទំនាក់ទំនងជាមួយសាលាឬលោកគ្រូ អ្នកគ្រូ ធ្វើឱ្យពួកគាត់កង្វះពត៌មានស្តីពីការសិក្សារបស់កូន ពិបាកក្នុងការជួយបង្ហាត់បង្រៀនកូន ពិបាកជួយធ្វើកិច្ចការផ្ទះរបស់កូន មិនបានដឹងពីសកម្មភាពរបស់កូននៅឯសាលារៀនឡើយ ។ ការទៅទំនាក់ទំនងនៅសាលាក៏ជាផ្នែកមួយនៃការពិនិត្យតាមដានការសិក្សារបស់កូនដែរ ផ្ទុយមកវិញបើឪពុកម្តាយខ្វះការទំនាក់ទំនងជាមួយសាលា ជាហេតុធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សារបស់កូនផងដែរ។ ប៉ុន្តែបើផ្អែកទៅលើ (Q5.D)(Mean=2.5) បានបង្ហាញថាសាលាតែងតែផ្តល់ពត៌មានទៅឪពុកម្តាយទាក់ទង ទៅនឹងការសិក្សារបស់កូនពួកគាត់ជាប្រចាំក្នុងកម្រិតមធ្យម។ បើពិនិត្យមើលទៅលើសំណួរទី27 និង 28 តម្លៃមធ្យមនៃការទៅសាកសួរព័ត៌មានរបស់ឪពុកម្តាយតូចជាងតម្លៃមធ្យមនៃការផ្តល់ពត៌មានពីការសិក្សារបស់សិស្សទៅឪពុកម្តាយវិញនេះបញ្ជាក់ឱ្យឃើញថា ឪពុកម្តាយភាគច្រើនមិនសូវ

បានទៅសាកសួរពត៌មានស្តីពីការសិក្សារបស់កូនទេ ប៉ុន្តែពួកគាត់ចាំទទួលពត៌មានត្រឡប់ពីសាលាវិញ។ ចំណោកឯការអញ្ជើញឪពុកម្តាយឲ្យចូលរួមនៅក្នុងកម្មវិធីសាលាវិញគឺមិនទាន់មានភាពពេញលេញតាមគោលការរបស់ក្រសួងអប់រំ ឡើយ។ ផ្អែកលើ(Q 31 Pa)( Mean= 2.08) បានបង្ហាញឱ្យ ឃើញថាឪពុកម្តាយទទួលបានការអញ្ជើញឱ្យចូលរួមចំពោះសកម្មភាពផ្សេងៗរបស់សាលាស្ថិតនៅកម្រិតទាបនៅឡើយ។សាលាភាគច្រើនអញ្ជើញឪពុកម្តាយឱ្យចូលរួមតែក្នុងកម្មវិធីបើកបវេសនកាល បុណ្យផ្កា និង១ មិថុនាទិវាកុមារអន្តជាតិតែប៉ុណ្ណោះ។ ដូចនេះការអញ្ជើញឪពុកម្តាយចូលរួមកម្មវិធីសាលាមិនទាន់ឆ្លើយតបទៅតាមតម្រូវការជាក់ស្តែងទេ ព្រោះថាសាលាមានកម្មវិធីជាច្រើនទៀត ដែលតម្រូវឱ្យឪពុកម្តាយ និងសាលារៀនមានទំនាក់ទំនងល្អរវាងគ្នាប្រសើរជាងនេះ។ នៅត្រង់ចំណុចនេះបើតាមការសង្កេតតាមភាពជាក់ស្តែងសាលានិងឪពុកម្តាយមិនបានសហការគ្នាបានល្អទេ ជួនសាលាធ្វើការអញ្ជើញពួកគាត់ តែពួកគាត់មិនបានចូលរួម ពេលខ្លះសាលាមិនសូវយកចិត្តទុកដាក់ទៅលើបញ្ហានេះ ចេះតែធ្វើឲ្យតែបង្គ្រប់កិច្ចទៅ។ ដូចនេះដើម្បីជួយសម្រួលដល់ការចូលរួមចំពោះឪពុកម្តាយ សាលារៀនគួរធ្វើការគាំទ្រ អន្តរាគមន៍ និងផ្តល់ពត៌មានទាន់ពេលវេលាទាក់ទងទៅនឹងការសិក្សា ឥរិយាបថរបស់សិស្ស និងអញ្ជើញឪពុកម្តាយឲ្យចូលរួមក្នុងកម្មវិធីសាលា។ ក្រុមគ្រួសារ និងសាលារៀនធ្វើការសហការជាដៃគូរក្នុងការអប់រំកុមារ និងយុវជន (A guide for school and families) ។

### ៤.២.១.៥. កត្តាចំណេះដឹងរបស់ឪពុកម្តាយនិងធនធានសេដ្ឋកិច្ចគ្រួសារ

យោងតាមលទ្ធផលនៃការសិក្សានេះបង្ហាញឱ្យឃើញថា កម្រិតនៃការបញ្ចប់ការសិក្សារបស់ឪពុកម្តាយសិស្សស្ថិតនៅកម្រិតទាបនៅឡើយ ផ្អែកលើ (Q3Pa)( Mean= 2.24) ឪពុកម្តាយ 54,19% បានបញ្ចប់ការសិក្សាខ្ពស់បំផុតត្រឹមកម្រិតអនុវិទ្យាល័យ ក្នុងនោះមានតែ 35,44% បានបញ្ចប់ការសិក្សាត្រឹមកម្រិតបឋមសិក្សា ពួកគាត់មិនបានទទួលការអប់រំចំណោះទូទៅមូលដ្ឋាន៩ ឆ្នាំឱ្យបានពេញលេញទេ។ នេះជាមូលហេតុដែលធ្វើឱ្យពួកគាត់មានការលំបាកក្នុងការបង្ហាត់បង្រៀន និងជួយធ្វើកិច្ចការផ្ទះកូន។ឪពុកម្តាយភាគច្រើនបង្ហាញពីសមត្ថភាពខ្លួនឯងនៅមានកម្រិតទាក់ទងទៅនឹងការចូលរួមចំពោះការអប់រំកូន។

ចំពោះការអប់រំកូន ពួកគាត់មានអារម្មណ៍អៀនខ្មាស់ដោយមានចំណេះដឹង ជំនាញមិនគ្រប់គ្រាន់ក្នុងការចូលរួម (Yi, 2018)។ សិស្សមួយចំនួនបានត្អូញត្អែ និងប្រាប់ពីការលំបាករបស់ខ្លួនចំពោះការសិក្សានៅផ្ទះគ្មានអ្នកជួយ ឪពុកម្តាយមិនសូវចេះ។ ចំណែកឪពុកម្តាយខ្លះទៀតបញ្ចប់ការសិក្សាថ្នាក់ខ្ពស់ តែពួកគាត់ភ្លេច ឬកម្មវិធីសិក្សាខុសពីមុនធ្វើឱ្យពួកគាត់មានភាពស្រពិចស្រពិលក្នុងការចូលរួមចំពោះការបង្ហាត់បង្រៀនកូន។ឪពុកម្តាយខ្លះយល់ថា កម្មវិធីសិក្សាបច្ចុប្បន្នមានលក្ខណៈខុសគ្នាពីកម្មវិធីសិក្សាដែលពួកគាត់បានរៀន ដូច្នេះពួកគាត់មិនយល់ស (Sophoat , 2011 ) ។ ឪពុកម្តាយភាគច្រើនបង្ហាញពីសមត្ថភាពខ្លួនឯងនៅមានកម្រិតទាក់ទងទៅនឹងការចូលរួមចំពោះការអប់រំកូន។ រវាងកម្រិតអប់រំរបស់ឪពុកម្តាយ និងកម្រិតចំណូលគ្រួសារមានទំនាក់ទំនងរវាងគ្នាផងដែរ។ យោងតាមមជ្ឈមណ្ឌលជាតិសម្រាប់កុមារក្រីក្រ ឪពុកម្តាយដែលមានការអប់រំទាប គ្រួសារនិងមានប្រាក់ចំណូលទាប។ ហើយការសិក្សាផ្សេងទៀតបង្ហាញឱ្យឃើញថា ស្ថានភាពសេដ្ឋកិច្ចសង្គមទាបអាចប៉ះពាល់អន្តរគ្រួសារ និងនាំយកបញ្ហាអាកប្បកិរិយាដែលអាចជះឥទ្ធិពលដល់ការសិក្សានិងការអភិវឌ្ឍរបស់កុមារ (UNIVERSITY LAMAR, 2019)។

### ៤.២.២.បញ្ហាប្រឈមដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយ

ការសិក្សានេះបានរកឃើញនូវបញ្ហាប្រឈមដែលរាំងស្ទះដល់ដំណើរការនៃការចូលរួមរបស់ឪពុកម្តាយរួមមានដូចជា កត្តាកង្វះខាតចំណេះដឹងរបស់ឪពុកម្តាយ កត្តាជីវភាពគ្រួសារ។ឪពុកម្តាយដែលមិនបានចូលរួមការសិក្សារបស់កូនដោយសារតែមានជីវភាពលំបាក ការមិនឱ្យតម្លៃទៅលើការសិក្សារបស់កូន ចំណេះដឹងឪពុកម្តាយមិនគ្រប់គ្រាន់។ ឪពុកម្តាយដែលមានជីវភាពធូរធារនិងចំណេះដឹងចូលរួមអប់រំកូនជាងឪពុកម្តាយដែលមានជីវភាពខ្វះខាត((Sokhea, 2013 ; Yi, 2018)។ កង្វះទំនាក់ទំនងជាមួយសាលារៀន ឬលោកគ្រូអ្នកគ្រូ កង្វះពេលវេលា។ ឪពុកម្តាយខ្លះពុំមានពេលគ្រប់គ្រាន់ក្នុងការចូលរួមការសិក្សារបស់កូនពួកគាត់ជាប់រវល់មុខរបរឬការងារ( Sophot, 2011) (Sophondarith ,2012) (Sokhea, 2013)។

### ៤.២.៣.យុទ្ធសាស្ត្រក្នុងការជំរុញនិងលើកទឹកចិត្តឪពុកម្ដាយក្នុងការចូលរួមការអប់រំកូន

ការជំរុញ និងលើកទឹកចិត្តឪពុកម្ដាយក្នុងការចូលរួមចំពោះការអប់រំកូន ផ្ដោតទៅលើបីចំណុចសំខាន់ទីកត្តាជំរុញ និងលើកទិកចិត្តពីកត្តាខាងក្នុង ដោយឪពុកម្ដាយមានការរំពឹងទុកខ្ពស់ទៅលើការសិក្សារបស់កូន និងមានបំណងចង់ឱ្យកូនរៀនបានខ្ពស់ ។ ជាងនេះទៅទៀតយល់ពីសារៈសំខាន់នៃការចូលរួមរបស់ខ្លួនចំពោះការសិក្សារបស់កូន ថែមទាំងបានពន្យល់ពីសារៈសំខាន់នៃការសិក្សាដល់កូនផងដែរ។ ទាំងនេះបញ្ជាក់ឱ្យឃើញថា ឪពុកម្ដាយមានឆន្ទៈការចូលរួមអប់រំកូន បើទោះបីជាពេលខ្លះឪពុកម្ដាយ មិនសូវមានពេលវេលាគ្រប់គ្រាន់ មានការលំបាកក្នុងជីវភាព ឬក៏ខ្វះខាតចំណេះដឹក៏ដោយ។ ទី២ កត្តាធ្វើការជំរុញ និងលើកទិកចិត្តលោកគ្រូ អ្នកគ្រូ តាមការសិក្សានេះបង្ហាញឱ្យឃើញថា លោកគ្រូអ្នកគ្រូនិងសាលាបានផ្ដល់ការជំរុញ និងលើកទឹកចិត្តឪពុកម្ដាយឲ្យចូលរួមចំពោះការអប់រំក្នុងកម្រិតមធ្យមផងដែរ។

# ជំពូកទី៥៖ សន្និដ្ឋាន និងសំណូមពរ

## ៥.១. សន្និដ្ឋាន

ការចូលរួមរបស់ឪពុកម្តាយ ចំពោះការសិក្សារបស់កូន មានភាពចាំបាច់ខ្លាំងណាស់ ព្រោះវាជាតួនាទី និងកាតព្វកិច្ចរបស់ឪពុកម្តាយដើម្បីលើកកម្ពស់ការសិក្សារបស់កូន ឱ្យទទួលបានជោគជ័យ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការចូលរួមចំពោះការសិក្សារបស់កូននៅកម្រិតបឋមសិក្សានៅរាជធានីភ្នំពេញស្ថិតក្នុងកម្រិតមធ្យមនៅឡើយទេ។ ផ្អែកទៅលើលទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញឱ្យឃើញថា នៅក្នុងដំណើរការនៃការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូនមិនទាន់បានគ្រប់ជ្រុងជ្រោយទេ មានតែឪពុកម្តាយមួយចំនួនតូច ដែលបានចូលរួមធ្វើកិច្ចការផ្ទះកូន បង្ហាត់បង្រៀននិងពិនិត្យតាមដានការសិក្សាកូនកូនជាប្រចាំ។ រីឯការទំនាក់ទំនងរវាងឪពុកម្តាយនិងសាលារៀននៅមានកម្រិតទាបនៅឡើយដែរដោយឪពុកម្តាយមិនសូវមានពេលទៅទំនាក់ទំនងជាមួយសាលាឯនាយកទៀតសោតក៏មិនសូវបានអញ្ជើញឪពុកម្តាយឲ្យចូលរួមក្នុងសកម្មភាពផ្សេងៗរបស់សាលាដែរ ប៉ុន្តែលោកគ្រូ អ្នកគ្រូបានផ្តល់ព័ត៌មានទាក់ទងទៅនឹងការសិក្សារបស់សិស្ស ការជំរុញ និងលើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមការសិក្សារបស់កូនក្នុងកម្រិតមធ្យម ។ ការសិក្សានេះរកឃើញផងដែរ នូវបញ្ហាប្រឈមមួយចំនួនដែលជះឥទ្ធិពលដល់ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំកូន រួមមាន កង្វះចំណេះដឹងរបស់ឪពុកម្តាយ កត្តាកង្វះពេលវេលានិងបញ្ហាជីវភាពគ្រួសារ កង្វះទំនាក់ទំនងឪពុកម្តាយជាមួយសាលារៀន និងលោកគ្រូ អ្នកគ្រូ ជាហេតុធ្វើឱ្យឪពុកម្តាយមួយ ទទួលបានព័ត៌មានមិនគ្រប់គ្រាន់ទាក់ទងទៅនឹងការសិក្សារបស់កូន និងមិនបានផ្តល់ព័ត៌មានត្រឡប់ទៅសាលាវិញ។ កង្វះចំណេះដឹងរបស់ឪពុកម្តាយ ឪពុកម្តាយមួយចំនួនទៀតមានការលំបាកផងដែរក្នុងការជួយធ្វើកិច្ចការផ្ទះ ឬបង្ហាត់បង្រៀនកូន ដោយសារពួកគាត់ទទួលការអប់រំបានតិចតួច។ ស្របជាមួយគ្នានេះដែរ កត្តាកង្វះពេលវេលាក៏ជាឧបសគ្គដែលរាំងស្ទះដល់ដំណើរការចូលរួមដែរដោយឪពុកម្តាយខ្លះមានការមមារញឹកក្នុងការប្រកបរបរដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការជួយអប់រំបង្ហាត់បង្រៀនកូនផងដែរ។ ប៉ុន្តែទន្ទឹមនឹងនេះដែរ យោងតាមលទ្ធផលនៃ

សិក្សាស្រាវជ្រាវនេះបង្ហាញឱ្យឃើញថា ឪពុកម្តាយភាគច្រើនយល់ច្បាស់ពីតួនាទីរបស់ខ្លួនក្នុងការចូលរួមចំពោះការអប់រំកូន ចង់ឱ្យកូនបន្តការសិក្សាបានខ្ពស់ ដោយធ្វើការជំរុញ និងលើកទឹកចិត្តកូនឱ្យខិតខំរៀនសូត្រជាប្រចាំ ហើយឪពុកម្តាយក៏បានអប់រំទូន្មានកូន និងប្រាប់ពីសារៈសំខាន់នៃការសិក្សាដល់កូនជាប្រចាំផងដែរ។ជាមួយគ្នានេះដែរនាយក នាយិកាសាលា លោកគ្រូ អ្នកគ្រូ ក៏បានចូលរួមចំណែកក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឲ្យចូលរួមចំពោះការសិក្សារបស់កូនពួកគាត់ផងដែរ។

## ៥.២. សំណូមពរ

ដើម្បីឱ្យការចូលរួមរបស់ឪពុកម្តាយចំពោះការសិក្សារបស់កូនមានលក្ខណៈពេញលេញ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ មន្ទីរ សាលារៀន និងឪពុកម្តាយ គួរចូលរួមសហការគ្នានិងចូលរួមគោរពតួនាទីរៀងៗខ្លួនដូចតទៅៈ

**ក្រសួងអប់រំ**

គួរសហការជាមួយភាគីពាក់ព័ន្ធដាក់វិធានការយ៉ាងម៉ឺងម៉ាត់ក្នុងការអប់រំយុវជនគ្រប់រូបឲ្យទទួលបានការសិក្សាអប់រំថ្នាក់មូលដ្ឋានរយៈពេល៩ឆ្នាំឲ្យបានពេញលេញជាកំណត់។

**មន្ទីរអប់រំ**

គួរកំណត់ឲ្យសាលាពង្រឹងការសហការជាមួយឪពុកម្តាយសិស្សឲ្យបានច្រើនជាងនេះ ដើម្បីជានាគុណភាពអប់រំឲ្យកាន់តែប្រសើរឡើង។

**ឪពុកម្តាយ**

- ទៅទំនាក់ទំនងសាកសួរពត៌មានទាក់ទងទៅនឹងការសិក្សារបស់កូនឱ្យបានទៀងទាត់
- ផ្តល់ពត៌មានត្រឡប់ទៅសាលាវិញ
- ព្យាយាមជួយធ្វើកិច្ចការកូន និងបង្ហាត់បង្រៀន ពិនិត្យតាមដានការសិក្សារបស់កូនឱ្យបានទៀងទាត់

**សាលារៀន**

- គួរបន្តធ្វើការជំរុញ និងលើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមចំពោះការសិក្សាសិស្ស

- ផ្តល់ពត៌មានចំពោះការសិក្សារបស់សិស្សជាប្រចាំ
- អញ្ជើញឪពុកម្តាយសិស្សឱ្យចូលរួមសកម្មភាពសាលាតាមដែលអាចធ្វើទៅបាន
- គួរធ្វើការសហការជាមួយអាជ្ញាធរដែនដី ភូមិ ឃុំ ដើម្បីធ្វើការផ្សព្វផ្សាយ និងជំរុញការចូលរួមរបស់ឪពុកម្តាយ

លោកគ្រូ អ្នកគ្រូ

- គួរបន្តការព្យាយាមទំនាក់ទំនង និងផ្តល់ពត៌មានទាក់ទងទៅនឹងការសិក្សារបស់សិស្សឱ្យបានជាប្រចាំ
- ធ្វើការជំរុញ និងលើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមចំពោះការសិក្សាសិស្ស

## ៥.៣. ការសិក្សាស្រាវជ្រាវបន្ត

ការស្រាវជ្រាវនេះធ្វើឡើងតែ ៨ សាលាបឋមសិក្សាដែលជ្រើសចញពី៧ ខណ្ឌក្នុងចំណោមខណ្ឌទាំង១៤ក្នុងរាជធានីភ្នំពេញតែប៉ុណ្ណោះ ហើយការសិក្សានេះធ្វើឡើងក្នុងសម័យកូវិដ មានការលំបាកក្នុងការចុះទៅប្រមូលទិន្នន័យ ចំណែកភាគសំណាកនៃចំនួនឪពុកម្តាយសិស្សមិនបានគ្រប់ចំនួនតាមអ្វីដែលបានគ្រោងទុក ដូច្នេះលទ្ធផលនៃការស្រាវជ្រាវនេះពុំអាចឆ្លើយតបទាំងស្រុងចំពោះលក្ខណៈទូទៅកម្មនៃសាលាទាំងអស់ក្នុងរាជធានីភ្នំពេញឡើយ។ ហេតុដូច្នេះហើយអ្នកសិក្សាស្រាវជ្រាវក្រោយៗគួរពង្រីកចំនួនសាលានិងភាគសំណាកឱ្យបានច្រើនជាងនេះ ។

# ឯកសារយោង

Gordon Gahl and Lance Lochner. (2012). the impact of family income on children Achievement: Evidence from the Earned income Tay Credit.

Li and i Qiu. (2018). How does family background affect children's educational achivement ? Evidence from Contemporary China. *The Journal of Chinese Sociology* .

Mathew R. Sander et Alina Moraws. (2014). *Can changing Parental Knoweledge.*

សម្ដេចសង្ឃរាជ ជួន ណាត. (sense data).

Abdullah. (2011). *Definetion of Parental Involvement.*

Ball &Blachman. (1991). *Does phenome awareness training in kindegerten Make a difference in early word recognition and development.*

Bando, R. g. (2013). Incentives in Education.

Barton. (2004). *Ecologies of parental engagement in Urban Education.*

Chiu, H. y. (2018). *Involvement and participationin pre-primary education governance : a pperspective of Hong Kong parent.* Hong Kong.

Dampsey, K. (2001). *Parental Involment in Homework.*

Dbow, E. I. (2019). Long term Effect of parent's Education on children's educational and occupation Succes: Mediation by Family Interaction child Aggression and Teenage Aspiration.

Dempsey, Kathleen V. Hoover-. (2004). *Parental Involvement in Homwork : A review of Current Research and Its Implication tor Teachers , After School Program Staff , and Parent Leaders.* Harvard: Harvaed Familt Research Project.

Dettmers, S. (2019). Antecedents and Outcomes of Parental Homework Involvement : How Do family- School Partnerships Affect Parental Homework Involvement and Student Outcomes ? *Front .Psychol.*

Dockter, C. (2017). What are parents. *Founder at HealthCare Sleep Products*, p. https;//.www..quora.com/Whatare parents.

Douglas Fisher and Nancy Frey. (2014). *Checking for Understading: Formative Assessment Techniques for Your Classrom* (2nd Edition ed.).

Drajea, C. o. (2014). Influence of parent education and family income on children's education on rural Uganda.

Echoune, M. (2015). Jounal of education on parent involvment in homework and primary school.

Grace Hui Chen Huang, Kimberly. (2015). *Motivation of parental involvment in children's learning.*

Hassan, A. (sense data). What is education . *Academia .edu*, p. https; // www.academia.edu/31432642/What is Education.

Hong and Lee. (2012). *Parent Involvment in children's education* (Vol. 9).

Horny and Lafade. (2018). Barriers to parental involvment in education: An explantatory modeleducation review.

Ireland, K. (2017). Definetion of Parental Involvememt.

Ismic. (11 / june / 2020). The Important of Positive Parent Teacher Relationship.

J.C .Nuner, N. S. (2014). *Student relationship between perceived parental involvement in homework.*

Jaiswal, S. K. (2018). Influent of Parent ' Education on Parental Academic Involvement. *Journal of Advantage and School research*.

Menon, A. (2013). Barres to parental involvment in early childhood. Education classrooms in Mubai Slums as Perceived by parents.

Mucella. (2011). The effect of teacher Attitudes on student personality and performance .

Naziew, A. (2017). what is an education ? *International Conferrence The Future of Education*, p. https/www.reseachgate.net/publication/317545698. What is an education .

Omoniyi, M. B. (2013). The role of education in poverty alleviation and Economic development: a theortical perspective and counselling implication . *British Journal of Art and Socail Sciences , 15*.

Pomerantz. (2007). *How whom and why of parents'in children's academic lives.*

Reed, R. P. (2020). Parent's Motivation in children's Education : testing a theeoritical model. *Parent's motivations for involvment in children's education: testing a theoritical model*.

Richard M. Ray&Edward . (2000). Intrinsic and Extrinsic Motivation : Classic Definition. doi:Doi:10.1006/ceps.1999.1020, available online at http://www.idealibrary.com

Safdar Rehman Ghazi, M. S. (April / 2010). Parental Involvment in Children Academic Motivation. *6*.

Sandler, H. D. (1999). *Parent's reported involvement in students'homeword strrategies and practices .*

Sokhea, T. (2013). *ការចូលរួមរបស់អាណាព្យាបាលក្នុងការពង្រឹងការសិក្សារបស់កូននៅបឋមសិក្សាក្នុងប្រទេសកម្ពុជា.*

Sophoat, S. (2011). *កាចូលរួមរបស់ឪពុកម្តាយក្នុងការអប់រំកុននៅអនុវិទ្យាល័យមួយក្នុងរាជធានីភ្នំពេញ.*

Statistic,U.K Department of Education National Center for Education. (2015). *Education Statistic in U.K.*

Studies, C. f. (2017). School's Partnership Programme.

Swap. (1993). *Developing home school partnerships .* New York.

Sylvie Normandeau and Isabell Nadon. (2020). Revues des sciecne de l'education : la participation des parents a la vie scolaires d'enfants de deuxeme annee.

Tao Lin and Han LV. (2017). The effect of family income on children's education : An emprirical analysis of CHNS data.

U.K essays. (16 / May / 2017). Definition Of Parental Involvement. p. 22.

UNIVERSITY LAMAR. (2019). Correlation Between Parents' Education Level and Children's Success. *LAMAR UNIVERSITY*, degree.lamar.edu. Consultat el April / 2019

Unknow. (2017). Parental involvement as an inportant factor to succesful education. *Center for educational policy studies* , P.3.

WIKI How'Staf. (2010). *Strategies for encourage parental involvement in learning.*

wikipedia. (sense data). *incentive.*

Yamato , Holloway & Suzuki . (2016). *Parental Involvement in school.*

រដ្ឋាភិបាល. (២០០៧). *ច្បាប់ស្តីពីការអប់រំនៅកម្ពុជា.*

រដ្ឋាភិបាល. (២០១៣). យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤និតិកាលទី៦.

រដ្ឋាភិបាល. (2013). យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល.

សាលារៀនសហគមន៍. (2013). *មគ្គុទ្ទេសក៏សម្រាប់មាតាបិតាសិស្ស.* Recollit de www.ousd.k12.ca.us.

អយក. (២០០៦). *កម្មវិធីសិក្សាគោលសម្រាប់ការអប់រំមូលដ្ឋាន.*

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធ " ក "**

## កម្រងសំណួរសម្រាប់ឪពុកម្តាយឬ អាណាព្យាបាល

## សូមជម្រាបសួរលោក លោកស្រីជាទីរាប់អាន

នាងខ្ញុំឈ្មោះ ឈន បូរ៉ា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ នាងខ្ញុំកំពុងសរសេរនិក្ខេបបទ បញ្ចប់ថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ "**ការចូលរួមរបស់ឪពុកម្តាយចំពោះការអប់រំរបស់កូននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ** "។

អាស្រ័យដោយហេតុនេះសូមលោក/លោកស្រីមេត្តាជួយផ្តល់ចម្លើយដោយក្តីអនុគ្រោះផងចុះ។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក/លោកស្រីក្នុងការសហការជាមួយនាងខ្ញុំ។

**<u>ក. អំពីព័ត៌មានផ្ទាល់ខ្លួន</u>**

សូមគូសសញ្ញា √ ក្នុងប្រអប់ និងបំពេញចម្លើយ៖

១. លោក/ លោកស្រី ត្រូវជា ( របស់សិស្ស)

☐ ឪពុក ☐ ម្តាយ ☐ ផ្សេងៗ.........................

២. លោក/ លោកស្រីមានអាយុ

☐ ២០ - ២៥ ឆ្នាំ ☐ ២៥ - ៣៥ ឆ្នាំ ☐ ៣៥ - ៤៥ ឆ្នាំ

៣. លោក/ លោកស្រីបានបញ្ចប់ការសិក្សា

☐ បឋមសិក្សា ☐ អនុវិទ្យាល័យ ☐ វិទ្យាល័យ ☐ បរិញ្ញាបត្រ ☐ ផ្សេងៗ ......

៤. ស្ថានភាពគ្រួសារ

☐ នៅជុំគ្នា ☐ លែងលះ ☐ នៅឆ្ងាយពីគ្នា

៥. លោក/ លោកស្រីប្រកបរបរជា

☐ មន្ត្រីរាជការ ☐ បុគ្គលិកក្រុមហ៊ុន ☐ អាជីវករ ☐ ផ្សេងៗ ...........

៦. ពេលវេលានៃម៉ោងធ្វើការ

☐ ពេញម៉ោង ☐ ក្រៅម៉ោង ☐ កន្លះពេល

៧. លោក/ លោកស្រីទទួលបានប្រាក់កម្រៃ

☐ ២០០ - ៣០០ដុល្លា ☐ ៣១០ -៤០០ដុល្លា ☐ ៤១០ - ៥០០ដុល្លា ☐ ផ្សេងៗ

៨. លោក/ លោកស្រីមានបញ្ហាប្រឈមនៅក្នុងជិវភាព

.............................................................................................................................................

៩. បើមាន មានបញ្ហាលំបាកដូចម្តេចខ្លះ ?

.............................................................................................................................................

.............................................................................................................................................

**.ខ ការចូលរួមរបស់ឳពុកម្តាយចំពោះការសិក្សាកូន**

១០. កូនលោក/ លោកស្រីរៀនថ្នាក់ទី

☐ ទី ៣ ☐ ទី ៤ ☐ ទី ៦

១១. លោក/ លោកស្រីយល់ពីតួនាទី របស់ឳពុកម្តាយ ចំពោះការអប់រំរបស់កូន

☐ មិនបានចាប់អារម្មណ៍ ☐ យល់តិចតួច ☐ យល់ច្បាស់ ☐ យល់ច្បាស់ណាស់

១២. លោក / លោកស្រីគិតថាការចូលរួមរបស់ឳពុកម្តាយមានសារៈសំខាន់

☐ មិនបានចាប់អារម្មណ៍ ☐ យល់តិចតួច ☐ យល់ច្បាស់ ☐ យល់ច្បាស់ណាស់

១៣. កាសិក្សាកូនរបស់លោក/ លោកស្រីទទួលលទ្ធផល

☐ ខ្សោយ ☐ មធ្យម ☐ ល្អបង្គួរ ☐ ល្អ

**ការណែនាំ៖ សូមអានចំនុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកសូមគូសសញ្ញា (√) ទៅតាមកម្រិតនៃ ស្ថានភាពជាក់ស្តែងរបស់លោក លោកស្រី**

| ល.រ | បរិយាយ | ១<br>មិនដែលសោះ | ២<br>ម្តងម្កាល | ៣<br>ជាប្រចាំ | ៤<br>ញឹកញាប់ | ៥<br>ញឹកញាប់ណាស់ |
|---|---|---|---|---|---|---|
| ១៤ | លោក/ លោកស្រីបានពិនិត្យសៀវភៅតាមដានរបស់កូន | | | | | |
| ១៥ | លោក/ លោកស្រីបានពិនិត្យសៀវភៅសរសេររបស់កូន | | | | | |
| ១៦ | លោក/ លោកស្រីបានចូលរួមធ្វើកិច្ចការផ្ទះរបស់កូន | | | | | |
| ១៧ | លោក/ លោកស្រីបានជួយបង្រៀនកូន | | | | | |
| ១៨ | លោក/ លោកស្រីធ្លាប់នាំកូនអានឬធ្វើលំហាត់ | | | | | |
| ១៩ | លោក/ លោកស្រីតែងតែជំរុញ និងលើកទឹកចិត្តកូនឱ្យខិតខំរៀន | | | | | |

២០. លោក/ លោកស្រីបានចូលរួមដូចម្តេចខ្លះ ចំពោះការសិក្សារបស់កូន

..........................................................................................................................................

..........................................................................................................................................

២១ លោក/ លោកស្រីមានបទពិសោធន៍ក្នុងការជួយកូនរៀនសូត្រ ?

..........................................................................................................................................

..........................................................................................................................................

២២. លោក/ លោកស្រី បានជួបការលំបាកអ្វីខ្លះ ក្នុងការចូលរួមការអប់រំរបស់កូន?..........................................................................................................................................

...................................................................................................................................................

.......

មតិយោបល់ ឬ សំណូមពរ

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

## គ. ធ្វើជាអ្នកជំរុញនិងលើកទឹកចិត្តដោយមានការរំពឹងខ្ពស់

២៣. លោក/ លោកស្រីកំណត់ការរំពឹងទុកលទ្ធផលនៃការសិក្សារបស់កូន

☐ មិនធ្លាប់រំពឹង ☐ រំពឹងតិចៗ ☐ រំពឹងខ្ពស់

២៤. លោក/ លោកស្រីចង់ឱ្យកូនរៀនបានខ្ពស់

☐ មិនធ្លាប់គិត ☐ ចង់ឱ្យកូនរៀនល្មម ☐ ចង់ឱ្យកូនរៀនខ្ពស់

២៥ . លោកអ្នកមានវិធីសាស្រ្តអ្វីខ្លះ ក្នុងការលើកទឹកចិត្តកូនអោយខិតខំរៀនសូត្រ ?

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

២៦. លោក/ លោកស្រីបានជួបបញ្ហាប្រឈមអ្វីខ្លះ ក្នុងការជំរុញនិងលើកទឹកតិត្តកូនឲ្យខិតខំរៀនសូត្រ?

...................................................................................................................................................

...................................................................................................................................................

## . ការទំនាក់ទំនងជាមួយនាយក/ នាយិកាសាលា និងគ្រូបង្រៀន

កាណែនាំ៖ សូមអានចំនុចនីមួយៗឱ្យបានច្បាស់លាស់ បន្ទាប់មកគូសសញ្ញា(√)ទៅតាមកម្រិតនៃ ស្ថានភាពជាក់ស្តែងរបស់លោក លោកស្រី៖

| ល.រ | បរិយាយ | ១<br>មិនដែលសោះ | ២<br>ម្តងម្កាល | ៣<br>ជាប្រចាំ | ៤<br>ញឹកញាប់ | ៥ |
|---|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | | ញឹក ញាប់ ណាស់ |
| ២៧ | លោក/ លោកស្រីធ្លាប់ទៅសាកសួរព័ត៌មាន អំពីការសិក្សារបស់កូននៅសាលារៀន | | | | | |
| ២៨ | លោក/ លោកស្រីទទួលបានព័ត៌មានទាក់ទង នឹងការសិក្សារបស់កូន | | | | | |
| ២៩ | សាលាឬ លោកគ្រូ អ្នកគ្រូតែងតែលើកទឹកចិត្ត លោក/ លោកស្រីក្នុងការចូលរួមចំពោះការ សិក្សាកូន | | | | | |
| ៣០ | សាលារៀន ឬលោកគ្រូអ្នកគ្រូបានផ្តល់ ព័ត៌មានអំពីការសិក្សារបស់កូនលោកអ្នក | | | | | |
| ៣១ | សាលារៀនធ្លាប់អញ្ជើញលោក/ លោកស្រីចូល រួមក្នុងសកម្មភាពផ្សេងៗរបស់សាលា | | | | | |

៣២. លោក/ លោកស្រីទទួលបានពត៌មានទាក់ទងនឹងការសិក្សារបស់កូន?

.........................................................................................................................................................

៣៣.បើធ្លាប់ តើលោកគ្រូ អ្នកគ្រូបានផ្តល់ព័ត៌មានអ្វីខ្លះ ទាក់ទងទៅនឹងការសិក្សារបស់កូនលោកអ្នក?

.........................................................................................................................................................

.........................................................................................................................................................

៣៤. សាលារៀនធ្លាប់បានអញ្ជើញលោក/ លោកស្រីឲចូលរួមកម្មវិធីអ្វីខ្លះ នៅសាលារៀន ?

.........................................................................................................................................................

.........................................................................................................................................................

៣៥. លោក/ លោកស្រីមានបញ្ហាលំបាកដែរឬទេក្នុងការទំនាក់ទំនងជាមួយសាលា ?បើមាន មានការលំបាកអ្វីខ្លះ?

.........................................................................................................................................................

.......................................................................................................................................................................

មតិយោបល់ ឬ សំណូមពរ

.......................................................................................................................................................................

.......................................................................................................................................................................

## ខ. ការបង្ហាញឥរិយាបថគំរូរបស់ឪពុកម្ដាយ

៣៦. លោក/ លោកស្រីតែងតែផ្ដល់គំរូដល់កូន

☐ ម្ដងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់សោះ

៣៧. លោក/ លោកស្រីមានកំណត់ពេលដាក់លាក់ចំពោះការប្រើប្រាស់ទូរសព្ទ័របស់កូន

☐ ម្ដងម្កាល ☐ មានការប្រុងប្រយត្ន័ខ្ពស់ ☐ មិនបានយកចិត្តទុក

៣៨. លោក/ លោកស្រីធ្លាប់ផ្ដល់ការអប់រំទូន្មានដល់កូន

☐ ម្ដងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់ទាល់តែសោះ

៣៩. លោក/ លោកស្រីបានបង្ហាញពីសារៈសំខាន់នៃការសិក្សាដល់កូន

☐ ម្ដងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់

៤០. លោក លោកស្រីមានវិធីសាស្ត្រដូចម្ដេចខ្លះក្នុងបង្ហាញពីសារសំខាន់នៃការសិក្សាដល់កូន?

.......................................................................................................................................................................

.......................................................................................................................................................................

៤១. នៅត្រង់ចំណុចនេះតើ លោក លោកស្រីមានបញ្ហាប្រឈម/ បើមានអ្វីខ្លះ ?

.......................................................................................................................................................................

.......................................................................................................................................................................។

**ឧបសម្ព័ន្ធ " ខ "**

## កម្រងសំណួរសម្រាប់លោកគ្រូអ្នកគ្រូ
## សូមជម្រាបសួរលោក លោកស្រីជាទីរាប់អាន

នាងខ្ញុំឈ្មោះ ឈន បូរ៉ា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ នាងខ្ញុំកំពុងសរសេរនិក្ខេបបទ បញ្ចប់ថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ "**ការចូលរួមរបស់ឪពុកម្តាយ ចំពោះការអប់រំរបស់កូននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**"។

អាស្រ័យដោយហេតុនេះសូមលោក/លោកស្រីមេត្តាជួយផ្តល់ចម្លើយដោយក្តីអនុគ្រោះ។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក លោកស្រី ក្នុងការសហការជាមួយនាងខ្ញុំ។

១. លោកគ្រូ អ្នកគ្រូបង្រៀនរយៈពេលប៉ុន្មានឆ្នាំហើយ

..........................................................................................................

២. លោកគ្រូ អ្នកគ្រូបង្រៀនសិស្សថ្នាក់ទីប៉ុន្មាន

☐ ទី៣ ☐ ទី៤ ☐ ទី ៦ ☐ ផ្សេងៗ

..............................

៣ . លោកគ្រូ អ្នកគ្រូមានសិស្សប៉ុន្មាននាក់ក្នុងថ្នាក់ ?

..................................................................................................................................................

៤. លោកគ្រូ អ្នកគ្រូតែងតែដាក់កិច្ចការឱ្យសិស្សធ្វើ

☐ ម្តងម្កាល ☐ ជាប្រចាំ

៥. កិច្ចការដែលលោកគ្រូ អ្នកគ្រូដាក់ឱ្យសិស្សធ្វើសិស្សតែងតែធ្វើ

☐ ធ្វើ ២០% - ៣០% ☐ ធ្វើ៣០% - ៥០% ☐ ធ្វើ៥០% - ៩០%

៦. លោក / លោកស្រីតែងតែទំនាក់ទំនងទៅឪពុកម្តាយ សិស្សទាក់ទងនឹងការសិក្សារបស់កូនៗពួកគាត់ ?

☐ ម្តងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់

៧. លោកគ្រូ / អ្នកគ្រូតែងជំរុញនិង លើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមក្នុងការសិក្សា

☐ ម្តងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់

៨.លោក លោកស្រី បានផ្តល់ព័ត៌មានអ្វីខ្លះ ទៅឪពុកម្តាយសិស្សទាក់ទងទៅនឹងការសិក្សារបស់ពួកគេ?

.................................................................................................................................

.................................................................................................................................

.

៩. លោក លោកស្រីមានវិធីសាស្រ្តដូចម្តេចខ្លះ ក្នុងការជំរុញ និងលើកទឹកចិត្តឪពុកម្តាយឲចូលរួមការសិក្សារបស់កូន?

.................................................................................................................................

.................................................................................................................................

១០. វិធីសាស្រ្តដែលលោក លោកស្រី ប្រើទទួលបានលទ្ធផលដែរទេ ព្រោះអ្វី ?

.................................................................................................................................

.................................................................................................................................

១១. លោក លោកស្រី ជួបបញ្ហាប្រឈមអ្វីខ្លះ ក្នុងការទំនាក់ទំនងជាមួយនឹង ឪពុកម្តាយសិស្ស ?

.................................................................................................................................

.................................................................................................................................

មតិយោបល់ ឬ សំណូមពរ

.................................................................................................................................

.................................................................................................................................

**សូមអរគុណ**

**ឧបសម្ព័ន្ធ " គ "**

## កម្រងសំណួរសម្រាប់នាយក / នាយិកា

## សូមជម្រាបសួរលោកនាយក / លោកស្រីនាយិកាជាទីរាប់អាន

នាងខ្ញុំឈ្មោះ ឈន បូរ៉ា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ នាងខ្ញុំកំពុងសរសេរនិក្ខេបបទ បញ្ចប់ថ្នាក់បរិញ្ញាបត្រក្រោមប្រធានបទ "**ការចូលរួមរបស់ឪពុកម្តាយ ចំពោះការអប់រំរបស់កូននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**"។

អាស្រ័យដោយហេតុនេះសូមលោក/លោកស្រីមេត្តាជួយផ្តល់ចម្លើយដោយក្តីអនុគ្រោះ។ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់លោក/លោកស្រី ក្នុងការសហការជាមួយនាងខ្ញុំ។

### ក. អំពីព័ត៌មានផ្ទាល់ខ្លួន

១. លោក/ លោកស្រីបានបញ្ចប់ការសិក្សា

☐ ចប់ទី១២ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ............។

២. បទពិសោធន៍ការងារៈ

☐៦ ដល់១០ ឆ្នាំឡើង ☐ ១១ ដល់ ១៥ឆ្នាំឡើង ☐ លើសពី១៥ឆ្នាំ

### ខ ការគ្រប់គ្រងទូទៅ

៣. លោក/ លោកស្រីមានសិស្សសរុបចំនួន

..........................................................................................................................................

៤. លោក/ លោកស្រីតែងតែផ្តល់ព័ត៌មានទាក់ទងទៅនឹងការសិក្សារបស់សិស្សទៅឪពុកម្តាយ

☐ម្តងម្កាល ☐ ជាប្រចាំ ☐ មិនសូវមានពេល

៥. ឪពុកម្តាយសិស្សឧស្សាហ៍មកសាកសួរព័ត៌មានអំពីការសិក្សារបស់កូនគាត់

☐ ម្តងម្កាល ☐ ជាប្រចាំ ☐ មិនសូវឃើញមក

៦. លោក/ លោកស្រីតែងតែជំរុញ និងលើកទឹកចិត្តឪពុកម្តាយសិស្សឱ្យចូលរួមក្នុងការសិក្សារបស់កូនៗ

☐ ម្តងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់

៧. លោក/ លោកស្រីធ្លាប់អញ្ជើញឪពុកម្តាយរបស់សិស្សឱ្យចូលរួមសកម្មភាពផ្សេងៗរបស់សាលា

☐ ម្តងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់

៨. លោក/ លោកស្រីធ្លាប់ផ្សព្វផ្សាយព័ត៌មានថ្មីពីកម្មវិធីសិក្សាដល់ឪពុកម្តាយសិស្ស

☐ ម្តងម្កាល ☐ ជាប្រចាំ ☐ មិនដែលសោះ

៩. លោក / លោកស្រីបានអញ្ជើញឪពុកម្តាយសិស្សចេូលរួមកម្មវិធីអ្វីខ្លះនៅសាលារៀន ?

..........................................................................................................................................................

..........................................................................................................................................................

១០. លោក / លោកស្រីមានវិធីសាស្ត្រក្នុងការជំរុញ និង លើកទឹកចិត្តឪពុកម្តាយសិស្សចេូលរួមក្នុងការសិក្សារបស់កូន?

..........................................................................................................................................................

..........................................................................................................................................................

១១. វិធីសាស្ត្រដែល លោក / លោកស្រី ប្រើ ទទួល បានលទ្ធផល/ ព្រោះអ្វី ?

..........................................................................................................................................................

..........................................................................................................................................................

១២. លោក / លោកស្រីមានបញ្ហាប្រឈមអ្វីខ្លះ ក្នុងការទំនាក់ទំនងជាមួយឪពុកម្តាយសិស្ស ?

..........................................................................................................................................................

..........................................................................................................................................................

មតិយោបល់ ឬសំណូមពរ

..........................................................................................................................................................

..........................................................................................................................................................

**សូមអរគុណ**

**ឧបសម្ព័ន្ធ " ឃ "**

## កម្រងសំណួរសម្រាប់សិស្សានុសិស្ស

## សួស្តីក្មួយៗជាទីរាប់អាន

ខ្ញុំឈ្មោះ ឈន បូរ៉ា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ។ នាងខ្ញុំកំពុងសរសេរនិក្ខេបបទ បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ក្រោមប្រធានបទ "**ការចូលរួមរបស់ឪពុកម្ដាយចំពោះការសិក្សារបស់កូននៅបឋមសិក្សាក្នុងរាជធានីភ្នំពេញ**"។

អាស្រ័យដោយហេតុនេះសូមក្មួយៗជួយផ្ដល់ចម្លើយដោយក្ដីអនុគ្រោះ។ អ៊ំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃរបស់ក្មួយៗ ក្នុងការសហការជាមួយអ៊ុំ។

១. កូនជាសិស្សថ្នាក់ទី

☐ ទី៣ ☐ ទី៤ ☐ ទី៦

២. កូនមានអាយុ

☐ ៦ - ៧ ឆ្នាំ ☐ ៨ - ១០ ឆ្នាំ ☐ ១០ - ១២ ឆ្នាំ

៣. ឪពុកម្ដាយកូនធ្លាប់នាំកូនអានសៀវភៅ ឬ ធ្វើលំហាត់

☐ ម្ដងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់ទេ

៤. កូនធ្លាប់សុំឱ្យឪពុកម្ដាយជួយធ្វើកិច្ចការផ្ទះ

☐ ម្ដងម្កាល ☐ ជាប្រចាំ ☐ មិនធ្លាប់

៥. ពួកគាត់ជួយធ្វើកិច្ចការផ្ទះកូន

☐ មិនដែល ☐ ជួយខ្លះ ☐ ជាប្រចាំ

៦. គាត់មានពេលគ្រប់គ្រាន់ដើម្បីជួយកូនដែរ

☐ បានជួយ ☐ ជួយខ្លះអត់ខ្លះ ☐ មិនបានជួយ

៧. ពួកគាត់បានបង្រៀនកូនហើយ បង្រៀនអ្វីខ្លះ

.......................................................................................................................................................

.......................................................................................................................................................

៨. ការជួយរបស់គាត់បានធ្វើឱ្យការសិក្សារបស់កូនប្រសើរឡើង ?

..........................................................................................................................................................................................

..........................................................................................................................................................................................

៩. ការសិក្សានៅផ្ទះ    ប្អូនជួបការលំបាក ហើយ  បើមាន  ជួបការលំបាកដូចម្តេចខ្លះ ?

..........................................................................................................................................................................................

..........................................................................................................................................................................................

មតិយោបល់ ឬ សំណូមពរ

..........................................................................................................................................................................................

..........................................................................................................................................................................................

**អរគុណ**!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**
**លេខ.....✓.....វជអ**

## បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧
## កាលបរិច្ឆេទទទួលនិក្ខេបបទស្រាវជ្រាវ

| ជំពូក | ចំណងជើង | កាលបរិច្ឆេទ | ថ្ងៃកំណត់ |
|---|---|---|---|
| ១ | សេចក្តីផ្តើម | ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ២ | រំលឹកទ្រឹស្តី | ថ្ងៃទី១២ ខែមេសា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៣ | វិធីសាស្ត្រស្រាវជ្រាវ | ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៤ | វិភាគស៊ីជម្រៅលើលទ្ធផលរបកគំហើញ និងការ ពិភាក្សា | ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |
| ៥ | សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ | ថ្ងៃអាទិត្យ |

កំណត់សម្គាល់:

- ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០ ទទួលនិក្ខេបបទ នៅគណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាល ថ្នាក់ក្រោយឧត្តម នៅវិទ្យាស្ថានជាតិអប់រំ។
- ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ **បទបង្ហាញសាកល្បង**ការពារការសរសេរនិក្ខេបបទ។
- ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ពិធីការពារការនិក្ខេបបទរៀបចំដោយ គណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមនៅវិទ្យាស្ថានជាតិអប់រំ។

រាល់ចម្ងល់ពីការសរសេរនិក្ខេបបទស្រាវជ្រាវសូមទាក់ទងគណៈកម្មការប្រតិបត្តិនៃការបណ្តុះបណ្តាលថ្នាក់ក្រោយឧត្តមសម្រាប់កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា។ លោក  បណ្ឌិត នួវ រ៉ា នាយករង វិទ្យាស្ថានជាតិអប់រំ និងលោក ចាប រតនា អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ ។

ថ្ងៃ សុក្រ ០៤ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០២០
**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សឿង សុវណ្ណា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជននិងកីឡា

មន្ទីរអប់រំ យុវជននិងកីឡារាជធានីភ្នំពេញ

លេខ [illegible] អយក.ភ

ថ្ងៃ[illegible] ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញថ្ងៃទី.[illegible]....ខែ កក្កដា ឆ្នាំ ២០២០

**ប្រធានមន្ទីរអប់រំ យុវជននិងកីឡារាជធានីភ្នំពេញ**

**ជម្រាបមក**

**លោកនាយក វិទ្យាស្ថានជាតិអប់រំ**

**កម្មវត្ថុ** ៖ - ករណីសំណើសុំឱ្យអ្នកស្រី **ឈន ចូរ៉ា** និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ធ្វើកម្មសិក្សាស្រាវជ្រាវនៅសាលាបឋមសិក្សានានាក្នុងរាជធានីភ្នំពេញ ដើម្បីសរសេរបញ្ចប់និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

**យោង** ៖ - លិខិតលេខ ១១៤ វជអ.ផក ចុះថ្ងៃព្រហស្បតិ៍ ១១រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០ របស់**វិទ្យាស្ថានជាតិអប់រំ** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **លោកនាយក** មេត្តាជ្រាបថា៖ ចំពោះសំណើសុំឱ្យអ្នកស្រី **ឈន ចូរ៉ា** និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ របស់ក្រសួង អប់រំ យុវជន និងកីឡា ចុះស្រាវជ្រាវលើប្រធានបទស្ដីពី "**ការចូលរួមរបស់ឪពុកម្ដាយ និង សហគមន៍ចំពោះការអប់រំរបស់កូន នៅសាលាបឋមសិក្សាក្នុងរាជធានីភ្នំពេញ**" ដើម្បីសរសេរបញ្ចប់និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ដោយធ្វើការសម្ភាសន៍តាមប្រព័ន្ធ ONLINE ពីគណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ មាតាបិតា និងសិស្សានុសិស្សថ្នាក់ទី២ ទី៤ និងទី៦ ដែលកំពុងសិក្សានៅសាលាបឋមសិក្សាក្នុងរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១៧ ខែកក្កដា រហូតដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០នោះ មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ មិនយល់ទាស់លើសំណើនេះទេ។

អាស្រ័យហេតុនេះ សូម **អ្នកស្រី ឈន ចូរ៉ា** ជួបពិភាក្សាផ្ទាល់ជាមួយលោកប្រធានការិយាល័យអប់រំយុវជន និងកីឡា នៃរដ្ឋបាលខណ្ឌគោលដៅ និងលោកនាយកសាលាបឋមសិក្សាពាក់ព័ន្ធ ដើម្បីអនុវត្តតាមខ្លឹមសារខាងលើដោយចៀសវាងប៉ះពាល់ម៉ោងសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិករបស់សិស្ស និងការងាររដ្ឋបាល។

សូម**លោកនាយក** ទទួលនូវការគោរពរាប់អានពីខ្ញុំ។

**ជ. ប្រធានមន្ទីរអប់រំ យុវជននិងកីឡារាជធានីភ្នំពេញ**

**អនុប្រធាន**

**អ៊ុក-ចន្ថា**

**ចម្លងជូន**

- ក្រសួងអប់រំ យុវជន និងកីឡា(នា.បឋមសិក្សា)
- រដ្ឋបាលរាជធានីភ្នំពេញ

"**ដើម្បីសូមមេត្តាជ្រាបជាព័ត៌មាន**"

- គ្រប់ការិយាល័យមន្ទីរអយក.ភ
- ការិយាល័យអយក.នៃរដ្ឋបាលខណ្ឌ

"**ដើម្បីជាព័ត៌មាន និងមុខការ**"

- សាលាបឋមសិក្សា ពាក់ព័ន្ធ

"**ដើម្បីបង្គាប់ណៈ និងសហការ**"

- ឯកសារ.កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ
ការិយាល័យបឋមសិក្សា

## បញ្ជីឈ្មោះសាលាបឋមសិក្សាដែលត្រូវចុះប្រមូលទិន្នន័យ

តារាង ឈ្មោះខណ្ឌ និងសាលា

| ល.រ | ខណ្ឌ | សាលា | កាលបរិច្ឆេទចុះប្រមូលទិន្នន័យ |
|---|---|---|---|
| ១ | ជ្រោយចង្វារ | បឋមសិក្សា ព្រែកលៀប | ០១-សីហា-២០២០ |
| ២ | សែនសុខ | បឋមសិក្សា ភ្នំពេញថ្មី | ០១-សីហា-២០២០ |
| ៣ | ៧មករា | បឋមសិក្សា បាក់ទូក | ០៤-សីហា-២០២០ |
| ៤ | ចំការមន | បឋមសិក្សា វត្តទួលទំពូង | ០៦-សីហា-២០២០ |
| ៥ | មានជ័យ | បឋមសិក្សា ចម្រើនផល | ០៨-សីហា-២០២០ |
| ៦ | ឫស្សីកែវ | បឋមសិក្សា ចំរើនរដ្ឋ | ០៨-សីហា-២០២០ |
| | | បឋមសិក្សា ឫស្សីកែវ | ១០-សីហា-២០២០ |
| ៧ | ព្រែកព្នៅ | បឋមសិក្សា សំរោងជើង | ១០-សីហា-២០២០ |
| សរុប | ៧ | ៨ | |

ថ្ងៃ អង្គារ៨កើត ខែ ស្រាពណ៍ ឆ្នាំ ជូតទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០
ប្រធានការិយាល័យបឋមសិក្សា

[illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**មន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ**

**ការិយាល័យបឋមសិក្សា**

## បញ្ជីឈ្មោះសាលាបឋមសិក្សាដែលត្រូវចុះប្រមូលទិន្នន័យ

តារាង ឈ្មោះខណ្ឌ និងសាលា

| ល.រ | ខណ្ឌ | សាលា | កាលបរិច្ឆេទចុះប្រមូលទិន្នន័យ |
|---|---|---|---|
| ១ | ជ្រោយចង្វារ | បឋមសិក្សា ព្រែកលៀប | ០១-សីហា-២០២០ |
| ២ | សែនសុខ | បឋមសិក្សា ភ្នំពេញថ្មី | ០១-សីហា-២០២០ |
| ៣ | ៧មករា | បឋមសិក្សា បាក់ទូក | ០៤-សីហា-២០២០ |
| ៤ | ចំការមន | បឋមសិក្សា វត្តទូលទំពូង | ០៦-សីហា-២០២០ |
| ៥ | មានជ័យ | បឋមសិក្សា ចម្រើនផល | ០៨-សីហា-២០២០ |
| ៦ | ឫស្សីកែវ | បឋមសិក្សា ចំរើនរដ្ឋ | ០៨-សីហា-២០២០ |
| | | បឋមសិក្សា ឫស្សីកែវ | ១០-សីហា-២០២០ |
| ៧ | ព្រែកព្នៅ | បឋមសិក្សា សំរោងជើង | ១០-សីហា-២០២០ |
| សរុប | ៧ | ៨ | |

ថ្ងៃ អង្គារ៨កើត ខែ ស្រាពណ៍ ឆ្នាំ ជូតទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០២០

ប្រធានការិយាល័យបឋមសិក្សា

ព្រាប ក្សេមះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :..............វជអ.

# លិខិតអញ្ជើញ

**សូមគោរពអញ្ជើញ ៖** **និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ដើម្បីចូលរួម** ៖ ការពារនិក្ខេបបទ

**កាលបរិច្ឆេទ** ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

**ទីកន្លែង** ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សឿង សុវណ្ណា

*ព័ត៌មានបន្ថែម ៖*

- ✓ *សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវធំខ្មៅឬខៀវចាស់ និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។*
- ✓ *និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។*